លេខ២៨ ខែកញ្ញា ឆ្នាំ២០០៦
Issue 28 September 2006

# ទស្សនាវដ្ដីសុខភាព
# Health Messenger

ចែកចាយទូទាំងប្រទេស
Nationwide distribution

## ជំងឺផ្ដាសាយបក្សី
## Avian Influenza





USAID
FROM THE AMERICAN PEOPLE

Australian Government
AusAID

Health Messenger is published by Ponleu Sokhapheap (PSP).

It is a bilingual training magazine providing updated information on the most urgent public health issues in Cambodia.

**Over 20,000 copies reach all public health providers, every quarter.**

**99%** **of readers rely on Health Messenger for up-to-date health information**

(PSP Monitoring and Evaluation survey)

"I use Health Messenger to provide community education. The information is good, up-to-date and easy to understand. I always receive my copy of Health Messenger every three months."

*Khiev Sophy, Kork Balang Health Centre Mongkol Borey, Banteay Meanchey*

## Health Messenger : an effective tool for sharing updated information

## ...be involved in Health Messenger

**Advertise** **Subscribe** **Sponsor***







## Health Messenger Back Issues for sale at PSP Office

1. Diarrhea Diseases
2. Mother and Child Health
3. ARI
4. Immunization and Vitamin A
5. Tuberculosis
6. Malaria
7. Dengue Fever
8. HIV/AIDS (1)
9. HIV/AIDS (2)
10. Sexually Transmitted Infections
11. Nutrition for Children
12. Integrated Management of Childhood Illness
13. Antenatal Care
14. Birth Spacing
15. Mental Health
16. Water and Health
17. Postnatal Care
18. Well-Functioning Health Center
19. Outreach Services
20. Child Health 1: Healthy Mother, Healthy Baby
21. Child Health 2: Improving Child Survival
22. Adolescent Reproductive Health
23. Tuberculosis
24. HIV/AIDS: VCCT and PMTCT
25. Leprosy
26. HIV/AIDS: Providing a Comprehensive Continuum of Care
27. Clients' Rights, Providers' Rights and Duties, Medical Ethics
28. Avian Influenza

**Ponleu Sokhapheap (PSP)**
**House 34, Street 304, Phnom Penh**
**hmess@online.com.kh**
**023 212 600**

*Sponsorship of individual pages or feature topics available. Contact PSP for details.

**We are very grateful to the Editorial Committee for providing technical advice for this issue:**

***MoH***
Dr Sok Touch
Dr Ly Sovann

***NCDM***
Mr Ross Sovann

***MAFF***
Dr Som San

***WHO***
Dr Megge Miller

***FAO***
Dr Friederike Mayen

***USAID***
Mr Jonathan Ross
Dr Chak Chantha
Dr Nop Sotheara

***UNICEF***
Mr Heng Santepheap

***AED***
Ms Angelique Smit

***US CDC***
Dr William Brady

•

***Special thanks to:***
Battambang PHD and
Mongkol Borey District Animal Health Workers

•

**Health Messenger is published by**
**Ponleu Sokhapheap (PSP)**

**• Board of Directors •**

***President***
Dr Chea Samnang

***Vice President***
Dr Ly Chenghuy

***Secretary General***
Mr Jérôme Turcas

***Board Members***
Dr Im Sarun
Ms Michelle Lang Alli

**• Executive Team •**


***Director/Editor***
Mr Lao Chantha


***Project Manager***
Mr Soun Solinh


***Admin & Accounting***
Mr Thap Bun Chhean


***Distribution, Marketing & Advertising***
Mr Yin Dina


***Technical Advisor (VSO)***
Ms Tammy Loverdos


***Office Assistant***
Ms Long Chansophea



***Packing and Delivery***
Mr Sok Von
Mr Um Bun Than

**• Design and Layout by PSP •**
Assistant Designer: Ms Chhour Maly

**• Reproduction and Printing •**
Entry Meas Printing House

Thank you to **VSO's SHINE** project for sponsoring the distribution of Health Messenger to Stung Treng.

**Ponleu Sokhapheap (PSP)**
**#34, Street 304, Olympic, Chamkarmon, Phnom Penh, Cambodia**
**PO Box 464**
**Tel: 023 212 600**
**Email: hmess@online.com.kh**

Please contact the publisher if you would like to reproduce any part of Health Messenger.

## ចំពោះមិត្តអ្នកអាន

យើងខ្ញុំសូមថ្លែងអំណរគុណដល់មិត្តអ្នកអាន អ្នកជាវ និងអ្នកគាំទ្រសៀវភៅទស្សនាវដ្ដីសុខភាពទាំងអស់ ដែលបានជួយធ្វើឱ្យចំនួនបោះពុម្ពកើនឡើងយ៉ាងខ្ពស់ក្នុងពេលនេះ។ សៀវភៅទស្សនាវដ្ដីសុខភាពលេខនេះកំពុងត្រូវបានចែកចាយដោយឥតថ្លៃដល់មិត្តអ្នកអានប្រហែល ៣០០០០ នាក់នៅទូទាំងប្រទេសកម្ពុជា។ យើងខ្ញុំសង្ឃឹមថាមិត្តអ្នកអានទាំងអស់នឹងបន្តចែករំលែកសៀវភៅនេះ ដូច្នេះនឹងមានមនុស្ស កាន់តែច្រើនបានយល់អំពីសារៈសំខាន់នៃការបង្ការជំងឺផ្ដាសាយបក្សីនេះ។

មួយផ្នែកធំនៃជោគជ័យរបស់សៀវភៅនេះគឺអាស្រ័យដោយការគាំទ្ររបស់មិត្តអ្នកអាន។ ជាមួយនឹងមតិយោបល់ និងព័ត៌មានត្រឡប់របស់មិត្តអ្នកអាន អង្គការពន្លឺសុខភាពអាចបន្តអភិវឌ្ឍសៀវភៅនេះឱ្យទៅជាសៀវភៅមួយដែលមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតំរូវការរបស់មិត្តអ្នកអាន។

យើងកំពុងមានផែនការសំរាប់អភិវឌ្ឍសៀវភៅទស្សនាវដ្ដីសុខភាពក្នុងពេលអនាគត ដូច្នេះសូមបន្តអានសៀវភៅទស្សនាវដ្ដីសុខភាព និងផ្ញើមកយើងខ្ញុំនូវរាល់សំណួមពរដែលមិត្តអ្នកអានមាន។

សូមអរគុណចំពោះការគាំទ្ររបស់មិត្តអ្នកអានទាំងអស់។

ឡាវ ចន្ថា

## លិខិតពីនិពន្ធនាយក
## FROM THE EDITOR



Dear readers,

Thank you to our readers, subscribers and supporters for helping Health Messenger reach its highest print run to date. This issue of Health Messenger is being distributed free of charge to nearly 30,000 readers throughout Cambodia. We hope our readers continue to share the magazine so many more people can understand the importance of preventing avian influenza.

The success of this publication is largely due to our readers. With your comments and feedback, PSP continues to develop Health Messenger into an effective tool that is more relevant and meets your needs.

We have exciting plans for the development of Health Messenger in the future, so keep reading and let us know if you have any suggestions.

We sincerely thank you for your support.

Lao Chantha

**This publication is made possible by the generous support of the American people through the United States Agency for International Development (USAID). The contents do not necessarily reflect the views of USAID or the United States Government.**

The procedure, explanations and treatment given in this publication are based on research and consultation with medical and nursing authorities, and the National Programmes of Cambodia. They all reflect accepted medical practices. Nevertheless they cannot be considered absolute and universal recommendations. The publishers, authors, sponsors and associates disclaim any responsibility for any adverse effects resulting directly or indirectly from the suggested procedures, from any undetected errors, or from the readers' misunderstanding of the text. Advertisements and sponsored pages are included in this issue solely for cost-recovery purposes of the publisher. The inclusion of advertising does not constitute an endorsement by sponsor of the products/services so advertised. The sponsor has no connection with the advertisements or pages sponsored.

ទស្សនាវដ្តីសុខភាព
Health Messenger

លេខ២៨ ខែកញ្ញា ឆ្នាំ២០០៦ Issue 28 September 2006

We sincerely thank USAID for sponsoring the publication and distribution of this issue of Health Messenger.
This issue is published in close co-operation with the Ministry of Health. Thank you to all our contributors.

# មាតិការឿង Contents


**1** ការឆាប់រកឃើញ - ការឆាប់ឆ្លើយតប
Early Detection - Early Response

**4** ចំណេះដឹងមូលដ្ឋាននៃជំងឺផ្តាសាយ
The Basics of Influenza

- **5** ជំងឺផ្តាសាយធម្មតានៅលើមនុស្ស
  Seasonal Influenza (influenza in humans - "the flu")
- **8** ជំងឺផ្តាសាយបក្សី (ជំងឺផ្តាសាយនៅលើបក្សី)
  Avian Influenza (influenza in birds - "bird flu")
- **13** ជំងឺផ្តាសាយបក្សីលើមនុស្ស
  Avian Influenza in Humans
- **16** ជំងឺផ្តាសាយដែលផ្ទុះឡើងរាតត្បាតជាសកល
  Pandemic Influenza

**25** ស្ថានភាពបច្ចុប្បន្ននៃជំងឺផ្តាសាយបក្សីនៅក្នុងប្រទេសកម្ពុជា
Current Situation of Avian Influenza in Cambodia

**32** ផែនការជាតិស្តីពីជំងឺផ្តាសាយបក្សី និងជំងឺផ្តាសាយធម្មតា
National Comprehensive Avian and Human Influenza Plan

**37** ការបង្ការជំងឺផ្តាសាយបក្សីនៅលើសត្វ
Prevention of Avian Influenza in Animals

**50** ការបង្ការជំងឺផ្តាសាយបក្សីនៅលើមនុស្ស
Prevention of Avian Influenza in Humans

**67** ការបង្ការការឆ្លងជំងឺ
Infection Control

**73** ការព្យាបាលអ្នកជំងឺផ្តាសាយបក្សី
Case Management of Avian Influenza in Humans

**80** ការរៀបចំផែនការជាស្រេចសំរាប់ការផ្ទុះជំងឺផ្តាសាយឆ្លងរាតត្បាតជាសកល
Influenza Pandemic Preparedness













# អារម្ភកថា

ជំងឺផ្តាសាយបក្សីបានកើតឡើងជាលើកដំបូងនៅក្រុងហុងកុងក្នុងឆ្នាំ១៩៩៧ ហើយចាប់តាំងពីពេលនោះមក ជំងឺនេះបានឆ្លងរាលដាលនៅទូទាំងទ្វីបអាស៊ី អឺរ៉ុប និងអាហ្វ្រិក។ នៅពេលសរសេរអារម្ភកថានេះ មានមនុស្សចំនួន១៨៤នាក់នៅទូទាំងពិភពលោក បានស្លាប់ដោយសារជំងឺផ្តាសាយបក្សី និងមានសត្វមាន់-ទាជាង២០០លានក្បាលត្រូវបានសំលាប់ ដើម្បីបង្ការមិនឱ្យជំងឺសត្វឆ្លងរាលដាល និងបំលែងខ្លួនទៅជាជំងឺរបស់មនុស្ស។ ទោះបីជាប្រទេសកម្ពុជាស្ថិតក្នុងតំបន់ដែលទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរ ពីជំងឺផ្តាសាយបក្សីក្តី ក៏យើងនៅតែមានសំណាងល្អដែរ ព្រោះរហូតមកដល់បច្ចុប្បន្ននេះ មានមនុស្សតែ៦នាក់ប៉ុណ្ណោះ ដែលត្រូវបានបញ្ជាក់ថា បានស្លាប់ដោយសារជំងឺនេះ។ ប៉ុន្តែប្រវត្តិសាស្ត្របានបង្ហាញថា ពិតជាមានការគំរាមកំហែងនៃការផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកលមែន។ ក្នុងឆ្នាំ១៩១៨ ពិភពលោកបានទទួលរងគ្រោះដោយជំងឺផ្តាសាយដែលផ្ទុះឡើងរាតត្បាតជាសកល និងបានសំលាប់មនុស្សចំនួនពី២០លាន ទៅ៤០លាននាក់ នៅទូទាំងពិភពលោក។ ប្រភេទវីរុសជំងឺផ្តាសាយនេះបានចាប់ផ្តើមពីជំងឺផ្តាសាយបក្សី។ ដូច្នេះ យើងត្រូវតែប្រុងប្រយ័ត្នយ៉ាងខ្លាំងចំពោះការគំរាមកំហែងនេះ ដើម្បីបង្ការការឆ្លងរាលដាលនៃវីរុស H5N1 របស់ជំងឺផ្តាសាយបក្សីនេះនៅក្នុងប្រទេសកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់អំពីតំរូវការជាបន្ទាន់ក្នុងការចាត់វិធានការយ៉ាងឆាប់រហ័សដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺផ្តាសាយបក្សីក្នុងប្រទេសកម្ពុជា។ ដោយមានកិច្ចសម្របសម្រួលពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងសុខាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងផ្តល់ការដឹកនាំដ៏ចាំបាច់ដើម្បីបង្ការការឆ្លងរាលដាលថែមទៀតនៃជំងឺផ្តាសាយបក្សី និងកំពុងធ្វើការរៀបចំដើម្បីធានាថា ប្រទេសយើងបានត្រៀមខ្លួនជាស្រេចក្នុងការឆ្លើយតបក្នុងពេលមានការផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកល។ តាមរយៈជំនួយថវិកានិងជំនួយបច្ចេកទេសពីសហរដ្ឋអាមេរិក ប្រទេសជប៉ុន អាឡឺម៉ង់ អូស្ត្រាលី និងប្រទេសផ្សេងៗទៀត ក៏ដូចជាពីអង្គការអន្តរជាតិនានា ដែលរួមមានអង្គការសុខភាពពិភពលោក អង្គការ UNICEF និងអង្គការ FAO កំពុងធ្វើការរួមគ្នាជាមួយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលនៅតាមសហគមន៍នានា លើវិធានការបង្ការ និងការត្រៀមខ្លួនជាស្រេចសំរាប់ប្រឈមមុខនឹងការឆ្លងរាតត្បាតជាសកល។

សៀវភៅទស្សនាវដ្តីសុខភាពលេខនេះ ផ្តល់នូវទិដ្ឋភាពទូទៅអំពីជំងឺផ្តាសាយបក្សី។ វាផ្តោតជាសំខាន់ទៅលើការប្រព្រឹត្តជាអាទិភាពរបស់រដ្ឋាភិបាល ក្នុងការបង្ការការឆ្លងរាលដាលនៃជំងឺផ្តាសាយបក្សីពីសត្វទៅសត្វ និងពីសត្វទៅមនុស្ស។ សៀវភៅ នេះក៏ពិភាក្សាអំពីវិធីដែលមន្ត្រីសុខភាពសត្វនិងមនុស្សត្រូវឆ្លើយតបទៅនឹងករណីសង្ស័យ និងករណីមនុស្សនិងសត្វដែលត្រូវបានបញ្ជាក់ថា បានឆ្លងជំងឺផ្តាសាយបក្សី ដើម្បីកាត់បន្ថយជាអតិបរមានូវការប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងរាលដាលបន្ថែមទៀត។ វិធានការការពារដែលយើងបានដាក់ចេញនាពេលបច្ចុប្បន្ននេះ នឹងធ្វើឱ្យយើងត្រៀមខ្លួនជាស្រេចសំរាប់ការគំរាមកំហែងនៃជំងឺដែលយើងមិនស្គាល់នាពេលអនាគត ហើយក៏អាចកាត់បន្ថយការមានជំងឺ និងមរណៈភាពដែលក្នុងពេលនេះបណ្តាលមកពីជំងឺផ្លូវដង្ហើម និងជំងឺរាគ។

ដោយយើងបានធ្វើការរួមគ្នា យើងនឹងអាចការពារប្រជាជនកម្ពុជាពីការគំរាមកំហែងដោយជំងឺផ្តាសាយបក្សី។ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះការប្តេជ្ញាចិត្ត និងសេវាកម្មរបស់លោកអ្នក។

**វេជ្ជ. សុខ ទូច**
ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង
ក្រសួងសុខាភិបាល

**បណ្ឌិតវេជ្ជ សិន សាន**
ប្រធានមជ្ឈមណ្ឌលជាតិស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ឯ.ឧ បណ្ឌិត ញឹម វណ្ណដា**
អនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

ម.ព.ឯ.ក AIDOC
Code: 231-025
Date:
Donated by:

# Editorial

Avian influenza first emerged in Hong Kong in 1997 but has since spread throughout Asia and to Europe and Africa. At the time this editorial was written, 144 people world-wide had died from avian influenza and over 200 million birds, primarily ducks and chickens, had been culled in an effort to prevent the animal disease from spreading and mutating into a human disease. Though Cambodia is in the region that has been most affected by avian influenza, we have been fortunate to only have 6 confirmed human deaths thus far. But history shows that the threat of a global pandemic is real. In 1918 the world was struck by a pandemic flu which killed between 20 million and 40 million people world-wide. This strain of flu was recently identified as a mutation of an avian influenza, thus we must take the threat from the H5N1 strain seriously to prevent it from mutating into a human disease and spreading within Cambodia and beyond.

The Royal Government of Cambodia has recognized the urgent need to move quickly to prevent the spread of avian influenza in Cambodia. Under the coordination of the National Committee for Disaster Management, the Ministry of Health and Ministry of Agriculture, Forestry and Fisheries are providing the leadership needed to prevent further spread of avian influenza and making preparations to ensure our country is prepared to respond in the event of a widespread outbreak. Through funding and technical assistance from the USA, Japan, Germany, Australia and others, international organizations, including the WHO, UNICEF, and FAO, are working in partnership with the Royal Government of Cambodia and community based non-governmental organizations on prevention and pandemic preparedness measures.

This issue of Health Messenger provides an overview of avian influenza. It highlights your government's recommended priority behaviors for prevention of transmission of avian influenza between animals and from animals to humans. It also discusses how health personnel, for both humans and animals, must respond to suspect and confirmed human and animal cases of avian influenza to minimize the risk of further spread. The protective measures we put in place now will prepare us for future threats from unknown diseases, and may also reduce the sickness and death currently caused by respiratory infections and diarrhea.

By working together we will be able to protect the people of Cambodia from the threat of avian influenza. Thank you for your commitment and service.

**Dr Sok Touch**
Director, CDC Department
Ministry of Health

**Dr Sorn San**
Head, NAHPIC
Ministry of Agriculture, Fisheries and Forestry

**H.E. Dr Nhim Vanda**
First Vice President
National Committee for Disaster Management

# ការឆាប់រកឃើញ - ការឆាប់ឆ្លើយតប

## Early Detection - Early Response

ពេញក្នុងសៀវភៅទស្សនាវដ្ដីសុខភាពលេខនេះ លោកអ្នកត្រូវបានលើកទឹកចិត្តឱ្យចូលរួមចំណែកក្នុងការបង្ការការចំលងជំងឺផ្ដាសាយបក្សី ដោយរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរដែលពាក់ព័ន្ធ នូវរាល់ករណីសត្វ និងមនុស្សដែលសង្ស័យថាមានជំងឺនេះ។ ដូច្នេះនៅរាល់ពេលដែលលោកអ្នកឃើញសញ្ញា "**រាយការណ៍ជាបន្ទាន់**" នេះ សូមទាក់ទងទៅអាជ្ញាធរខាងក្រោម:

**Throughout this issue of Health Messenger, you are encouraged to play your part in controlling the spread of avian influenza by reporting suspected animal and human cases to the relevant authorities.**

Where you see this symbol: **"Report immediately"** please contact any of the following:



## រាយការណ៍ជាបន្ទាន់

## Report Immediately



### សត្វមាន់_ទាឈឺ ឬងាប់

មជ្ឈមណ្ឌលជាតិស្រាវជ្រាវ
ផលិតកម្ម និងបសុព្យាបាល

**012 833 795**
**012 214 970**

ឬទាក់ទងភ្នាក់ងារសុខភាពសត្វភូមិ
ពេទ្យសត្វស្រុក ឬខេត្ត
ឬទាក់ទងប្រធានភូមិ ឬសមាជិកក្រុមប្រឹក្សាឃុំ

**For sick or dead poultry contact the MAFF hotline**
Or the Village Animal Health Worker, district or provincial vet, or talk to your Village Leader or a Commune Council Member

### ករណីមនុស្សដែលសង្ស័យថាមានជំងឺផ្ដាសាយបក្សី

សូមអ្នកទាក់ទងមកក្រសួងសុខាភិបាល

**012 488 981**
**012 836 868**

ឬទាក់ទងក្រុមឆ្លើយតបបន្ទាន់របស់
ក្រសួងសុខាភិបាលនៅក្នុងខេត្តរបស់លោកអ្នក
ឬទាក់ទងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ
ឬមន្ទីរសុខាភិបាលនៅក្នុងខេត្តរបស់លោកអ្នក

**For suspected human cases, contact the MoH hotline**
Or the provincial MoH Rapid Response Team, or talk to your OD or PHD

# ក្រុមមន្ត្រីឆ្លើយតបបន្ទាន់របស់ក្រសួងសុខាភិបាល
# Ministry of Health Rapid Response Team

នៅគ្រប់ខេត្តទាំងអស់សុទ្ធតែមានក្រុមមន្ត្រីឆ្លើយតបបន្ទាន់។ ក្រុមនេះនឹងមកតំបន់របស់អ្នកជាបន្ទាន់ដើម្បីចាប់ផ្តើមស្រាវជ្រាវ។ ក្រុមមន្ត្រីឆ្លើយតបបន្ទាន់នឹងប្រមូលយកវត្ថុវិភាគដើម្បីយកទៅវិភាគនៅវិទ្យាស្ថានប៉ាស្ទ័រនៅភ្នំពេញ ក្នុងរយៈពេល២៤ម៉ោង។

ដើម្បីទាក់ទងក្រុមមន្ត្រីឆ្លើយតបបន្ទាន់នៅក្នុងខេត្តរបស់លោកអ្នក សូមប្រើលេខទូរស័ព្ទខាងក្រោម:

Every province has a qualified **Rapid Response Team**. This team will come immediately to your area to start an investigation. The Rapid Response Team will collect samples to send to Pasteur Institute in Phnom Penh (within 24 hours) for analysis.

To contact the Rapid Response Team in your area, please use the following telephone numbers:

| | | | | |
|---|---|---|---|---|
| **ភ្នំពេញ**<br>**Phnom Penh** | សរ បញ្ញា<br>Sor Pagna<br>011 811 403 | មុំ គី<br>Mom Ky<br>011 956 569 | ដួង បៀន<br>Doung Bien<br>011 809 090 | ផៃ សារីម<br>Phay Sarim<br>012 878 972 |
| **កណ្ដាល**<br>**Kandal** | គឹក ធានអិន<br>Keuk Thean Orn<br>012 877 198 | ឡុត សុខឿន<br>Loth Sokhoeun<br>012 852 971 | មាស ហួត<br>Meas Houth<br>016 602 889 | គួង ឈុនលី<br>Koung Chhunly<br>012 578 099 |
| **បាត់ដំបង**<br>**Battambang** | ជូ សឺត<br>Chu Seuth<br>012 947 440 | អ៊ុក វិជ្ជា<br>Ouk Vitchea<br>012 897 342 | ស៊ី ប៊ុនយឺ<br>Sea Bunyeur<br>012 926 357 | ចាន់ ដាវីង<br>Chan Daving<br>012 992 994 |
| **តាកែវ**<br>**Takeo** | កៅ សំភី<br>Kao Samphy<br>011 878 019 | ថាន កែវមុន្នី<br>Than Keomony<br>012 650 598 | ទុំ គីមលី<br>Tum Kimly<br>012 298 898 | ជា ហួត<br>Chea Huoth<br>016 738 588 |
| **កំពង់ចាម**<br>**Kg Cham** | លន់ ច័ន្ទរស្មី<br>Loun Chanraksmey<br>012 420 222 | វ៉ា វណ្ណា<br>Var Vanna<br>012 736 755 | ហេង រីវ៉ាន់<br>Heng Ryvann<br>012 553 562 | ប៉ាន់ មករា<br>Pan Makara<br>092 807 616 |
| **មណ្ឌលគិរី**<br>**Mondoulkiri** | ឡេក សុវណ្ណារ័ត្ន<br>Leg Sovannarath<br>016 620 666 | កែវ សុខុម<br>Keo Sokhom<br>012 976 314 | អ៊ី គង់<br>Y Koung<br>012 976 314 | ប៊ិន រតនា<br>Bin Rathana<br>012 970 339 |

| | | | |
|---|---|---|---|
| កំពង់ឆ្នាំង<br>Kg Chhnang | ម៉ម ម៉ាល័យ Mam Malay<br>016 3 01197 | អ៊ង ដារ៉ា Orng Dara<br>012 702 690 | ឈិត សាឃៀន Chheth Sakhean<br>016 891 791 |
| កំពង់ស្ពឺ<br>Kg Speu | ចក់ ថៃ Chak Thay<br>016 904 509 | សោម ល័ក្ខណ Som Leakhann<br>016 849 859 | ឡាយ សេរីវង្ស Lay Serey Vong<br>016 252 102 |
| ព្រៃវែង<br>Prey Veng | អ៊ុត បុណ្ណដារ៉ា Outh Pondara<br>012 989 803 | សុន ស៊ីម Son Sim<br>011 738 350 | ទេព សំអឿន Tep Sam Oeun<br>092 914 240 |
| ស្វាយរៀង<br>Svay Rieng | សុខ ភាព Sok SoPheap<br>016 742 957 | ហៃម បេលណាលី Haim Belnaly<br>012 977 611 | ឈូក បណ្ឌិត Chhouk Bandith<br>012 1914 739 |
| ក្រុងកែប<br>Kep | លៀង កា Leang Ka<br>012 974 692 | អ៊ុង ណាវុឌ្ឍ Ong Navuth<br>092 818 211 | សាំង ឃិម Saing Khim<br>012 477 895 |
| កំពត<br>Kampot | កែវ សុផាន់ Keo Sophan<br>012 868 767 | ហេង ចាន់ថា Heng Chantha<br>012 824 564 | |
| ក្រុងព្រះសីហនុ<br>Sihanoukville | ជួប វុត្ថា Chuob Vutha<br>012 885 875 | សែ ជូសិទ្ធិជោត Se Chousithichoth<br>012 794 896 | ស្រេង ហាក់ស្រួ Sreng Haksruor<br>012 878 401 |
| កោះកុង<br>Koh Kong | ជេត ជីវ៉ា Cheth Chiva<br>016 878 892 | កេត វុឌ្ឍី Keth Vuthy<br>011 895 822 | ខេង ដារ៉ាស៊ី Kheng Darasy<br>012 659 945 |
| ពោធិ៍សាត់<br>Pursat | ផាន់ ស៊ីណា Phan Sina<br>016 992 000 | ហេង សុមុន្នី Heng Somony<br>012 914 367 | សោ ហុង Sor Hong<br>012 931 302 |
| ក្រុងប៉ៃលិន<br>Pailin | យក់ សុវណ្ណ Yok Sovann<br>016 811 912 | តែង សារ៉ាត់ Teng Sarath<br>011 751 152 | ខឹម មុន្នីកុសល Khem Munikosal<br>012 769 097 |
| ស្ទឹងត្រែង<br>Stung Treng | មាស ថា Meas Tha<br>012 939 499 | មុត សែន Muth Sen<br>012 583 832 | សាយ ព្រលឹង Say Proloeung<br>012 961 703 |
| រតនគិរី<br>Ratanakiri | អ៊ុង រតនា Ong Ratana<br>012 962 480 | ហួយ វណ្ណារ៉ា Hoy Vanara<br>012 970 359 | គិម តោញព្រីង Kim Togn Pring<br>016 734 401 |
| កំពង់ធំ<br>Kg Thom | ទូច ផល្លា Tuoch Phalla<br>012 435 677 | លឹម សុមុនី Lim Somony<br>012 653 114 | សៀងលំអង្គុន្ធា Sieng LomAngkunthe a<br>012 718 300 |
| ព្រះវិហារ<br>Preah Vihea | ឡោ ឡាពិន Loa Lapyn<br>011 753 965 | នួន សុគន្ធា Noun Sokunthea<br>012 985 689 | យុនសោភ័ណដារ៉ា Yun Sophomdara<br>012 950 729 |
| សៀមរាប<br>Siem Reap | ម៉ៅ សំបូរ Mao Sambo<br>016 630 070 | ឃាង សុខទ្រី Kheang Soktry<br>012 630 007 | ប៊ូ សារិន Bou Sarenn<br>012 731 658 |
| ឧត្តរមានជ័យ<br>O. Meanchey | ខាំ សម្ផស្ស Kham Samphos<br>011 731 788 | ធុយ ធនិន Thuy Thonin<br>011 719 577 | សៀងលី វ៉ាន់ឌុល Seangly Vandol<br>011 900 177 |
| បន្ទាយមានជ័យ<br>B. Meanchey | កែវ សុភ័ក្ត្រា Keo Sophaktra<br>012 962 992 | សយ សម្ផស្ស Soy Sampho s<br>016 826 639 | ឡេ ច័ន្ទសង្វាត Le Chansanvat<br>012 948 779 |
| ក្រចេះ<br>Kratie | សាមុត លីម៉ា Samuth Lyma<br>012 917 592 | ញ៉ឹក ប៉ុច Ngek Poch<br>012 305 333 | ប៉ិច សីម៉ា Pech Seyma<br>012 973 726 |

# ចំណេះដឹងមូលដ្ឋាននៃជំងឺផ្តាសាយ

# The Basics of Influenza

## វីរុសជំងឺផ្តាសាយ

វីរុសគឺជាភ្នាក់ងារបង្ករោគដ៏តូចល្អិតមួយដែលអាចរស់នៅតែក្នុងកោសិកា ។

ជារួម វីរុសផ្សំឡើងដោយ២ផ្នែក ។ ផ្នែកខាងក្រៅគឺស្រោមការពារ ដែលកើតឡើងដោយជាតិប្រូតេអ៊ីន ។ ផ្នែកខាងក្នុងផ្សំឡើងដោយសារធាតុហ្សែន (genetic material) ជា RNA ឬ DNA ។

វីរុសគ្មានរចនាសម្ព័ន្ធផ្សេងទៀត ( ដែលហៅថា organelles) ដែលកោសិការស់ដទៃទៀតមានទេ ដូចជា nucleus ។ ដោយសារតែវីរុសគ្មាន organelles វាមិនអាចបន្តពូជដោយខ្លួនឯងបានឡើយ ។ ដើម្បីបន្តពូជ វីរុសឈ្លានពានកោសិការបស់ខ្លួនមនុស្ស ឬ សត្វ ដែលគេហៅថាអ្នកទទួល (host) ។ ប្រភេទនីមួយៗនៃវីរុសមានអ្នកទទួលដោយឡែកៗពីគ្នា ដែលវាអាចឈ្លានពានដោយជោគជ័យ ។

នៅពេលដែលស្ថិតនៅក្នុងកោសិកាអ្នកទទួល វីរុសបានប្រើប្រាស់កោសិការបស់ organelle នោះ ដើម្បីបង្កើតវីរុសជាច្រើនទៀត ។ វីរុសនោះបានជំរុញឱ្យកោសិកានោះបំបែកខ្លួនវាដោយខ្លួនឯង ។ នៅពេលដែលបានបំបែកខ្លួនហើយ វីរុសថ្មីក៏ចាកចេញពីកោសិកាអ្នកទទួល ហើយអាចធ្វើការឈ្លានពានកោសិកាដទៃទៀត ។



## Influenza virus

*A virus is an extremely tiny infectious agent that is only able to live inside a cell.*

Basically, viruses are composed of two parts. The outer part is a protective shell made of protein. The inner part is made of genetic material, either RNA or DNA.

A virus does not have any other structures (called organelles) that living cells have, like a nucleus. Because a virus lacks organelles, it cannot reproduce by itself. To reproduce, a virus invades a cell in the body of a human or animal, called the host. Each type of virus has particular host that it will invade successfully.

Once within the host cell, the virus uses the cell's organelles to produce more viruses. The virus forces the cell to replicate itself. Once replicated, the new viruses leave the host cell and are ready to invade other cells.

Source: www.ccc.gov - glossary

វីរុសឈ្លានពានកោសិកា ហើយបង្កឱ្យមានជំងឺ។ ជំងឺមួយចំនួនដែលបង្កដោយវីរុសមានដូចជា ជំងឺផ្តាសាយ អុតស្វាយ កញ្ជ្រឹល ក្រឡទែន ស្អូច អេដស៍ រលាកថ្លើម និងជំងឺ SARS ។
ជំងឺដែលបង្កដោយវីរុសមិនអាចព្យាបាលជាដោយថ្នាំអង់ទីប៊ីយោទិកទេ។ ការព្យាបាលគឺតាមប្រភេទជំងឺមួយៗ។

Viruses infect cells and cause disease. Common diseases caused by viruses include influenza, chicken-pox, measles, mumps, rubella, AIDS, hepatitis and SARS.
Viral infections can not be cured with antibiotics. Treatment is disease specific.

ផ្លូវចំលងសំខាន់ៗទាំង៤យ៉ាងនៃវីរុសគឺ:

១. ឈាម
២. ទឹករំអិលផ្លូវដង្ហើម
៣. កាកសំណល់របស់ពោះវៀន
៤. ទឹករំអិលផ្លូវបន្តពូជ

The 4 main modes of transmission of viruses are:

1. Blood
2. Respiratory secretions
3. Intestinal excretion (feces)
4. Secretions from reproductive tract

# ជំងឺផ្តាសាយធម្មតានៅលើមនុស្ស
# Seasonal influenza (influenza in humans - "the flu")

ចំពោះមនុស្ស ជំងឺផ្តាសាយគឺជាជំងឺឆ្លងនៃផ្លូវដង្ហើមផ្នែកខាងលើៈ ច្រមុះ បំពង់ក និងពេលខ្លះ សួត ដែលបណ្តាលមកពីការបង្ករោគរបស់វីរុសជំងឺផ្តាសាយ។ ជាធម្មតា ជំងឺនេះបាត់ទៅវិញក្នុងរយៈពេលប្រហែលមួយសប្តាហ៍។ មនុស្សភាគច្រើនជាសះស្បើយក្នុងរយៈពេល ១-២សប្តាហ៍ ដោយមិនចាំបាច់ប្រើថ្នាំព្យាបាលទេ។

In humans, influenza is a highly contagious illness of the upper respiratory tract - the nose, throat and sometimes the lungs - resulting from infection by an influenza virus. The illness usually lasts for about one week. Most people recover in 1-2 weeks without requiring any medical treatment.

## រោគសញ្ញា

រោគសញ្ញាជាទូទៅច្រើនកើតឡើងភ្លាមៗ ដែលរួមមានៈ

- គ្រុនក្តៅ/ញាក់
- ក្អកគ្មានស្លេស
- ឈឺក្បាល
- ហៀរសំបោរ
- ឈឺសាច់ដុំនិងសន្លាក់ឆ្អឹង
- ឈឺបំពង់ក
- ភាពល្ហិតល្ហៃទូទៅ

## Symptoms of seasonal influenza:

Symptoms are generally of sudden onset and include:

- Fever / chills
- Non-productive cough
- Headache
- Runny nose
- Sore throat
- General malaise
- Muscles and joint pain / body aches

## ការចំលង

វីរុសជំងឺផ្តាសាយងាយឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតណាស់ នៅពេលអ្នកជំងឺក្អក ឬ កណ្តាស់ ហើយបញ្ចេញវីរុសនោះទៅក្នុងខ្យល់ ។

វីរុសជំងឺផ្តាសាយចូលក្នុងខ្លួនមនុស្សតាមច្រមុះ ឬបំពង់ក ។ វាជាការកម្រដែលវីរុសជំងឺផ្តាសាយអាចមានឱកាសឆ្លងចូលទៅក្នុងខ្លួនមនុស្ស នៅពេលវីរុសនោះមានការប៉ះពាល់ជាមួយភ្នែក ។

យើងក៏អាចទទួលការឆ្លងវីរុសនេះ តាមរយៈការប៉ះពាល់ផ្ទៃវត្ថុដែលប្រឡាក់ដោយវីរុសនេះ ហើយបន្ទាប់មក ទៅប៉ះច្រមុះ មាត់ ឬភ្នែក ។

## Transmission

Influenza viruses are easily passed from person to person when an infected person coughs/sneezes and expels the virus into the air.

The influenza virus enters the body through the nose or throat. On rare occasions influenza can also enter the body when the virus come into contact with eyes.

It can also be transmitted through touching contaminated surfaces and then touching the nose, mouth or eyes.

## ការបង្ការជំងឺផ្តាសាយ

## Prevention of seasonal influenza



ខ្ទប់មាត់នៅពេលក្អក ឬកណ្តាស់
Cover your cough and sneeze

លាងសំអាតដៃឱ្យបានញឹកញាប់
Wash your hands thoroughly and often

ហាមខាកស្តោះ
Don't spit









ជំងឺភាគច្រើនដែលបង្កដោយវីរុស មានរយៈពេលសំងំ (រយៈពេលចាប់ពីបានឆ្លងវីរុសរហូតដល់ពេលចាប់ផ្ដើមមានរោគសញ្ញា)។ ជំងឺផ្ដាសាយរបស់មនុស្សមានរយៈពេលសំងំពី១-៥ថ្ងៃ។

ជំងឺផ្ដាសាយនៅលើមនុស្សងាយឆ្លងណាស់ ដែលមានន័យថា វាអាចឆ្លងរាលដាលយ៉ាងងាយពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ មនុស្សពេញវ័យអាចចំលងចាប់ពីមុនពេលមានរោគសញ្ញា រហូតដល់៤-៥ថ្ងៃក្រោយការចាប់មានរោគសញ្ញា។ ប៉ុន្តែកុមារទំនងជាមានរយៈពេលចំលងវែងជាងមនុស្សពេញវ័យ (ជាទូទៅ រហូតដល់៧ថ្ងៃ)។

Most viruses have an incubation period - the time between infection with a virus and the onset of symptoms. Seasonal influenza has an incubation period of one to five days.

Seasonal influenza is highly infectious which means it can spread easily from person to person. Adults are likely to be infectious from just before symptoms develop until four to five days after the onset of symptoms. Children, however, tend to be infectious for longer (typically up to seven days).

## ការព្យាបាលជំងឺផ្ដាសាយ

មានវិធីតិចតួចដើម្បីព្យាបាលជំងឺនេះ ប៉ុន្តែ ជាទូទៅត្រូវបង្កើនការសំរាក បង្កើនការហូបជាតិទឹក និងប្រើថ្នាំប៉ារ៉ាសេតាម៉ុល ដើម្បីជួយបញ្ចុះកំដៅ និងបន្ថយការឈឺចាប់។

មិនត្រូវប្រើថ្នាំអង់ទីប៊ីយោទិកដើម្បីព្យាបាលជំងឺផ្ដាសាយទេ គឺត្រូវព្យាបាលតាមរោគសញ្ញា។

ចំពោះកុមារ សូមអនុវត្តតាមសមាហរណកម្មនៃការទទួលបន្ទុកពិនិត្យនិងព្យាបាលជំងឺកុមារ (IMCI) សំរាប់ការគ្រុន ឬក្អក។

សូមឱ្យអ្នកជំងឺត្រឡប់មកវិញនៅ៣ថ្ងៃក្រោយ ប្រសិនបើគ្មានការធូរស្រាល។

បរិភោគផ្លែឈើ និងបន្លែស្រស់ ជាពិសេសផ្លែឈើនិងបន្លែដែលសំបូរវីតាមីនសេ។

## Treatment of seasonal influenza

There is little that one can do to treat, but generally, increased rest, increased fluid intake and use of paracetamol to help relieve fever and pain.

Do not prescribe antibiotics for the treatment of influenza, rather use symptomatic treatments.

For children, follow the IMCI guidelines for cough or cold.

Ask patients to come back after 3 days if there is no improvement.

Eat fresh fruit and vegetables, especially those rich in Vitamin C.



# ជំងឺផ្តាសាយបក្សី (ជំងឺផ្តាសាយនៅលើបក្សី)
# Avian influenza (influenza in birds - "bird flu")

ជំងឺផ្តាសាយបក្សី គឺជាជំងឺមួយដែលកើតលើសត្វបក្សី បន្ទាប់ពីសត្វបក្សីនោះបានទទួលការឆ្លងវីរុសជំងឺផ្តាសាយបក្សី ។

គ្រប់សត្វបក្សីទាំងអស់អាចឆ្លងវីរុសនេះ ហើយសត្វបក្សីជាច្រើនងាប់យ៉ាងលឿន ជាពិសេសសត្វបក្សីស្រុក ។

ជំងឺផ្តាសាយបក្សីអាចកើតឡើងភ្លាមៗនៅក្នុងតំបន់មួយដែលគ្មានជំងឺនេះពីមុនមកសោះ ព្រោះមានវិធីជាច្រើនដែលវីរុសរបស់ជំងឺនេះអាចឆ្លងរាលដាលពីតំបន់មួយទៅតំបន់មួយទៀត:

- សត្វបក្សីព្រៃធ្វើដំណើរយ៉ាងឆ្ងាយ ដែលធ្វើឱ្យគេគិតថាជាកត្តាចំលងជំងឺផ្តាសាយបក្សីនេះ ព្រោះសត្វទាំងនេះអាចជាអ្នកផ្ទុកវីរុសជំងឺផ្តាសាយបក្សីនេះ ហើយអាចចំលងទៅសត្វបក្សីស្រុកតាមរយៈការជួបគ្នា ។
- ការចល័តទីកន្លែងរបស់សត្វបក្សីស្រុកដែលមានជំងឺផ្តាសាយបក្សី បណ្តាលឱ្យមានការឆ្លងរាលដាលជំងឺនេះ ។
- ការចល័តចំណី ទ្រុង យានជំនិះ សំភារៈនិងមនុស្ស (ជាពិសេសតាមរយៈស្បែកជើង និងសំលៀកបំពាក់) ដែលប្រឡាក់ជាប់វីរុសជំងឺផ្តាសាយបក្សីអាចចំលងវីរុសជំងឺផ្តាសាយបក្សី ។

ជំងឺផ្តាសាយបក្សីគឺជា Zoonotic Disease ដែលមានន័យថាជាប្រភេទជំងឺមួយដែលអាចឆ្លងពីសត្វទៅមនុស្សបាន។ សព្វថ្ងៃនេះ ជំងឺនេះនៅ *តែជាជំងឺរបស់សត្វ* ។

Avian influenza is a disease that birds get when they are infected by the avian influenza virus.

All birds can be infected, and it is fatal to many birds, especially domestic poultry.

Avian influenza can suddenly appear in an area where it has not been seen before because there are many ways that the virus can spread from area to area:

- Wild birds travel over long distances which is thought to be a risk factor in spreading the disease, as they can "carry" the avian influenza virus and infect domestic birds when they meet.



- The movement of infected poultry spreads the virus.
- The movement of contaminated feed, cages, vehicles, equipment and people (including shoes and clothing), spreads the virus.

Avian influenza is a "zoonotic" disease, meaning a type of disease that can be passed from animal to human. Today it is still very much a bird disease.

# សត្វបក្សីគ្រប់ប្រភេទសុទ្ធតែអាចកើតជំងឺផ្តាសាយបក្សី
# Any birds can get the avian influenza virus



## ការចំលងវីរុសជំងឺផ្តាសាយបក្សីរវាងសត្វបក្សី

- ការប៉ះពាល់ផ្ទាល់ជាមួយសត្វបក្សីដែលមានជំងឺ
- ការដកដង្ហើមចូលនូវទឹករំអិលរាងកាយ (ទឹកមាត់ ទឹករំអិលច្រមុះ ឬកណ្តាស់ ទឹកភ្នែក ឈាម) និងលាមក
- សំភារៈបរិក្ខារ សំលៀកបំពាក់ ដៃ ចំណី ទឹក ផ្ទៃវត្ថុផ្សេងៗ និងទ្រុងដែលមានប្រឡាក់ជាប់វីរុស
- អាចតាមរយៈស៊ុត និងសំបកស៊ុត ។

វីរុសនេះអាចរស់នៅក្នុងលាមក និងនៅក្នុងសាកសពសត្វបក្សីដែលងាប់

## Transmission of the avian influenza virus between birds

- Direct contact with another infected bird
- Inhalation of body fluid (mouth liquid, nasal secretions or sneezes, eye fluid, blood) and feces
- Contaminated equipment, clothing, hands, feed, water, surfaces, cages
- Possibly through eggs and egg shells

The virus can live in feces and the carcass of dead poultry

**សត្វបក្សីដែលមានជំងឺផ្តាសាយបក្សីបញ្ចេញវីរុសផ្តាសាយបក្សីតាមទឹកមាត់ ទឹករំអិលច្រមុះ និងលាមក ។**

សត្វបក្សីក៏អាចឆ្លងជំងឺនេះ បើសិនជាពួកវាមកប៉ះជាមួយទ្រុង ឬផ្ទៃផ្សេងៗដែលបានប្រឡាក់ដោយសត្វបក្សីដែលមានជំងឺនេះ ។ ដូច្នេះហើយបានជាអ្នកស្រាវជ្រាវជាច្រើនគិតថា ទីផ្សារលក់សត្វបក្សីរស់ដែលមានផ្ទុកសត្វបក្សីរស់ជាច្រើននៅជិតៗគ្នា គឺជាកន្លែងដែលវីរុសជំងឺនេះអាចឆ្លងរាលដាលយ៉ាងលឿន ។

**Infected birds shed influenza virus in their saliva, nasal secretions, and feces.**



មាន់-ទាដែលឈឺអាចចំលងជំងឺទៅមាន់-ទាផ្សេងទៀត
A sick bird will make other birds sick

Birds can also get sick if they come into contact with cages or any surfaces that have been contaminated by sick birds. That's why researchers think live bird markets where birds are kept in close quarters are places where the virus has spread quickly.

## វីរុស H5N1

ជំងឺផ្តាសាយបក្សីបណ្តាលមកពីវីរុស influenza A ។ វីរុស influenza A មានប្រភេទតូចៗខុសៗគ្នាជាច្រើនប្រភេទ ។

ជំងឺផ្តាសាយបក្សីដែលបានផ្ទុះឡើងក្នុងពេលថ្មីៗនេះបណ្តាលមកពីវីរុសប្រភេទ H5N1 ដែលងាយឆ្លងរាលដាល និងគ្រោះថ្នាក់យ៉ាងខ្លាំងក្នុងចំណោមសត្វបក្សី ។

ជួនកាលគេហៅជំងឺផ្តាសាយបក្សីថា "Highly Pathogenic Avian Influenza (HPAI)" ។ Pathogenic មានន័យថា បណ្តាលឱ្យមានជំងឺធ្ងន់ធ្ងរ ។

Avian influenza is caused by influenza virus type A. There are many different subtypes of influenza virus type A. The current outbreak is caused by subtype **H5N1,** which is highly contagious among birds and often rapidly fatal.

Avian influenza is sometimes also referred to as 'Highly Pathogenic Avian Influenza **(HPAI)**'. Pathogenic means causing severe disease.



វីរុសជំងឺផ្តាសាយបក្សី A H5N1 ដែលបានបំពាក់ពណ៌ (មើលឃើញជាពណ៌មាស)

Colorized avian influenza A H5N1 viruses (seen in gold)
(Photo: CDC USA)

## សត្វបក្សីខ្លះជាអ្នកផ្ទុកមេរោគ

សត្វបក្សីខ្លះ ដូចជាបក្សីព្រៃ និងសត្វទា អាចផ្ទុកវីរុសជំងឺផ្តាសាយបក្សីនេះ ដោយមិនកើតជំងឺ ឬងាប់ឡើយ។ សត្វបក្សីខ្លះទៀត ជាពិសេសបក្សីស្រុក តែងតែមានជំងឺហើយងាប់។

- សត្វមាន់ស្ទើរតែទាំងអស់ ដែលឆ្លងមេរោគនេះ មានជំងឺ ហើយងាប់។
- សត្វទាខ្លះដែលបានឆ្លងមេរោគនេះ មានជំងឺដោយបង្ហាញរោគសញ្ញាដូចមាន់ដែរ។ សត្វទាខ្លះទៀត អាចជាអ្នកផ្ទុកវីរុសនេះ ដែលមានន័យថាសត្វទាទាំងនោះបានទទួលការឆ្លងមេរោគហើយ ប៉ុន្តែមិនបង្ហាញរោគសញ្ញានៃជំងឺឡើយ។

ទោះបីជាសត្វទាមិនឈឺ ឬងាប់ក៏ដោយ ក៏វានៅតែអាចចំលងវីរុសនេះទៅសត្វបក្សីដទៃទៀតបានដែរ

សត្វបក្សីដែលបានឆ្លងវីរុសនេះ អាចងាប់នៅពេលជាមួយគ្នានឹងពេលដែលវាចាប់ផ្តើមមានរោគសញ្ញា ឬអាចឈឺបន្តិចម្តងៗ និងងាប់ក្នុងរយៈពេល២-៣ថ្ងៃ។

## Some birds are carriers

Some birds, such as wild birds and ducks, can carry the avian influenza virus but do not get sick or die. Others, especially domestic poultry, get very sick and die.

- Almost all affected chickens get sick and die.
- Some infected ducks get sick with visible symptoms in the same way as chickens. Other ducks can be carriers - meaning they could be infected but do not show signs of sickness.

Even if the ducks do not get sick or die, they can still transmit the virus to other birds.

Affected birds can die on the same day when they first develop the symptoms, or could get sick slowly and die over a period of days.

## រយៈពេលសំងំ

រយៈពេលនៃការបង្កជំងឺ ដែលចាប់ពីពេលដែលមេរោគបានឆ្លងចូលទៅក្នុងខ្លួន រហូតដល់ពេលដែលចាប់ផ្តើមមានរោគសញ្ញាដំបូង។ ចំពោះសត្វបក្សី រយៈពេលសំងំ មានជាមធ្យមពី៣-២១ថ្ងៃបន្ទាប់ពីបានឆ្លងមេរោគ។ នេះមានន័យថា បន្ទាប់ពីបានឆ្លងមេរោគសត្វបក្សីអាចមើលទៅនៅមានសុខភាពល្អរយៈ៣-២១ថ្ងៃ ប៉ុន្តែសត្វបក្សីនោះនៅតែមានមេរោគនៅក្នុងខ្លួន ហើយនិងអាចចំលងមេរោគនោះទៅសត្វដទៃទៀតបាន។



## Incubation period

*The development of an infection from the time the pathogen enters the body until signs or symptoms first appear.*

On average the incubation time in poultry is 3-21 days after being infected. That means, a sick bird could look healthy for 3-21 days but still be infected and still pass on the virus.

## រោគសញ្ញានៃជំងឺផ្តាសាយបក្សីលើសត្វបក្សី

ជំងឺនេះច្រើនតែកើតឡើងភ្លាមៗ ហើយមានសត្វបក្សីជាច្រើនងាប់ក្នុងពេលជាមួយគ្នា (អត្រាងាប់ខ្ពស់)។

សត្វបក្សីអាចមិនបង្ហាញរោគសញ្ញាទេ - ជាញឹកញាប់វាគ្មានរោគសញ្ញាអ្វីទាំងអស់ ឬអាចមានរោគសញ្ញាមួយឬពីរ។

សត្វបក្សីដែលសំកុក (ងងុយដេក) ទន់ខ្សោយ និងដើរយឺតៗ អាចជាសត្វដែលមានជំងឺ។

រោគសញ្ញាដទៃទៀត រួមមាន:

- ការងាប់ភ្លាមៗដោយគ្មានរោគសញ្ញា
- ការហើមក្បាល ត្របកភ្នែក សិរមាន់ខាងលើ និងខាងក្រោម និងតន្លាក់ជើង
- មិនសូវដើរ
- ចំពោះមេមាន់វិញ អាចឈប់ផលិតពង
- សិរមាន់ខាងលើ និងខាងក្រោម និងជើង ប្រែទៅជាពណ៌ស្វាយ
- ហៀរសំបោរ
- សំបកស៊ុតទៅជាទន់ ឬខូចទ្រង់ទ្រាយ
- ការក្អក និងកណ្តាស់
- មានរាគ

## Symptoms of avian influenza in birds

The disease often appears suddenly and many poultry die at the same time (high mortality).

Birds may not show all the symptoms - often they do not have any, or only one or two.

Sleepy, weak and slow birds are probably sick.

Other symptoms may include:

- Sudden death without any signs
- Swelling of the head, eyelids, comb, wattles and hocks
- Lack of coordination
- Hens might stop laying eggs
- Purple discoloration of the wattles, combs and legs
- Nasai discharge
- Soft-shelled or misshapen eggs (they don't look right)
- Coughing, sneezing
- Diarrhea

កសិករតែងតែមានការលំបាកណាស់ក្នុងការនិយាយថា តើសត្វបក្សីរបស់គាត់បានឆ្លងវីរុសជំងឺផ្តាសាយបក្សីដែរឬទេ ដោយគ្មានការធ្វើតេស្តរកមេរោគ។ ប្រសិនបើមានសត្វមាន់ឈឺ ឬងាប់នៅក្នុងកសិដ្ឋានណាមួយ សូមរាយការណ៍ជាបន្ទាន់។

It is very hard for a farmer to tell if birds are infected with avian influenza without a test. If there are any sick or dead chickens in a farm, report immediately.



**រាយការណ៍ជាបន្ទាន់**
**Report Immediately**
មជ្ឈមណ្ឌលជាតិស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល
MAFF hotline **012 833 795   012 214 970**

# ជំងឺផ្តាសាយបក្សីលើមនុស្ស
## Avian influenza in humans

មនុស្សទីមួយដែលបានឆ្លងជំងឺផ្តាសាយបក្សីដែលបានកត់ត្រាក្នុងឯកសារ គឺបានកើតឡើងនៅក្នុងទីក្រុងហុងកុង ក្នុងឆ្នាំ១៩៩៧ នៅពេលដែលប្រភេទវីរុស H5N1 បានបណ្តាលអោយមានជំងឺផ្លូវដង្ហើមយ៉ាងធ្ងន់ធ្ងរនៅលើមនុស្សចំនួន១៨នាក់ ដែលក្នុងនោះមាន៦នាក់បានស្លាប់។ ការស៊ើបអង្កេតហ្មត់ចត់មួយទៅលើការផ្ទុះឡើងនៃជំងឺនោះ បានកំណត់ថាមេរោគនោះបានឆ្លងដោយផ្ទាល់ពីសត្វបក្សីទៅមនុស្ស នៅពេលដែលមនុស្សនោះបានប៉ះពាល់ជាមួយសត្វបក្សីដែលមានជំងឺនោះ។




The first documented infection of humans with an avian influenza virus occurred in Hong Kong in 1997, when the H5N1 strain caused severe respiratory disease in 18 humans, of whom 6 died. Extensive investigation of that outbreak determined that the virus had jumped directly from birds to humans, when the humans had close contact with infected birds.



ជាទូទៅ ឱកាសដែលមនុស្សអាចឆ្លងជំងឺផ្តាសាយបក្សីគឺមានកំរិតទាបចំពោះមនុស្សភាគច្រើន ពីព្រោះជាធម្មតា វីរុសនេះមិនឆ្លងទៅមនុស្សទេ។ ទោះបីយ៉ាងណាក្តី ការឆ្លងជំងឺផ្តាសាយបក្សីបានកើតឡើងលើមនុស្សរួចហើយ។

The risk of people becoming infected with avian influenza is generally low for most people, because the virus does not usually infect humans. However, infections of avian influenza have occurred in humans.

---

ភាគច្រើននៃករណីទាំងនេះ បានបណ្តាលមកពីមនុស្សមានទំនាក់ទំនងដោយផ្ទាល់ ឬជិតស្និទ្ធជាមួយសត្វបក្សីដែលមានជំងឺ ឬផ្ទៃវត្ថុដែលមានប្រឡាក់ជាប់វីរុសនៃជំងឺនេះ។

---

Most of these cases have resulted from people having close contact with infected poultry or contaminated surfaces.

---

ជាទូទៅ ជំងឺផ្តាសាយបក្សីនៅតែជាជំងឺដ៏កម្របស់មនុស្ស។

In general, avian influenza remains a very rare disease in people.

## ការចំលង

វីរុសផ្តាសាយបក្សីអាចឆ្លងតាមរយៈការប៉ះពាល់ជាមួយសត្វបក្សីដែលមានជំងឺ និង លាមក រោម ពោះវៀន និងឈាម និងអាចតាមរយៈស៊ុតដែរ ។

## Transmission

The avian influenza virus can be transmitted to humans through contact with infected poultry, and their droppings, feathers, intestines and blood, and maybe through eggs.



ជាញឹកញាប់ មេរោគទាំងនេះអាចប្រឡាក់ជាប់នៅដៃ ហើយអាចឆ្លងចូលទៅក្នុងខ្លួនមនុស្សតាមមាត់ ច្រមុះ ឬភ្នែក ។

The virus is often picked up on hands. It can easily be transferred to the mouth, nose or eyes, where it can enter the human body.





បច្ចុប្បន្ននេះវីរុសនេះមិនងាយឆ្លងពីមនុស្សទៅមនុស្សទេ ។
Currently it is not easy for the virus to spread from person to person.

## រោគសញ្ញានៃជំងឺផ្តាសាយបក្សីនៅលើមនុស្ស

រោគសញ្ញានៃជំងឺផ្តាសាយបក្សីលើមនុស្ស គឺប្រហាក់ប្រហែលនឹងជំងឺផ្តាសាយធម្មតាដែរ:

- គ្រុនក្តៅ (លើសពី៣៨អង្សា)
- ក្អក និងឈឺបំពង់ក
- ឈឺក្បាល
- ឈឺសាច់ដុំ

ប៉ុន្តែជំងឺផ្តាសាយបក្សី ក៏អាចនាំអោយមានបញ្ហានៅភ្នែក ជំងឺរលាកសួតធ្ងន់ធ្ងរ ការក្អកធ្ងន់ធ្ងរ និងការពិបាកដកដង្ហើម ។

អ្នកដែលបានឆ្លងជំងឺនេះអាចស្លាប់ដោយសារផលវិបាករបស់វា ។ ចំនួនប្រហែលពាក់កណ្តាលនៃអ្នកដែលបានឆ្លងវីរុសនេះនៅទូទាំងពិភពលោកបានស្លាប់ ។

## The symptoms of avian influenza in humans

Symptoms are similar to seasonal human influenza:

- High fever (above 38 degrees)
- Cough and sore throat
- Headache
- Muscle aches

But avian influenza can also lead to eye infections, severe pneumonia, severe coughing and breathing problems.

The infected person can die from complications. In fact, approximately half of the people throughout the world who have been infected with avian influenza have died.

កុមារហាក់ដូចជាងាយឆ្លងជំងឺផ្តាសាយបក្សី ដែលប្រហែលជាបណ្តាលមកពីប្រព័ន្ធការពាររាងកាយរបស់កុមារនៅខ្ចី និង បណ្តាលមកពីកុមារមានការប្រឈមមុខខ្ពស់ តាមរយៈការលេងជាមួយសត្វបក្សីដែលឈឺ ឬងាប់ ។



ម្យ៉ាងទៀត កុមារមានចំណេះដឹងទាបអំពីអនាម័យ និងការលាងសំអាតដៃ ហើយច្រើនតែដាក់ដៃកខ្វក់ទៅក្នុងមាត់របស់វា

Children seem more susceptible to contracting avian influenza, possibly because of the immaturity of their immune systems, and possibly because of high exposure through playing with sick or dead birds.

Furthermore, children often have limited awareness for hygiene and washing hands, and a tendency to put dirty hands into their mouths.

ចំពោះមនុស្សដែលមានរោគសញ្ញាសង្ស័យថាមានជំងឺផ្តាសាយបក្សី សូមទាក់ទងក្រសួងសុខាភិបាលភ្លាម ។

For suspected symptoms of avian influenza in people, please contact the MoH immediately.



**រាយការណ៍ជាបន្ទាន់**
**Report Immediately**

សូមអ្នកទាក់ទងមកក្រសួងសុខាភិបាល

MOH hotline 012 488 981 012 836 868

# ជំងឺផ្តាសាយដែលផ្ទុះឡើងរាតត្បាតជាសកល
# Pandemic influenza

ជំងឺផ្តាសាយដែលផ្ទុះឡើងរាតត្បាតជាសកល គឺជាប្រភេទជំងឺផ្តាសាយថ្មីមួយដែលឆ្លងរាលដាលយ៉ាងឆាប់រហ័សនៅទូទាំងពិភពលោក ។

Pandemic influenza is a new type of influenza that spreads rapidly around the world.

---

ជំងឺផ្តាសាយដែលផ្ទុះឡើងរាតត្បាតជាសកល មានសភាពធ្ងន់ធ្ងរជាងជំងឺផ្តាសាយធម្មតា ពីព្រោះវីរុសជំងឺផ្តាសាយនេះជាវីរុសថ្មី ហើយគ្មាននរណាម្នាក់មានប្រព័ន្ធការពាររាងកាយប្រឆាំងនឹងវីរុសនេះទេ ។ រោគសញ្ញារបស់វាអាចធ្ងន់ធ្ងរ ហើយអាចមានមនុស្សជាច្រើនកើតជំងឺនេះ ។

Pandemic influenza is more serious than seasonal influenza because the virus is new and no one has any immunity to the virus. The symptoms may be more severe and more people may be infected.

---

## និយមន័យនៃការផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកល

ការឆ្លងរាលដាលជំងឺផ្តាសាយលើមនុស្សបានកើតឡើងរៀងរាល់ឆ្នាំនៅទូទាំងពិភពលោក ។ Epidemic គឺជាការកើនឡើងយ៉ាងឆាប់នៃជំងឺមួយ នៅក្នុងសហគមន៍មួយ ក្នុងចំណោមមនុស្សជាច្រើន ឬក្នុងតំបន់ណាមួយនៅរយៈពេលយ៉ាងខ្លី ។ ម្យ៉ាងទៀត Pandemic គឺជាការឆ្លងរាលដាលនៅទូទាំងពិភពលោក ដោយមានការប៉ះពាល់លើមនុស្សជាច្រើនរយពាន់នាក់ នៅប្រទេសជាច្រើន ។

ពាក្យ *ផែនដេមិក* (Pandemic) កើតមកពីពាក្យក្រិក *ផែន* (Pan) ដែលមានន័យថា "ទាំងអស់" និង *ដេមូស* (Demos) ដែលមានន័យថា "មនុស្ស "។ ជំងឺដទៃទៀតដែលមានអាត្រាឆ្លងរាលដាលលើមនុស្សជាច្រើន រួមមានជំងឺអេដស៍ និងជំងឺរបេង ។

## Definition of pandemic

Epidemics of seasonal human flu occur every year around the world. An epidemic is a dramatic increase of a disease in a single community, population or region in a short period of time. A pandemic, on the other hand, spreads around the world affecting many hundreds of thousands of people across many countries.

The word pandemic comes from the Greek words pan, meaning 'all,' and demos, meaning 'people.' Other diseases of pandemic proportions include HIV/AIDS and tuberculosis.

## ប្រវត្តិជំងឺផ្តាសាយដែលផ្ទុះឡើងរាតត្បាតជាសកល

**ការផ្ទុះជំងឺផ្តាសាយអេស្ប៉ាញរាតត្បាតជាសកល** (Spanish Flu Pandemic) **ក្នុងឆ្នាំ១៩១៨-១៩១៩**

វីរុសនោះ គឺជាប្រភេទវីរុសជំងឺផ្តាសាយ H1N1 ដែលបានកើតចេញពីវីរុសរបស់ជំងឺផ្តាសាយបក្សី។ វីរុសជំងឺផ្តាសាយបក្សីបានបំលែងមួយរយៈពេលដើម្បីអាចមានលទ្ធភាពចំលងយ៉ាងខ្លាំងក្លាពីមនុស្សទៅមនុស្ស។ វីរុស H1N1 បានបណ្តាលអោយមានមនុស្សស្លាប់ប្រមាណ៤០លាននាក់នៅទូទាំងពិភពលោក។

**ជំងឺផ្តាសាយអាស៊ី** (Asian Flu) **ក្នុងឆ្នាំ១៩៥៧-១៩៥៨**

ការផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកលនៅឆ្នាំ១៩៥៧នេះ បណ្តាលមកពីវីរុស H2N2។ វីរុសនេះត្រូវបានកើតឡើង នៅពេលដែលវីរុសជំងឺផ្តាសាយបក្សីផ្សំគ្នាជាមួយវីរុសជំងឺផ្តាសាយមនុស្ស កើតបានជាប្រភេទជំងឺផ្តាសាយថ្មីមួយ ដែលបានឆ្លងរាលដាលនៅទូទាំងពិភពលោកចាប់ពីឆ្នាំ១៩៥៧រហូតដល់ឆ្នាំ១៩៥៨។ ការប៉ាន់ប្រមាណអំពីចំនួននៃការស្លាប់ មានលក្ខណៈខុសគ្នាយ៉ាងខ្លាំង ពីមួយលានដល់បួនលាននាក់។

**ជំងឺផ្តាសាយហុងកុង** (Hong Kong Flu) **ក្នុងឆ្នាំ១៩៦៨-១៩៦៩**

ការផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកលនៃប្រភេទវីរុស H3N2 ត្រូវបានបង្កើតឡើងដោយការផ្សំគ្នារវាងវីរុសជំងឺផ្តាសាយបក្សីនិងវីរុសជំងឺផ្តាសាយមនុស្ស។ ជាលទ្ធផល វីរុសនេះបានឆ្លងរាលដាលនៅទូទាំងពិភពលោក ហើយបានសំលាប់មនុស្សរហូតដល់ចំនួនមួយលាននាក់។

## History of influenza pandemics

*Pandemics of influenza have occurred three times in the last hundred years - resulting in many deaths in many different countries.*

**The Spanish Flu Pandemic, 1918-1919**

The virus was a H1N1 influenza strain which emerged from an avian influenza virus. The avian influenza virus adapted over time to be able to transmit efficiently from human to human. The H1N1 virus was particularly deadly and caused approximately 40 million deaths worldwide.

**The Asian Flu, 1957-1958**

The pandemic of 1957 was caused by an H2N2 virus. It was created when an avian influenza virus mixed with a human influenza virus, to create a new type of influenza, which spread worldwide from 1957 lasting until 1958. Estimates of worldwide mortality numbers vary widely, ranging from one million to four million people.

**The Hong Kong Flu, 1968-1969**

The Hong Kong pandemic strain of H3N2 was created by an avian and a human influenza strain mixing together. The resulting virus spread throughout the world and killed up to one million people.

| ជំងឺផ្តាសាយធម្មតានៅលើមនុស្ស | ជំងឺផ្តាសាយដែលផ្ទុះឡើងរាតត្បាតជាសកល |
|---|---|
| • កើតឡើងជារៀងរាល់ឆ្នាំ | • មិនកើតឡើងញឹកញាប់ទេ កើតឡើងតែបីដងប៉ុណ្ណោះក្នុងរយៈពេល១០០ឆ្នាំ ចុងក្រោយនេះ |
| • អ្នកដែលបានកើតជំងឺផ្តាសាយធម្មតាពីមុនមក បានបង្កើតភាពស៊ាំប្រឆាំងនឹងជំងឺនេះ | • គ្មានការបង្កើតឱ្យមានភាពស៊ាំទេ — ព្រោះវាជាវីរុសថ្មី |
| • អ្នកជំងឺភាគច្រើនមានការធូរស្រាលក្នុងរយៈពេល១ ឬ២សប្តាហ៍ដោយមិនត្រូវការការព្យាបាលដោយថ្នាំទេ | • អ្នកជំងឺខ្លះគ្មានការធូរស្រាលទេ សូម្បីតែមានការព្យាបាលដោយថ្នាំក៏ដោយ |
| • កុមារតូចៗ ចាស់ជរា និងអ្នកដែលមានជំងឺរ៉ាំរ៉ៃ មានការប្រឈមមុខនឹងការមានជំងឺនេះធ្ងន់ធ្ងរ | • មនុស្សគ្រប់វ័យទាំងអស់សុទ្ធតែអាចប្រឈមមុខនឹងការមានជំងឺនេះដ៏ធ្ងន់ធ្ងរ |

| Seasonal influenza | Pandemic Influenza |
|---|---|
| • Occurs every year | • Occurs infrequently, there were only three influenza pandemics in the last 100 years |
| • People build up immunity to influenza that they have been infected with in the past | • There is no immunity – it is a new virus |
| • Most people recover in one or two weeks without requiring medical treatment | • Some people will not recover even with medical treatment |
| • The very young, the very old and the very sick are most at risk of serious illness | • People of every age may be at risk of serious illness |



មន្ទីរពេទ្យសង្គ្រោះបន្ទាន់មួយនៅសហរដ្ឋអាមេរិកក្នុងពេលមានការផ្ទុះជំងឺផ្តាសាយឆ្លងរាតត្បាតជាសកលក្នុងឆ្នាំ១៩១៨

An emergency hospital in USA during the 1918 influenza pandemic
(Photo: The National Musuem of Health and Medicine, Washington DC)



កុមារកំពុងខ្ពុរមាត់នៅមន្ទីរពេទ្យ Sagamihara Hospital ប្រទេសជប៉ុន ពេលផ្ទុះជំងឺផ្តាសាយឆ្លងរាតត្បាតជាសកលក្នុងឆ្នាំ១៩៥៧

Child gargling, Sagamihara Hospital, Japan, 1957 influenza pandemic
(Photo: The National Musuem of Health and Medicine, Washington DC)

## ជំងឺផ្តាសាយបក្សី - ការព្រួយបារម្ភ

ក្នុងពេលបច្ចុប្បន្ននេះ ប្រសិនបើមនុស្សណាម្នាក់បានឆ្លងជំងឺផ្តាសាយបក្សី មនុស្សនោះមិនអាចចំលងវីរុសជំងឺនេះដោយផ្ទាល់ទៅមនុស្សដទៃទៀតបានឡើយ ។

ប៉ុន្តែ វីរុសជំងឺផ្តាសាយធ្វើការបំលែងរចនាសម្ព័ន្ធរបស់វាជាប្រចាំ ។ **ការព្រួយបារម្ភរបស់យើងនោះគឺថា វីរុសនេះនឹងអាចបំលែងទៅជាវីរុសប្រភេទថ្មីមួយដែលអាចងាយឆ្លងទៅមនុស្សបាន ។** នេះមានន័យថា វីរុសនេះអាចធ្វើឱ្យមនុស្សជាច្រើនកើតជំងឺយ៉ាងលឿន និងបណ្តាលឱ្យមានការឆ្លងរាតត្បាលទូទាំងពិភពលោក ។

អ្នកវិទ្យាសាស្ត្រជាច្រើនកំពុងធ្វើការពិនិត្យតាមដានវីរុសនេះយ៉ាងជិតស្និទ្ធ ដើម្បីពិនិត្យមើលថាតើវាអាចបំលែងទៅជាវីរុសមួយដែលអាចឆ្លងពីមនុស្សទៅមនុស្សបានដែរឬទេ ។

**នៅក្នុងដំណាក់កាលនេះ ការដែលសំខាន់នោះគឺត្រូវបញ្ឈប់ការឆ្លងវីរុសជំងឺផ្តាសាយបក្សីក្នុងចំណោមសត្វបក្សី និងដើម្បីបន្ថយឱកាសដែលវីរុសអាចចំលងទៅមនុស្ស ។**

## Avian influenza - the concerns

With the current influenza virus is now, if a person becomes infected, that person can not directly infect another person.

But the influenza virus regularly changes its structure. **The worry is that it will change into a new type of virus that can find a way to easily infect people.** It means it could make many people sick very fast and cause a world wide epidemic ('pandemic') of influenza.

Scientists are closely monitoring the virus to see if it will change into a virus that can be spread from human to human.



Photograph: WHO

**At this stage, the important thing is to stop the transmission of avian influenza in poultry - and so decrease the risk of it finding a way to infect humans.**

ជំងឺផ្ដាសាយដែលផ្ទុះឡើងរាតត្បាតជាសកល អាចមានរោគសញ្ញាប្រហាក់ប្រហែលនឹងរោគសញ្ញាជំងឺផ្ដាសាយធម្មតាដែរ ។

ការផ្ទុះជំងឺផ្ដាសាយរាតត្បាតជាសកលដែលធ្ងន់ធ្ងរ អាចបណ្ដាលឱ្យមានមនុស្សជាច្រើនស្លាប់ បន្ទុចបង្អាក់ជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សជាច្រើន និងបណ្ដាលឱ្យមានសំពាធយ៉ាងធ្ងន់ធ្ងរទៅលើសេវាសុខភាព និងសេវាដទៃទៀត ។

Pandemic influenza is likely to have the same symptoms as seasonal human influenza.

A serious pandemic may cause many deaths, disrupt the daily life of many people and cause intense pressure on health and other services.

## វិធីដែលវីរុសជំងឺផ្ដាសាយធ្វើការបំលែងខ្លួន: drift និង shift

មានយន្តការពីរយ៉ាងដែលវីរុសធ្វើការបំលែងខ្លួនរបស់វា - antigenic drift និង antigenic shift

Antigenic drift – ការខុសគ្នាបន្តិចបន្តួចរបស់វីរុស តាមលក្ខណៈធម្មជាតិ និងដែលមិនអាចទាយមុនបាន ដែលកើតឡើងជាបន្តបន្ទាប់ក្នុងមួយរយៈពេល ។ នៅពេលវីរុសបំលែងខ្លួនវា វាធ្វើឱ្យមានការបំបែកខ្លួនរបស់វាមានភាពខុសប្លែកគ្នាបន្តិចបន្តួច ដូច្នេះវីរុសដែលបានមកពីការបំបែកខ្លួនតែងតែមានសភាពខុសគ្នាបន្តិចបន្តួចពីវីរុសដើម ។

ដូច្នេះ ហើយបានជាពីមួយឆ្នាំទៅមួយឆ្នាំ តែងតែមានវីរុសជំងឺផ្ដាសាយដែលខុសគ្នាបន្តិចបន្តួចឆ្លងរាលដាលពីមនុស្សទៅមនុស្ស ។ នេះគឺជាហេតុផលសំខាន់មួយដែលបង្ហាញអំពីមូលហេតុដែលមនុស្សយើងអាចកើតជំងឺផ្ដាសាយ លើសពីមួយដងក្នុងមួយជីវិត និងមូលហេតុដែលវ៉ាក់សាំងបង្ការជំងឺផ្ដាសាយត្រូវបានបង្កើតឡើងជារៀងរាល់ឆ្នាំ ដែលមានន័យថាវ៉ាក់សាំងបង្ការជំងឺផ្ដាសាយឆ្នាំនេះ នឹងអាចគ្មានប្រសិទ្ធភាពសំរាប់បង្ការជំងឺផ្ដាសាយនៅឆ្នាំក្រោយ ។

*Antigenic shift ឬអាចហៅថា viral shift – គឺជាដំណើរការនៃការបំលែងយ៉ាងខ្លាំងដើម្បីបង្កើតបានជាវីរុសអនុក្រុមថ្មីមួយទៀត ។*

## How influenza viruses change: drift and shift

There are two mechanisms by which viruses change - antigenic drift and shift.

***Antigenic drift*** - Small, natural and unpredictable changes in the virus that happen continually over time. As these viruses change, they make small errors in their duplication so the duplicated virus is always slightly different from the one before. Therefore, from year to year, slightly different influenza viruses spread from human to human. This is one of the main reasons why people can get the flu more than one time in their life and why the vaccination for ordinary influenza is especially created each year, ie the vaccination for influenza this season may not work for influenza in the next season.

***Antigenic shift*** *refers to an abrupt, major change to produce a new influenza virus subtype.*

## ការបំលែងរបស់វីរុសជំងឺផ្តាសាយប៉ះពាល់ដល់ប្រព័ន្ធការពាររាងកាយរបស់មនុស្សយើង

ការបំលែងជាទូទៅ កើតមានឡើងជាបន្តបន្ទាប់ ចំពោះវីរុសជំងឺផ្តាសាយគ្រប់ប្រភេទ ក្នុងរយៈពេលមួយ ។ ការបំលែងនេះប៉ះពាល់ដល់ប្រព័ន្ធការពាររាងកាយរបស់យើង ពីព្រោះ ប្រព័ន្ធការពាររបស់យើងដែលមាន អាចមិនស្គាល់វីរុសប្រភេទថ្មី ។

## Changes in the influenza virus affect our immunity (Antigenic drift)

Natural changes occur in all types of influenza viruses, continually over time, making slightly different viruses, or strains. Our immune system develops antibodies to match each strain we are infected with. New virus strains are usually not recognized by antibodies to earlier influenza strains.




**ឆ្នាំទី១ :** មនុស្សដែលឆ្លងវីរុសជំងឺផ្តាសាយមួយប្រភេទ (ពណ៌ខៀវខ្ចី) ហើយបង្កើតឱ្យមានប្រព័ន្ធការពាររាងកាយប្រឆាំងនឹងវីរុសប្រភេទនោះតែប៉ុណ្ណោះ ។

**ឆ្នាំទី២ :** នៅក្នុងពេលបន្ទាប់មកវីរុសជំងឺផ្តាសាយមួយប្រភេទទៀតអាចកើតឡើង (ពណ៌ខៀវ) ។
មនុស្សនេះនៅមានប្រព័ន្ធការពាររាងកាយប្រឆាំង នឹងវីរុសប្រភេទពណ៌ខៀវខ្ចី ហើយនឹងមិនមានជំងឺផ្តាសាយដោយសារវីរុសប្រភេទនេះទៀតទេ ប្រសិនបើគាត់បានឆ្លង វីរុសជំងឺផ្តាសាយប្រភេទពណ៌ខៀវខ្ចីទៀត ។
ប៉ុន្តែគាត់អាចមានជំងឺផ្តាសាយ នៅពេលបានឆ្លងវីរុសជំងឺផ្តាសាយប្រភេទពណ៌ខៀវ ។ បន្ទាប់មកគាត់នឹងមានប្រព័ន្ធការពាររាងកាយប្រឆាំងនឹង វីរុសជំងឺផ្តាសាយប្រភេទពណ៌ខៀវនេះ ។

**ឆ្នាំទី៣ :** នៅឆ្នាំបន្ទាប់មកទៀត គាត់គ្មានប្រព័ន្ធការពារប្រឆាំងនឹងវីរុសថ្មីនេះទេ (ពណ៌ក្រហម) ប៉ុន្តែគាត់នៅមានប្រព័ន្ធការពារប្រឆាំងនឹងប្រភេទវីរុសពណ៌ខៀវខ្ចី និងពណ៌ខៀវដែលគាត់បានឆ្លងពីមុនមក ។

**Year 1 :** Person infected with a strain of influenza - "light blue" - and develops immunity to this strain only.

**Year 2 :** In the next season, a new strain appears (dark blue). The person keeps his immunity to the light blue strain and does not get sick if infected with the light blue strain. But he can get sick when infected with the "dark blue" strain. After infection, he is able to develop immunity, against the dark blue strain.

**Year 3 :** In the next season, he has no immunity to the new strain (red), but keeps immunity to the dark blue and light blue strains that have previously infected him.

# ការបំលែងនៃវីរុសជំងឺផ្ដាសាយអាចបង្កើតឱ្យមានវីរុសមួយថ្មីដែលមនុស្សយើងគ្មានប្រព័ន្ធការពាររាងកាយដើម្បីប្រឆាំង

**Antigenic shift ឬអាចហៅថា viral shift**

គឺជាដំណើរការនៃការបំលែងយ៉ាងខ្លាំងនៅក្នុងរចនាសម្ព័ន្ធរបស់វីរុសជំងឺផ្ដាសាយ ។

"Reassortment" គឺជាដំណើរការនៃ antigenic shift ដែលវីរុសជំងឺផ្ដាសាយ២ប្រភេទ រួមបញ្ចូលគ្នាបង្កើតបានជាកូនប្រភេទមួយទៀតដែលមានផ្ទៃ antigens នៃប្រភេទដើមទាំងពីររួមគ្នា ។

- មិនកើតឡើងញឹកញាប់ទេ
- បង្កើតបានជាវីរុសជំងឺផ្ដាសាយកូនប្រភេទមួយថ្មី

# Changes in the influenza virus can create a new virus to which people have no immunity

***Antigenic shift, also called viral shift***

*The process by which there is major change in the structure of the influenza virus.*

"Reassortment" is a type of antigenic shift where two different strains of influenza combine to form a new subtype having a mixture of the surface antigens of the two original strains.

- Happens only occasionally.
- Results in a new influenza subtype.

**ឧទាហរណ៍នៃអ្វីដែលអាចកើតឡើង ដើម្បីបង្កើតឱ្យមានការផ្ទុះជំងឺផ្ដាសាយរាតត្បាតជាសកល**

**An example of what could happen to create a pandemic influenza**




មាន់ ឬទាដែលមានវីរុសជំងឺផ្ដាសាយបក្សី

Birds with avian influenza virus.

មនុស្សដែលបានឆ្លងវីរុសជំងឺផ្ដាសាយមនុស្ស និងវីរុសជំងឺផ្ដាសាយបក្សី

Person infected with human influenza virus and avian influenza virus. Viruses may combine to form a new virus.

វីរុសថ្មី - អាចឆ្លងយ៉ាងឆាប់រហ័សពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។ អាចនាំឱ្យមានការរាតត្បាតជាសកល ។

New virus - highly infectious and spreads from person to person.
Could lead to global pandemic.

## ប្រភពនៃមេរោគផ្តាសាយដែលផ្ទុះឡើងរាតត្បាតជាសកលក្នុងពេលអតីតកាល

## The origins of pandemic influenza viruses in the past




- បច្ចុប្បន្ននេះគ្មានការផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកលទេ ។
- គេមិនបានដឹងថាតើពេលណានឹងអាចមានផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកលទេ ។
- ប្រការដែលសំខាន់ក្នុងពេលនេះគឺត្រូវបង្ការការចំលងវីរុសដើម្បីកាត់បន្ថយការគំរាមកំហែងនៃការរាតត្បាតជាសកល ។

- Currently there is no pandemic.
- It is not known when another pandemic will occur.
- The important thing now is to prevent the transmission of H5N1 to reduce the threat of a pandemic.

**Source: Robert B. Belshe, M.D. The New England Journal of Medicine** http://content.nejm.org/cgi/content/full/353/21/2209

# ការកាត់បន្ថយការប្រឈមមុខនឹងការផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកលៈ

## To reduce the risk of an influenza pandemic

### គ្រប់គ្រងជំងឺនេះក្នុងចំណោមសត្វនានា

**Control avian influenza in animals**



### បង្ការការប្រឈមមុខរបស់មនុស្សទៅនឹងវីរុសជំងឺផ្តាសាយបក្សី

**Prevent exposure of people to the avian influenza virus**






Photo: MAFF

# ស្ថានភាពបច្ចុប្បន្ននៃជំងឺផ្ដាសាយបក្សី នៅក្នុងប្រទេសកម្ពុជា

## Current Situation of Avian Influenza in Cambodia

**ការផ្ទុះឡើងលើកដំបូងនៃជំងឺផ្ដាសាយបក្សីលើសត្វបក្សីនៅក្នុងប្រទេសកម្ពុជា ត្រូវបានរកឃើញនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៤ ដោយបានបណ្ដាលឱ្យសត្វបក្សីជាច្រើនពាន់ក្បាលងាប់។**

ការស្លាប់នៃសត្វបក្សីទាំងនេះ បណ្ដាលឱ្យមានការខាតបង់ផ្នែកសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរដល់កសិករ - ទាំងកសិករដែលមានកសិដ្ឋានចិញ្ចឹមមាន់-ទាតាមផ្ទះ និងអ្នកដែលមានកសិដ្ឋានចិញ្ចឹមមាន់-ទាបែបពាក់កណ្ដាលអាជីវកម្ម។ គ្រប់អ្នកចិញ្ចឹមមាន់-ទាទាំងអស់សុទ្ធតែប្រឈមមុខនឹងការខាតបង់ផ្នែកសេដ្ឋកិច្ច ប្រសិនបើមាន់-ទារបស់គាត់ឈឺ និងងាប់។

**The first outbreak in poultry in Cambodia was identified on 23 January 2004 causing the death of thousands of heads of poultry.**

The death of poultry causes dramatic economic loss for the farmers, both backyard and semi-commercial farms. Anyone involved in raising poultry risks this type of economic loss if their poultry get sick and die.

## ការផ្ទុះជំងឺផ្ដាសាយបក្សីលើសត្វមាន់_ទានៅក្នុងប្រទេសកម្ពុជា

## Avian influenza outbreaks in poultry in Cambodia



| | |
|---|---|
| រាជធានីភ្នំពេញ | Phnom Penh |
| ខេត្តតាកែវ | Takeo |
| ខេត្តកណ្ដាល | Kandal |
| ខេត្តសៀមរាប | Siem Reap |
| ខេត្តកំពង់ចាម | Kampong Cham |
| ខេត្តកំពត | Kampot |
| ខេត្តព្រៃវែង | Prey Veng |

## ការឆ្លើយតបរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## MAFF's response

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការគ្រប់គ្រងឆ្លើយតបជាបន្ទាន់ដល់ការផ្ទុះឡើងនៃជំងឺផ្តាសាយបក្សីនេះតាមរយៈការស៊ើបអង្កេតលើការផ្ទុះឡើងនៃជំងឺនេះ ការសំលាប់សត្វមាន់-ទាមួយចំនួន ការបាញ់ថ្នាំសំលាប់មេរោគ ការប្រមូលវត្ថុវិភាគ និងការអង្កេតឃ្លាំមើលហ្វូងសត្វមាន់-ទា ផ្សេងៗទៀតដែលនៅជុំវិញកន្លែងផ្ទុះជំងឺ។

ឧបករណ៍សំភារៈការពារនិងការការពារ ដូចជាការបំផ្លាញចោលសត្វមាន់-ទាមួយចំនួនដែលកើតជំងឺ និងការបាញ់ថ្នាំសំលាប់មេរោគ ត្រូវបានផ្តល់ឱ្យពេទ្យសត្វស្រុកនិងខេត្ត និងភ្នាក់ងារសុខភាពសត្វភូមិនៅក្នុងកម្មវិធីបណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិ ដែលរៀបចំឡើងដោយអង្គការ FAO និងក្រសួងកសិកម្ម។

The Ministry of Agriculture, Forestry and Fisheries (MAFF) responded by emergency control to the outbreaks through outbreak investigation, selective culling, disinfection, sampling and surveillance of surrounding flocks.

Protective gear and equipment, such as disposal of affected poultry and disinfectant, have been provided to Provincial and District Vets and Village Animal Health Workers in the training program for Village Animal Health Workers which is organized by FAO and Ministry of Agriculture.



ការថ្នាំបាញ់សំលាប់មេរោគបន្ទាប់ពីមានការផ្ទុះឡើងនៃជំងឺផ្តាសាយបក្សីលើសត្វបក្សី Photo:MAFF
Disinfection after an outbreak of avian influenza in poultry

## ករណីមនុស្សដែលមានជំងឺផ្តាសាយបក្សីនៅក្នុងប្រទេសកម្ពុជា

នៅក្នុងខែមករា ឆ្នាំ២០០៥ ប្រទេសកម្ពុជាមានរបាយការណ៍អំពីករណីមនុស្សកើតជំងឺផ្តាសាយបក្សីលើកដំបូង ហើយចាប់តាំងពីពេលនោះមកមានមនុស្សចំនួន៦នាក់បានស្លាប់។

ក្នុងចំណោមករណីទាំងនេះ ភាគច្រើនបានបណ្តាលមកពីមនុស្សនោះ មានទំនាក់ទំនងដោយផ្ទាល់ ឬជិតស្និទ្ធជាមួយមាន់-ទាដែលកើតជំងឺ ឬផ្ទៃវត្ថុផ្សេងៗដែលប្រឡាក់ជាវីរុសជំងឺនេះ។

## Human cases in Cambodia

In January 2005, Cambodia reported the first human case of avian influenza, and since that time six people have died.

Most of these cases have resulted from people having direct or close contact with infected poultry or contaminated surfaces.

### នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៥ - នៅស្រុកកំពង់ត្រាច ខេត្តកំពត

ស្ត្រីម្នាក់អាយុ២៤ឆ្នាំ បានស្លាប់នៅមន្ទីរពេទ្យក្នុងប្រទេសវៀតណាម ហើយត្រូវបានធ្វើតេស្តរកឃើញមានវីរុសជំងឺផ្តាសាយបក្សី។ ស្ត្រីនេះពុំមានប្រវត្តិនៃការប៉ះពាល់សត្វបក្សីដែលឈឺ ឬងាប់ច្បាស់លាស់ទេ ពីព្រោះគាត់មិននៅក្នុងភូមិទេក្នុងពេលមានការផ្ទុះជំងឺផ្តាសាយបក្សីលើសត្វមាន់-ទា។ នៅក្នុងសប្តាហ៍មុនពេលស្ត្រីនេះបានធ្លាក់ខ្លួនឈឺ បងប្រុសរបស់គាត់បានស្លាប់ដោយសារជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរនៅក្នុងភូមិនោះ។ គេបានសង្ស័យថាបងប្រុសរបស់គាត់អាចឆ្លងជំងឺផ្តាសាយបក្សី ប៉ុន្តែគេមិនបានប្រមូលវត្ថុវិភាគពីសាកសពទេ មុនពេលដែលបុរសនេះ ត្រូវបានបូជា។ នៅពេលស្ត្រីនេះបានដំណឹងថាបងប្រុសរបស់គាត់ស្លាប់ គាត់បានទៅជិតហើយអោបថើបសាកសពនោះ។ ការមានទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយសាកសពបងប្រុសរបស់គាត់ដែលកើតមានជំងឺធ្ងន់ធ្ងរនោះ ត្រូវបានគេសង្ស័យថាជាប្រភពនៃការប្រឈមមុខរបស់ស្ត្រីនេះទៅនឹងវីរុសជំងឺនេះ។ ទោះបីយ៉ាងណាក្តីការប្រឈមមុខដទៃទៀតមិនអាចត្រូវបានគេរកឃើញឡើយ។

### 30 January 2005 - Kampong Trach District, Kampot

A 24-year-old woman died in hospital in Viet Nam, and tested positive for avian influenza infection. She did not have a clear exposure to sick/dead poultry as she was living outside of the village when the outbreak in poultry was occurring. In the week before the woman became ill, her brother had died from a severe respiratory illness at the village. It is suspected that he may have been infected with avian influenza, but no samples were collected before he was cremated. When the woman heard her brother had died, she went to his body and was kissing and hugging his body. This intense, close contact with the potentially infected body of her brother is suspected to be the source of the woman's exposure to the virus. However, other exposures cannot be ruled out.

## នៅថ្ងៃទី២២ ខែមិនា ឆ្នាំ២០០៥ - នៅស្រុកបន្ទាយមាស ខេត្តកំពត

បុរសម្នាក់អាយុ២៨ឆ្នាំ បានកើតមានរោគសញ្ញាគ្រុនក្តៅ ឈឺក្បាល ពិបាកដកដង្ហើម និងចុកពោះ នៅថ្ងៃទី១៧ ខែមិនា ហើយត្រូវបានបញ្ជូនទៅមន្ទីរពេទ្យក្នុងរាជធានីភ្នំពេញនៅថ្ងៃទី២១ ខែមិនា។ គាត់បានស្លាប់នៅថ្ងៃទី២២ ខែមិនា។ នៅថ្ងៃដដែលនោះ ការធ្វើតេស្តពិសោធន៍ដោយវិទ្យាស្ថានប៉ាស្ទ័រក្នុងរាជធានីភ្នំពេញបានបញ្ជាក់ថា បុរសនេះបានឆ្លងវីរុសជំងឺផ្តាសាយបក្សី។

ការស៊ើបអង្កេតភ្លាមមួយត្រូវបានចាប់ផ្តើមដើម្បីស្រាវជ្រាវរកករណីដែលអាចមានបន្ថែមទៀត និងកំណត់ប្រភពនានាដែលអាចជាការប្រឈមមុខនឹងវីរុសនេះ។

តាមរបាយការណ៍បានឱ្យដឹងថាមានមាន់ងាប់ជាច្រើននៅក្នុងតំបន់នោះ ហើយវត្ថុវិភាគដែលយកពីមាន់ឈឺទាំងនោះត្រូវបានធ្វើតេស្តរកឃើញវីរុសជំងឺផ្តាសាយបក្សី។

លទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា បុរសដែលស្លាប់នោះ ធ្លាប់មានទំនាក់ទំនងជាមួយសត្វបក្សីឈឺ។

វត្ថុវិភាគដែលបានយកពីមនុស្សផ្សេងទៀត ដោយរួមទាំងមនុស្សនៅក្នុងគ្រួសាររបស់បុរសនោះ និងមន្ត្រីសុខាភិបាលនៅរាជធានីភ្នំពេញដែលចូលរួមក្នុងការថែទាំបុរសនោះ ត្រូវបានគេធ្វើតេស្តរកឃើញថាគ្មានការឆ្លងវីរុសជំងឺផ្តាសាយបក្សីទេ។

## 22 March 2005 - Bantey Meas District, Kampot

A 28-year-old man developed symptoms of fever, headache, difficulty breathing and abdominal pain on 17 March and was hospitalized in Phnom Penh on 21 March. He died on 22 March. The same day, laboratory tests by the Pasteur Institute in Phnom Penh confirmed that the man was infected with the avian influenza virus.

An immediate investigation was launched to search for possible additional cases and identify possible sources of exposure to the virus.

Numerous deaths among chickens in the area were reported and samples taken from sick chickens tested positive for avian influenza.

The results from the investigation indicate the deceased man had contact with sick poultry.

Samples taken from other people, including family contacts of the confirmed case and Phnom Penh medical staff involved in his care, all tested negative for avian influenza infection.

## នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៥ - នៅស្រុកកំពង់ត្រាច ខេត្តកំពត

កុមារីម្នាក់អាយុ៨ឆ្នាំបានធ្លាក់ខ្លួនឈឺដោយមានគ្រុនក្តៅនៅថ្ងៃទី២៩ ខែមិនា។ ស្ថានភាពជំងឺរបស់កុមារីនេះកាន់តែមានអាការៈធ្ងន់ធ្ងរឡើងៗយ៉ាងឆាប់រហ័សនៅថ្ងៃទី៧ ខែមេសា នៅពេលនាងត្រូវបានគេយកទៅមន្ទីរពេទ្យបង្អែកស្រុក ហើយបន្ទាប់មកត្រូវបានបញ្ជូនទៅមន្ទីរពេទ្យគន្ធបុប្ផាក្នុងរាជធានីភ្នំពេញ នាងក៏បានស្លាប់នៅទីនោះ។ វត្ថុវិភាគដែលបានយកពីកុមារីនេះ ត្រូវបានគេធ្វើតេស្តនៅវិទ្យាស្ថានប៉ាស្ទ័រក្នុងរាជធានីភ្នំពេញរកឃើញមានវីរុសជំងឺផ្តាសាយបក្សី។

ការស៊ើបអង្កេតដល់ទីកន្លែងត្រូវបានចាប់ផ្តើមភ្លាមៗ ហើយបានរកឃើញថាមានមាន់-ទាងាប់ នៅក្នុងភូមិនោះក្នុងខែកុម្ភៈ ប៉ុន្តែពុំមានមាន់-ទាងាប់នៅក្នុងរយៈពេលពីរសប្តាហ៍មុនពេលកុមារីនេះចាប់ផ្តើមមានរោគសញ្ញាឡើយ។ ការចំលងវីរុសពីមនុស្សទៅមនុស្សហាក់ដូចមិនមែនជាប្រភពនៃការឆ្លងជំងឺរបស់កុមារីនេះទេ ព្រោះគ្មាននរណាម្នាក់ក្នុងចំណោមមនុស្សដែលមានទំនាក់ទំនងជាមួយនាង ឈឺដោយមានរោគសញ្ញាស្រដៀងគ្នានេះទេនៅមុនពេលនាងបានធ្លាក់ខ្លួនឈឺ។

គេបានគិតថាក្មេងស្រីនេះ អាចមានការប្រឈមមុខនឹងវីរុសនេះដោយសារការហែលទឹកក្នុងស្រះចិញ្ចឹមទា។ សត្វទាអាចមានផ្ទុកវីរុសហើយបញ្ចេញវីរុសនេះតាមលាមករបស់វា។ មានស្រះចិញ្ចឹមទាជាច្រើននៅជិតផ្ទះរបស់កុមារីនេះ ហើយគេបានគិតថាសត្វទាខ្លះដែលកើតមានជំងឺ អាចធ្វើអោយស្រះទឹកណាមួយមានមេរោគហើយកុមារីនេះបានប្រឈមមុខនឹងវីរុសជំងឺផ្តាសាយបក្សីដោយសារការហែលក្នុងទឹកដែលមានមេរោគនោះ។ ទោះបីយ៉ាងណាក្តី ករណីនេះមិនអាចត្រូវបានគេបញ្ជាក់បង្ហាញអោយច្បាស់ប្រាកដឡើយ។

## 7 April 2005 - Kampong Trach District, Kampot

An 8-year-old girl became ill with a fever on the 29th March. Her condition deteriorated rapidly on 7 April, when she was taken to a district referral hospital and then transferred to Kuntha Bopha Hospital in Phnom Penh, where she died. Samples from the girl tested positive for the avian influenza virus at the Pasteur Institute, Phnom Penh.

A field investigation was conducted immediately and found that poultry deaths occurred in this village in February, but no poultry deaths occurred in the two weeks prior to the girl's onset of symptoms. Human-to-human transmission appears to be an unlikely source of the girl's infection, as none of her known contacts were sick with similar symptoms before she became ill.

It is thought that the girl may have been exposed to the virus by swimming in a duck pond. There were numerous duck ponds near the girl's house and it is thought that some infected ducks may have contaminated one of the ponds. Ducks can carry the virus and shed the virus in their faeces. The girl perhaps became exposed by swimming in the contaminated water. However, this cannot be conclusively proven.

## នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥ - នៅស្រុកបន្ទាយមាស ខេត្តកំពត

សិស្សវិទ្យាល័យម្នាក់ ភេទស្រី អាយុ២០ឆ្នាំ បានស្លាប់នៅថ្ងៃទី១៩ ខែមេសា ក្នុងមន្ទីរពេទ្យមួយនៅប្រទេសវៀតណាម។ វត្ថុវិភាគដែលយកពីនារីនេះ ត្រូវបានគេធ្វើតេស្តនៅវិទ្យាស្ថានប៉ាស្ទ័រនៅទីក្រុងហូជីមិញ ក្នុងប្រទេសវៀតណាម រកឃើញមានវីរុសជំងឺផ្តាសាយបក្សី។

ក្រសួងសុខាភិបាលនៃប្រទេសកម្ពុជា បានចាប់ផ្តើមធ្វើការស៊ើបអង្កេតនៅក្នុងភូមិដែលនារីនេះបានរៀន និងបានផ្តល់ការអប់រំដល់សិស្សទាំងអស់នៅសាលារៀននោះ។ នារីនេះគឺជាអ្នកលក់មាន់។ តាមរបាយការណ៍ឱ្យដឹងថា នាងបានប្រមូលមាន់ដែលងាប់ពីតំបន់ដែលនៅជុំវិញសាលារៀនរបស់នាងយកទៅលក់។

## 19 April 2005 - Bantey Meas District, Kampot

A 20-year-old secondary school woman died on 19 April in a hospital in Viet Nam. Samples taken from the woman tested positive for the avian influenza virus by the Pasteur Institute in Ho Chi Minh City, Viet Nam.

The Ministry of Health in Cambodia conducted an investigation in the village where the woman attended school and provided education sessions to the students at the school. The woman was a chicken seller. She reportedly collected some dead chickens from the area surrounding her school and was selling them.

## នៅថ្ងៃទី២១ ខែមិនា ឆ្នាំ២០០៦ - នៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ

កុមារីអាយុ៣ឆ្នាំម្នាក់ បានកើតមានគ្រុនក្តៅនៅថ្ងៃទី១៤ ខែមិនា។ ស្ថានភាពរបស់កុមារីនេះកាន់តែធ្ងន់ធ្ងរឡើងៗយ៉ាងឆាប់រហ័ស ហើយនាងត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យក្នុងរាជធានីភ្នំពេញនៅថ្ងៃទី២០ ខែមិនា។ នាងបានស្លាប់នៅថ្ងៃទី២១ ខែមិនា។ វត្ថុវិភាគដែលបានយកពីកុមារីនេះ ត្រូវបានគេធ្វើតេស្តនៅវិទ្យាស្ថានប៉ាស្ទ័រ ក្នុងរាជធានីភ្នំពេញរកឃើញមានវីរុសជំងឺផ្តាសាយបក្សី។

ការស៊ើបអង្កេតនៅក្នុងភូមិដាច់ស្រយាលដែលកុមារីនេះបានរស់នៅ បានរកឃើញថា សត្វមាន់-ទាដែលគេចិញ្ចឹមនៅតាមផ្ទះក្នុងភូមិនេះបានចាប់ផ្តើមងាប់ក្នុងខែកុម្ភៈ និងមានមាន់ងាប់ជាបន្តបន្ទាប់ទៀត។ កុមារីនេះត្រូវបានគេដឹងថា បានលេងជាមួយមាន់ ដែលមានរួមទាំងមាន់ឈឺខ្លះផងដែរ។

## 21 March 2006 - Kong Pisey district, Kompong Speu

A 3-year-old girl developed fever on 14 March. Her condition deteriorated rapidly and she was hospitalized in Phnom Penh on 20 March. She died on 21 March. Samples from the girl tested positive for the avian influenza virus at the Pasteur Institute in Cambodia.

An investigation in the remote village where the child lived found backyard poultry began dying in the village in February, and chicken deaths continued. The child is known to have played with chickens, including some showing signs of illness.

## នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០០៦ - នៅស្រុកមេសាង ខេត្តព្រៃវែង

ក្មេងប្រុសអាយុ១២ឆ្នាំម្នាក់ បានកើតមានរោគសញ្ញាគ្រុនក្ដៅ និងឈឺក្បាលនៅថ្ងៃទី២៩ ខែមីនា។ ក្មេងប្រុសនេះ ត្រូវបានព្យាបាលលើកដំបូងនៅគ្លីនិកឯកជនមួយ បន្ទាប់មកត្រូវបានបញ្ជូនទៅមន្ទីរពេទ្យក្នុងរាជធានីភ្នំពេញ នៅថ្ងៃទី៤ ខែមេសា។ ក្មេងប្រុសនេះបានស្លាប់នៅថ្ងៃទី៥ ខែមេសា។ វត្ថុវិភាគដែលបានយកពីក្មេងប្រុសនេះ ត្រូវបានធ្វើតេស្តនៅវិទ្យាស្ថានប៉ាស្ទ័រក្នុងរាជធានីភ្នំពេញ រកឃើញមានវីរុសជំងឺផ្ដាសាយបក្សី។

ការស៊ើបអង្កេតបានរកឃើញថា មានមាន់ជាច្រើន និងទាមួយចំនួនបានងាប់នៅក្នុងភូមិរបស់កុមារនេះ។ តាមរបាយការណ៍អោយដឹងថា កុមារនេះបានប្រមូលមាន់ងាប់ឱ្យសាច់ញាតិរបស់ខ្លួនដើម្បីរៀបចំធ្វើម្ហូបសំរាប់ទទួលទាន។

## 5 April 2006 - Mesang district, Prey Veng

A 12-year-old boy developed symptoms of fever and headache on 29 March. He was initially treated at a private clinic, then hospitalized in Phnom Penh on 4 April. He died on 5 April. Samples from the boy tested positive for the avian influenza virus at the Pasteur Institute in Phnom Penh.

An investigation found numerous chickens and some ducks died in the child's village. The child reportedly gathered dead chickens for his relatives who prepared them for consumption.

## ជំងឺផ្ដាសាយបក្សីលើមនុស្ស

មានករណីមនុស្សដែលបានឆ្លងជំងឺផ្ដាសាយបក្សីសរុបចំនួន២៤៦ករណី នៅទូទាំងពិភពលោក ហើយក្នុងចំនួននេះ មានមនុស្ស១៤៤នាក់បានស្លាប់។

ប្រទេសដែលកើតមានជំងឺផ្ដាសាយបក្សីនៅលើមនុស្ស រួមមាន ប្រទេស Azerbaijan ប្រទេសកម្ពុជា ប្រទេសចិន ប្រទេស Djibouti ប្រទេសអេហ្ស៊ីប ប្រទេសឥណ្ឌូនេស៊ី ប្រទេសអ៊ីរ៉ាក់ ប្រទេសថៃ ប្រទេសទួរគី និងប្រទេសវៀតណាម។

(អង្គការសុខភាពពិភពលោក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៦)

## Avian influenza in humans

There have been 246 total cases of avian influenza in humans throughout the world, of whom 144 have died.

The affected countries with human cases of avian influenza are Azerbaijan, Cambodia, China, Djibouti, Egypt, Indonesia, Iraq, Thailand, Turkey and Viet Nam.



(WHO, 14 September 2006)

# ផែនការជាតិស្ដីពីជំងឺផ្ដាសាយបក្សី និងជំងឺផ្ដាសាយធម្មតា

# National Comprehensive Avian and Human Influenza Plan

ដើម្បីដោះស្រាយបញ្ហាជំងឺផ្ដាសាយបក្សីក្នុងយុទ្ធវិធីរួម និងប្រកបដោយនិរន្តរភាព រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតផែនការជាតិមួយស្ដីពីជំងឺផ្ដាសាយបក្សី និងជំងឺផ្ដាសាយធម្មតា ។

## គោលបំណង

- ដើម្បីគ្រប់គ្រងការផ្ទុះជំងឺផ្ដាសាយបក្សីលើសត្វបក្សី
- ដើម្បីបង្ការការចំលងជំងឺផ្ដាសាយបក្សីពីសត្វបក្សីទៅមនុស្ស
- ដើម្បីកាត់បន្ថយជាអតិបរមានូវគ្រោះថ្នាក់ និងផលវិបាកនានាដោយសារការផ្ទុះជំងឺផ្ដាសាយឆ្លងភាគត្បាតជាសកល ។

## រចនាសម្ព័ន្ធ និងវិសាលភាព

សមាសភាពនៃផែនការជាតិនេះមាន ផែនការសុខភាពសត្វដែលបានបង្កើតឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផែនការសុខភាពមនុស្សដែលបានបង្កើតឡើងដោយក្រសួងសុខាភិបាល និងរួមទាំងផែនការកិច្ចសហប្រតិបត្តិការអន្តរក្រសួង ។

**In order to tackle the problem of avian influenza in an integrated, holistic and sustainable manner, the Royal Government of Cambodia has developed a National Comprehensive Avian and Human Influenza Plan.**

## Objectives

- To control the outbreak of avianb influenza in birds
- To prevent transmission of avian influenza from birds to human
- To minimize risk and consequences of a pandemic.

## Structure and scope

This Comprehensive Plan is composed of Animal health plan developed by the Ministry of Agriculture, Fisheries and Forestry together with the human health plan developed by the Ministry of Health combined with the Inter-Ministerial Cooperation Plan.

## សមាសភាពនៃផែនការជាតិ
## Composition of National Comprehensive Plan

ផែនការជាតិស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺផ្តាសាយធម្មតា
Cambodia National Comprehensive
Avian and Human Influenza Plan

ផែនការកិច្ចសហប្រតិបត្តិការអន្តរក្រសួង
Inter-Ministerial Cooperation Plan

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
National Committee for Disaster Management (NCDM)

ផែនការសុខភាពមនុស្ស
Human Health Plan

ក្រសួងសុខាភិបាល
Ministry of Health (MOH)

ផែនការសុខភាពសត្វ
Animal Health Plan

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
Ministry of Agriculture, Forestry and Fisheries (MAFF)

**ផែនការសុខភាពសត្វ** មានយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រង និងការលុបបំបាត់ជំងឺផ្តាសាយបក្សីដោយរួមទាំងផែនការសកម្មភាពសំរាប់អនុវត្តការគ្រប់គ្រងជំងឺផ្តាសាយបក្សី នៅក្នុងប្រទេសកម្ពុជា។ ផែនការនេះត្រូវបានអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ផែនការសុខភាពមនុស្ស** ត្រូវបានអនុវត្តដោយក្រសួងសុខាភិបាល និងបញ្ចូលទាំងផែនការសកម្មភាពសំរាប់ជំងឺផ្តាសាយបក្សី នៅក្នុងប្រទេសកម្ពុជា ដោយមានរួមទាំងផែនការ ជាតិស្តីពីការត្រៀមខ្លួនជាស្រេច និងការឆ្លើយតបទៅនឹងការផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកល។

**The Animal Health Plan** is comprised of the National Strategy on Highly Pathogenic Avian Influenza Control and Eradication combined with the Action Plan for implementing the control of avian influenza in Cambodia. It is implemented by the The Ministry of Agriculture, Forestry and Fisheries (MAFF).

**The Human Health Plan** is implemented by the Ministry of Health (MOH) and combines the Action Plan for avian influenza in Cambodia with the National Pandemic Influenza Preparedness and Response Plan of Cambodia.

**ផែនការកិច្ចសហប្រតិបត្តិការអន្តរក្រសួង**ផ្តោតទៅលើការរៀបចំកិច្ចសហប្រតិបត្តិការ និងកិច្ចសម្របសម្រួល ក្នុងចំណោមក្រសួងនានា ក្នុងគោលបំណងដើម្បីគាំទ្រការបង្ការជំងឺផ្តាសាយបក្សី និងជំងឺផ្តាសាយធម្មតា។ ផែនការនេះត្រូវបានសម្របសម្រួលដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

(សំរាប់ព័ត៌មានលំអិតស្តីពីផែនការជាតិនេះ សូមទំនាក់ទំនងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ)

យុទ្ធសាស្ត្រប្រាស្រ័យទាក់ទង និងផែនការសកម្មភាពជាតិស្តីពីជំងឺផ្តាសាយបក្សី និងជំងឺផ្តាសាយធម្មតា ត្រូវបានបង្កើតឡើងដើម្បីគាំទ្រផែនការជាតិស្តីពីជំងឺផ្តាសាយបក្សី និងជំងឺផ្តាសាយធម្មតា។

គោលបំណងរួមនៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងនេះគឺដើម្បីផ្តល់ព័ត៌មានដល់សាធារណៈជនអំពីជំងឺផ្តាសាយបក្សី ដើម្បីកាត់បន្ថយការប្រឈមមុខនិងគ្រោះថ្នាក់នៃការឆ្លងជំងឺនេះ។ ប្រសិនបើទទួលបានជោគជ័យទាំងស្រុងវានឹងអាចបង្ការការឆ្លងរាលដាលជាសកលដែលបណ្តាលមកពីការបំផ្លែងរបស់វីរុស H5N1 ដើម្បីអាចចំលងពីមនុស្សទៅមនុស្ស។ ប៉ុន្តែដើម្បីត្រៀមខ្លួនជាស្រេចចំពោះការឆ្លងរាលដាលជាសកល យុទ្ធសាស្ត្រនេះក៏បានគូសបញ្ជាក់ពីផែនការក្នុងការផ្តល់ព័ត៌មានដល់សាធារណៈជនអំពីការរាំងខ្ទប់ការឆ្លងរាលដាលជំងឺនេះរួមទាំងការថែទាំអ្នកជំងឺ និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅក្នុងពេលមានវិបត្តិ ដើម្បីផ្តល់ព័ត៌មាន និងគ្រប់គ្រងភាពភ័យរន្ធត់។

យុទ្ធសាស្ត្រនេះ បានចែងអំពីស្ថានភាពក្នុងពីរដំណាក់កាលផ្សេងៗគ្នា (ដំណាក់កាលមុនពេលឆ្លងរាលដាលជាសកល និងពេលឆ្លងរាលដាលជាសកល) ដែលមានគោលបំណងបួន:

**The Inter-Ministerial Cooperation Plan** focuses on cooperation and coordination arrangements among ministries in support of both Avian and Human Influenza prevention. It is coordinated by the National Committee for Disaster Management (NCDM).

(For detail information on the Comprehensive Plan, please contact NCDM)

A National Communication Strategy and Action Plan on Avian and Human Influenza have been developed to support the National Comprehensive Avian and Human Influenza Plan.

The overall aim of this communication strategy is to inform the public about avian influenza in order to reduce the risk of its transmission. If entirely successful, this would prevent a pandemic caused by a human-to-human variation of the H5N1 virus. But in order to be prepared for a pandemic, the strategy also outlines plans for informing the public about containing the spread of disease in a pandemic and caring for the sick; and using the mass media in a crisis for sharing information and controlling panic.

The strategy covers two different phases of the situation - pre-pandemic and pandemic - under which there are four objectives:

### ដំណាក់កាលមុនពេលផ្ទុះរាលដាលជាសកល

១. កាត់បន្ថយឱកាសនៃការចំលងជំងឺផ្តាសាយបក្សីពីសត្វទៅសត្វ
២. កាត់បន្ថយឱកាសនៃការចំលងជំងឺផ្តាសាយបក្សីពីសត្វទៅមនុស្ស និងកំណត់ព្រំដែនការឆ្លងរាលដាលជំងឺផ្តាសាយធម្មតា

### ដំណាក់កាលពេលផ្ទុះរាលដាលជាសកល

៣. រាំងខ្ទប់ការកើតឡើងនៃវីរុសជំងឺផ្តាសាយដែលផ្ទុះឡើង (ឆ្លងរាលដាលជាសកល) លើមនុស្ស
៤. ការរស់នៅក្រោយពីការផ្ទុះជំងឺផ្តាសាយឆ្លងរាលដាលជាសកល

យុទ្ធនាការប្រាស្រ័យទាក់ទងភ្លាម១និងមានរយះពេលយូរត្រូវបានបង្កើតឡើងដើម្បីគាំទ្រការអនុវត្តន៍គោលបំណងទី១និងទី២និងរបៀបប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសំរាប់ការអនុវត្តន៍គោលបំណងទី៣និងទី៤នៅពេលមានការផ្ទុះជំងឺផ្តាសាយឆ្លងជាសកល ។

គណៈកម្មាធិការជាតិសម្របសម្រួលព័ត៌មានការអប់រំ និងការប្រាស្រ័យទាក់ទង (IEC) សំរាប់ជំងឺផ្តាសាយបក្សី និងជំងឺផ្តាសាយធម្មតាត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួល និងធានាបាននូវការអនុវត្តន៍យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងថ្នាក់ជាតិ ។ យុទ្ធសាស្ត្រនេះនឹងធានាបាននូវការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនិងដែលផ្តោតលើអន្តរាគមន៍នៃព័ត៌មានការអប់រំ និងការប្រាស្រ័យទាក់ទង (IEC) ព្រមទាំងសារល្អៗ ច្បាស់លាស់ត្រឹមត្រូវ និងដែលទាក់ទងទៅនឹងវីរុសជំងឺផ្តាសាយបក្សី ។ យុទ្ធសាស្ត្រនេះក៏នឹងផ្តល់នូវការត្រួតពិនិត្យជាទៀងទាត់ និងទៅតាមពេលវេលាអំពីសកម្មភាពប្រាស្រ័យទាក់ទងនិងសារស្តីពីជំងឺផ្តាសាយបក្សី ក្នុងគោលបំណងដើម្បីសម្របសម្រួលសកម្មភាពនៅពេលចាំបាច់ ។

### Pre-pandemic

1. Reduce the risk of animal to animal transmission of avian influenza
2. Reduce the risk of animal to human transmission of avian influenza and limit the spread of human influenza

### Pandemic

3. Contain an emerging human (pandemic) virus
4. Survive a pandemic

Immediate and longer-term communication campaigns have been developed to support the implementation of objectives 1 and 2; and how to use the mass media for the implementation of objectives 3 and 4 should a pandemic develop.

A National Coordinating Committee on IEC for Avian and Human Influenza has been formed to coordinate and ensure implementation of the National Communication Strategy. It will ensure coordinated, effective and focused IEC interventions as well as clear, correct and consistent key messages relating to Highly Pathogenic Avian Influenza. It will provide regular and periodic review of the communication activities and messages on avian influenza in order to adjust the activities when needed.

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសុខាភិបាល ត្រូវបានជ្រើសរើសជាក្រសួងតំណាងសំរាប់ដំណាក់កាលទី៣-៥ នៃការប្រុងប្រយ័ត្នចំពោះជំងឺផ្តាសាយដែលផ្ទុះឡើងរាតត្បាតជាសកលដែលកំណត់ដោយអង្គការសុខភាពពិភពលោក។ នៅពេលការឆ្លងរាលដាលជាសកលកើតឡើង ហើយប្រតិបត្តិការគ្រាមានអាសន្នមានរួចជាស្រេច (ដំណាក់កាលទី៦) គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនឹងអាចទទួលតួនាទីជាអ្នកតំណាង។ អង្គការ UNICEF គឺត្រូវធ្វើជាលេខាធិការដ្ឋាននៅគ្រប់ដំណាក់កាលទាំងអស់។

The Ministry of Agriculture, Forestry and Fisheries (MAFF) and the Ministry of Health (MOH) have been designated co-moderators for Phases 3-5 of the WHO pandemic alert level. Should a pandemic emerge and emergency operations come into place (Phase 6), the National Committee for Disaster Management (NCDM) would take over the moderator's role. UNICEF is to be the Secretariat through all Phases.

### ផែនការសកម្មភាពរបស់ក្រសួងសុខាភិបាលស្តីពីជំងឺផ្តាសាយបក្សី

១. ឆ្លើយតបទៅនឹងករណីមនុស្សដែលឆ្លងជំងឺផ្តាសាយបក្សី
២. កាត់បន្ថយការគំរាមកំហែងដោយសារការឆ្លងរាលដាលជាសកល
៣. កាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ក្នុងករណីឆ្លងរាលដាលជាសកល

### MoH Avian Influenza Action Plan

1. Respond to human cases of Avian Influenza
2. Abate the threat of a pandemic
3. Minimize the impact in the case of a pandemic



ក្រុមមន្ត្រីឆ្លើយតបបន្ទាន់របស់ក្រសួងសុខាភិបាល
Ministry of Health Rapid Response Team
Photo:MoH

# ការបង្ការជំងឺផ្តាសាយបក្សីនៅលើសត្វ

# Prevention of Avian Influenza in Animals

## វិធានការសំខាន់ៗដើម្បីបញ្ឈប់ការឆ្លងរាលដាលនៃជំងឺផ្តាសាយបក្សី ៖

- ចូរដាក់មាន់-ទានៅក្នុងទ្រុង ឬរបង ដើម្បីបង្ការការឆ្លងជំងឺគ្រប់ប្រភេទ រួមទាំងជំងឺផ្តាសាយបក្សី
- ចូរសំអាតទីធ្លាក្នុងរបងឱ្យបានស្អាត
- ចូរដាក់ទានិងមាន់ឱ្យនៅដាច់ពីគ្នា ដើម្បីបង្ការការឆ្លងជំងឺពីគ្នាទៅវិញទៅមក
- ចូរដាក់មាន់-ទាដែលទើបទិញថ្មីៗឱ្យនៅដាច់ពីមាន់-ទាដទៃទៀត។ ការធ្វើបែបនេះ គេហៅថា "វិធានចត្តាឡីស័ក" ដែលមានរយៈពេល១៤ថ្ងៃ
- ចូរដាក់មាន់-ទាដែលមានសុខភាពល្អឱ្យនៅដាច់ពីមាន់-ទាដែលឈឺ។ ចូរតាមដានត្រួតពិនិត្យ និងព្យាបាលមាន់-ទាដែលឈឺ។ សូមទាក់ទងពេទ្យសត្វស្រុកជាបន្ទាន់ នៅពេលមានមាន់-ទាឈឺ ដើម្បីឱ្យពួកគេជួយ។

## Important measures to stop the spread of bird flu:

- Keep poultry fenced to protect them from all diseases, including avian influenza.
- Keep the fenced area clean.
- Separate ducks and chickens from each other so they don't pass any virus to each other.
- Separate newly-bought poultry from the other poultry. This is called "quarantine" and should last 14 days.
- Separate healthy poultry from sick poultry. Monitor and cure the sick ones. Call the district vet immediately when you have sick poultry so they can help you.



លោកអ៊ុល ទេវិន
គ្រូបណ្តុះបណ្តាលផ្នែកសុខភាពសត្វ (អង្គការ FAO)
Mr. Ul Tevin
Animal Health Trainer (FAO)

# ជីវសុវត្ថិភាព
# Biosecurity

**ជីវសុវត្ថិភាពគឺជាការអនុវត្តន៍ដ៏ល្អមួយក្នុងការចិញ្ចឹមសត្វដើម្បីការពារសត្វពីជំងឺផ្សេងៗ**

- វាពុំចំណាយថវិកាច្រើនហើយងាយស្រួលធ្វើ។
- ជីវសុវត្ថិភាពអាចធ្វើទាំងនៅក្នុងកសិដ្ឋានធំ និងតូច ដោយប្រើសំភារៈដែលមានក្នុងភូមិ។
- ប្រសិនបើមិនអនុវត្តវិធានការជីវសុវត្ថិភាពទេ យើងនឹងត្រូវចំណាយពេលវេលា និងថវិកាច្រើនថែមទៀតក្នុងការខិតខំដោះស្រាយបញ្ហាជំងឺនេះនៅពេលវាកើតឡើង។
- ជីវសុវត្ថិភាពនឹងជួយការពារកសិដ្ឋានប្រឆាំងនឹងរាល់ជំងឺគ្រប់ប្រភេទ ពោលគឺមិនត្រឹមតែជំងឺផ្តាសាយបក្សីប៉ុណ្ណោះទេ។

**Biosecurity is a good farming practice that protects animals from disease.**

- It does not cost much money and is easy.
- Biosecurity can be done in both large and small farms using local materials.
- If biosecurity measures are not followed, we spend more time and more money to try and solve the disease when it does appear.
- Biosecurity will help to protect farms against every disease, not only avian influenza.

## គោលការណ៍នៃជីវសុវត្ថិភាព
## Principles of Biosecurity

### ១. រក្សាទុកមាន់-ទានៅក្នុងកន្លែងដែលមានស្ថានភាពល្អ

សត្វដែលមានសុខភាពល្អអាចប្រឆាំងនឹងជំងឺនានាបានកាន់តែប្រសើរ

### 1. Keep the poultry in good condition.

A healthy animal resists diseases better.



## ២. រក្សាទុកមាន់ទានៅក្នុងបរិស្ថានដែលមានការការពារ -ដាក់មាន់ទារបស់អ្នកនៅក្នុងរបងព័ទ្ធជុំវិញ

- ចូរដាក់មាន់នៅក្នុងទ្រុងមាន់ដែលមានរបងធំទូលាយ ។
- បើមិនអាចសង់កន្លែងដាក់ទា ឬទ្រុងមាន់ទេ ចូរធ្វើរបងព័ទ្ធជុំវិញទីធ្លា ដើម្បីជៀសវាងកុំឱ្យវាប៉ះពាល់ជាមួយបសុបក្សីផ្សេងទៀត ។
- បើយើងអនុញ្ញាតឱ្យមាន់-ទាចូលទៅក្នុងទីធ្លាកសិដ្ឋាន ចូរសំអាតបរិវេណទីធ្លានោះឱ្យស្អាត ជាពិសេសលាមករបស់វា ។
- ការអនុញ្ញាតឱ្យសត្វទាដើររកចំណីនៅក្នុងវាលស្រែ គឺជាការប្រព្រឹត្តដែលប្រឈមមុខនឹងគ្រោះថ្នាក់ ។ ចូរដាក់ទានៅក្នុងរបង ។

## 2. Keep the poultry in a protected environment - fence your birds.

- Keep chickens in a chicken house with a wide fence.
- If building a duck area or a chicken house is not possible then fence the yard to keep other poultry out.
- If poultry are allowed to go in the farmyard, keep the ground clean, especially of feces.
- Letting ducks scavenge in paddy fields is a risky behavior. Keep ducks fenced.

---

បើមានមាន់-ទាមួយឬច្រើនឈឺ ដូចជា ងងុយដេក ខ្សោយ ដើរយឺត ចូរយកមាន់-ទា ទាំងនោះចេញពីហ្វូង ទៅដាក់នៅក្នុងទ្រុងបិទជិត ។ មិនត្រូវឱ្យមាន់-ទាដែលឈឺនោះមានទំនាក់ទំនងជាមួយមាន់-ទា ឬសត្វដទៃទៀត ឬមនុស្សឡើយ ជាពិសេសជាមួយកុមារ ។

If one or more birds appear to be sick (sleepy, weak or slow) take these birds out of the flock and place them in a closed cage. They must not be in contact with other birds, animals or people, especially not with children.

---

“ ខ្ញុំតែងតែបង្ការមិនឱ្យមាន់-ទារបស់អ្នកជិតខាងមកជិតមាន់-ទារបស់ខ្ញុំឡើយ ។ ខ្ញុំដាក់មាន់-ទាណាដែលឈឺឱ្យនៅដាច់ដោយឡែកពីគេ ដើម្បីបង្ការមិនឱ្យវាឆ្លងជំងឺទៅមាន់-ទាដែលមានសុខភាពល្អ ។

I always prevent other people's poultry from mingling with mine. I put any sick chickens or ducks by themselves in order to stop healthy poultry from getting sick. ”

**លោកពូ មាន សុខុម កសិករ ខេត្តបន្ទាយមានជ័យ**
**Mr. Mean Sokhom, Farmer, Banteay Meanchey**



## ៣. ការគ្រប់គ្រងការចេញចូលក្នុងកសិដ្ឋាន និងនៅក្នុងទីធ្លាភូមិរបស់អ្នក

គ្រប់មនុស្សទាំងអស់ដែលមកពីកន្លែងដែលមានមាន់-ទាឈឺ អាចនាំមេរោគជំងឺនោះមកជាមួយៈ តាមស្បែកជើង សំលៀកបំពាក់ សំភារៈបរិក្ខារ ឬសំបកកង់យានជំនិះ។ មនុស្សអាចមិនដឹងខ្លួនថា ពួកគេកំពុងចេញមកពីកន្លែងដែលបានឆ្លងជំងឺ ហើយបាននាំវីរុសនោះទៅក្នុងកសិដ្ឋានទេ។

## 3. Control the entries on to your farm and property.

Everyone coming from a place where there are sick poultry can carry the virus - on their shoes, clothes, equipment or vehicle tires. People may not know they are coming from an infected area and that carry the virus into the farm.



### ការចេញចូលដែលធ្វើឱ្យកសិដ្ឋានប្រឈមមុខនឹងគ្រោះថ្នាក់រួមមាន :

- មនុស្សដែលចូលទៅក្នុងកសិដ្ឋាន រួមមានភ្ញៀវ អ្នកជិតខាង ភ្ញៀវពិសេសៗដែលមកចូលរួមក្នុងពិធីមង្គលការ ។ល។
- ការត្រលប់មកផ្ទះវិញពីផ្សារ ឬពីវាលស្រែ។
- ម៉ូតូ កង់ ឬយានជំនិះផ្សេងៗទៀត ដែលចូលទៅក្នុងទីធ្លាកសិដ្ឋាន។
- ឈ្មួញកណ្តាលដែលមកទិញ ឬលក់មាន់-ទា ជ្រូក គោ ក្របី ឬផលិតផលកសិកម្មផ្សេងទៀត។
- កូនមាន់ កូនទា កូនជ្រូក ឬសត្វផ្សេងៗទៀត ដែលទើបតែទិញថ្មីៗ។
- ការទិញចំណីសត្វ សំភារៈបរិក្ខារ លាមកសត្វ។
- សត្វឆ្កែ ឬឆ្មាដែលពាំសត្វងាប់។

### Risky entries on to a farm include:

- People coming to the farm including visitors, neighbors, special guests for weddings, etc.
- Returning home from the local market or paddy fields.
- Entry of motorbike, bicycle or other vehicle in the farmyard.
- Middlemen coming to buy or to sell poultry but also pigs, cattle or other agriculture products.
- Newly bought chicks, ducklings, piglets or other animals.
- Purchase of animal feed, equipment, manure, etc.
- Dogs or cats that bring dead animals.

ចូរឱ្យភ្ញៀវនៅឆ្ងាយពីកន្លែងដែលមាន់-ទារស់នៅ ឬកំពុងស៊ីចំណី ។

- ប្រការនេះអាចអនុវត្តដោយងាយស្រួលនៅពេលដែលមាន់-ទាត្រូវបានដាក់ក្នុងរបងព័ទ្ធជុំវិញ ។
- ចូរសុំឱ្យមនុស្ស (ជាពិសេសឈ្មួញកណ្ដាលដែលមានដឹកមាន់-ទារស់) ទុកម៉ូតូ ឬកង់របស់គាត់នៅឯទ្វាររបងកសិដ្ឋាន ។ មិនត្រូវឱ្យឈ្មួញកណ្ដាលចូលទៅក្នុងទីធ្លាកសិដ្ឋានរបស់អ្នកឡើយ ។ បើអ្នកចង់លក់មាន់-ទារបស់អ្នក ចូរនាំយកមាន់-ទាទាំងនោះដោយខ្លួនឯងចេញទៅក្រៅឱ្យឈ្មួញកណ្ដាល ។
- ចូរលាងសំអាតដៃជាមួយសាប៊ូ ឬផេះជានិច្ចនៅមុនពេលនិងក្រោយពេលថែទាំសត្វ ។

Keep the visitors away from where the poultry live or eat.

- This can be easily done when poultry is fenced.
- Ask people, especially the middleman carrying live birds, to leave their motorbike or bicycle at the farm gate. Do not let the middleman enter your farmyard. If you want to sell your animals, carry them yourself outside to the middleman.
- Always wash hands with soap or ash, before and after taking care of animals.

## ការឆាប់រកឃើញ - ការឆាប់ឆ្លើយតប

នៅពេលកត់សំគាល់ឃើញមានមាន់-ទា ឈឺនៅក្នុងតំបន់របស់អ្នក សូមរាយការណ៍ជាបន្ទាន់ ។

## EARLY DETECTION - EARLY RESPONSE

Recognize when there are sick or dead poultry in your area, and report immediately.



**រាយការណ៍ជាបន្ទាន់**

**Report Immediately**

មជ្ឈមណ្ឌលជាតិស្រាវជ្រាវផលិតកម្ម និងបសុពេទ្យ

MAFF hotline **012 833 795 012 214 970**

ឬសូមទាក់ទងភ្នាក់ងារសុខភាពសត្វភូមិ ពេទ្យសត្វស្រុក ឬខេត្ត ឬសូមពិភាក្សាជាមួយប្រធានភូមិ ឬសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់របស់លោកអ្នក ។

Or contact your Village Animal Health Worker, or district or provincial vet, or talk to your Village Leader or a Commune Council Member.

## អនុសាសន៍សំរាប់ប្រជាជនថែទាំមាន់_ទា

កសិករនិងប្រជាជនដែលមានចិញ្ចឹមមាន់-ទានៅតាមផ្ទះ អាចអនុវត្តវិធានការមួយចំនួនដែលនឹងអាចជួយបង្ការ ការឆ្លងជំងឺផ្តាសាយបក្សីដល់មាន់-ទារបស់ខ្លួន។

## The recommendations for people keeping poultry are:

Farmers and people who have poultry at home can implement some measures which will help prevent their poultry from becoming infected with avian influenza.













## ទិញមាន់_ទាដែលមានសុខភាពល្អ

ទោះបីមាន់-ទាមិនថ្លៃក៏ដោយ សូមកុំទិញវាឱ្យសោះ - បើយើងដឹងថា វាមានជំងឺ។ សូមសាកសួរសំនួរដើម្បីឱ្យដឹងថាមាន់-ទានោះមកពីកន្លែងណា និងសួរថាតើមាន់-ទាដទៃទៀតនៅក្នុងហ្វូងជាមួយវាមានជំងឺដែរ ឬទេ។



### Buy healthly poultry

Even if a bird seems inexpensive, don't purchase it - unless you know it is not sick. Ask questions to find out where it came from and if any other birds from the same flock have been sick.

# រក្សាទុកមាន់-ទាឱ្យមានសុវត្ថិភាព
# Keeping poultry safe

## ដាក់មាន់-ទានៅក្នុងរបងព័ទ្ធជុំវិញ

ការធ្វើដូច្នេះ ពួកវាគ្មានការប៉ះពាល់ជាមួយមាន់-ទាដែលដើររកចំណីផងទៃទៀត ដែលអាចមានជំងឺផ្តាសាយបក្សី ។

## Fence or enclose poultry

So they don't mix with possible avian influenza infected roaming poultry



មាន់-ទាដែលបានឆ្លងជំងឺអាចចម្លងវីរុសនេះទៅមាន់-ទាផងទៃទៀត និងមនុស្សបាន ។

**Infected poultry can transfer the virus to other poultry and humans.**

## សូមដាក់ទានិងមាន់ឱ្យនៅដាច់ពីគ្នា

មាន់តែងតែអាចងាប់ ប៉ុន្តែទាជួនកាលហាក់ដូចជាអាចនៅមានសុខភាពល្អ ទោះបីពួកវាមានជំងឺក៏ដោយ ។

## Keep ducks and chickens separate

Chickens almost always die but ducks can sometimes look healthy even if they have been infected.





ការចិញ្ចឹមមាន់ និងទាជាមួយគ្នាដូច្នេះមិនមែនជាការល្អទេ- សូមចិញ្ចឹមមាន់ និងទាឱ្យនៅដាច់ពីគា
Its not good practise to feed chickens and ducks together - keep them separate!

## សូមសំអាតទីធ្លាកុំឱ្យមានលាមកសត្វ

វីរុសជំងឺផ្តាសាយបក្សីអាចរស់នៅក្នុងលាមកសត្វ ៖ ការសំអាតនេះបង្ការសត្វនិងកុមារមិនឱ្យប៉ះពាល់ជាមួយលាមកនោះ ។

## Clean yard of feces

The virus can live in waste droppings. Cleaning up feces prevents animals and/or children from contact with the virus.



## សូមយកមាន់-ទាដែលឈឺចេញពីហ្វូងជាបន្ទាន់

បើមានមាន់-ទាឈឺ សូមរាយការណ៍ជាបន្ទាន់

## Take sick birds out of the flock immediately.

Report immediately any sick birds.



## ការចាក់ថ្នាំវ៉ាក់សាំងដល់មាន់-ទា

មកដល់ពេលនេះ ពុំមានវ៉ាក់សាំងបង្ការជំងឺផ្តាសាយបក្សីទេ នៅក្នុងប្រទេសកម្ពុជា ។

វ៉ាក់សាំងបង្ការជំងឺផ្សេងៗទៀត ដូចជាជំងឺញ៉ូកាស ឬដង្កាកាច់ (Newcastle disease) អាចជួយធ្វើឱ្យមាន់-ទា មានសុខភាពល្អ ។ សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងពេទ្យសត្វស្រុក ឬពេទ្យសត្វខេត្ត ។

## Vaccinating poultry

There is no vaccine against avian influenza in Cambodia.

Vaccines against diseases such as Newcastle disease help keep poultry in good condition. Contact your district or provincial vet for more information.

## សូមដាក់មាន់-ទាថ្មីឱ្យនៅដាច់ពីគេ



អ្នកអាចដាក់មាន់-ទាចំណូលថ្មីឱ្យនៅក្នុងទ្រុងធំមួយដាច់ពីគេ។ អ្នកមិនគួរបណ្ដោយឱ្យមាន់-ទាដទៃទៀតអាចចូលមកជិតទ្រុងនោះក្នុងចំងាយបីម៉ែត្រឡើយ។

- បើមានមាន់-ទាណាមួយចេញពីកសិដ្ឋានរបស់អ្នក ពេលវាត្រលប់មកវិញ សូមដាក់វាឱ្យនៅដាច់ពីគេក្នុងរយៈពេល១៤ថ្ងៃ។

## Quarantine new poultry



New poultry can be kept in quarantine under a large basket. Other poultry should not be able to come within 3 meters of the basket.

- If a bird leaves your farm, when it comes back keep it separate for 14 days.

## ការដាក់មាន់-ទាឱ្យនៅដាច់ដោយឡែកពីគេ (វិធានចត្តាឡីស័ក)

*ការដាក់ឱ្យនៅដាច់ដោយឡែកដើម្បីបង្ការការឆ្លងរាលដាលជំងឺ*

- ប្រសិនបើកសិករណាម្នាក់ទិញមាន់-ទាថ្មី ឬទទួលបានមាន់-ទាជាអំណោយ សូមដាក់មាន់-ទានោះនៅកន្លែងដាច់ដោយឡែកពីគេដោយមិនឱ្យវាមានទំនាក់ទំនងជាមួយសត្វផ្សេងទៀតក្នុងរយៈពេល១៤ថ្ងៃ។
- ទោះបីមាន់-ទាថ្មីនោះមើលទៅមានសុខភាពល្អក៏ដោយ ក៏គ្មាននរណាម្នាក់អាចដឹងថា តើវាមានផ្ទុកវីរុស ឬអត់ នោះទេ។ ប្រសិនបើវាមានផ្ទុកវីរុស នោះវានឹងឈឺហើយអាចងាប់ក្នុងអំឡុងពេល១៤ថ្ងៃ។ ប្រសិនបើមិនបានដាក់វាឱ្យនៅដាច់ដោយឡែកពីគេទេ វានឹងអាចចំលងជំងឺដល់មាន់-ទាដទៃទៀត។
- ប្រសិនបើមាន់-ទានោះគ្មានផ្ទុកវីរុសទេនោះ វានឹងនៅមានសុខភាពល្អដដែលបន្ទាប់ពីរយៈពេល១៤ថ្ងៃ ហើយយើងអាចលែងវាឱ្យចូលក្នុងហ្វូងមាន់-ទាដទៃទៀតបាន។

## Quarantine

*A strict isolation imposed to prevent the spread of disease.*

- If a farmer buys new poultry or receives poultry as a gift, the poultry should be put in a separate place with no contact with other animals for 14 days.
- Even if the new animals look healthy, no one can know if they carry a virus or not. If they do carry a virus, they will get sick and maybe die during the 14 days. If they are not kept separate, they will infect other poultry.
- If they do not carry a virus, they will still be healthy after 14 days and can be released to join the other poultry.

## ទីផ្សារលក់មាន់-ទា គឺជាទីកន្លែងដែលប្រឈមមុខនឹងគ្រោះថ្នាក់

- មាន់-ទា ផលិតផលមាន់-ទា និងឧបករណ៍សំភារៈដែលប្រឡាក់លាមកសត្វដែលមានជំងឺ ជាពិសេសទ្រុង អាចជាប្រភពចំលងវីរុសនេះ។
- សូមកុំប៉ះពាល់រោម/ស្លាបសត្វ ឬកាកសំណល់រាវ (លាមក ទឹកនោម ឈាមនិងសារធាតុរាវហូរចេញពីច្រមុះ) ប្រសិនបើមិនពាក់ស្រោមដៃ (ឬស្បោងប្លាស្ទិក) និងម៉ាស់ ឬក្រម៉ាទេ។
- សូមលាងសំអាតដៃរបស់អ្នកនៅមុនពេលនិងក្រោយពេលចាប់កាន់មាន់-ទា ឬផលិតផលមាន់-ទា

## ចំពោះអ្នកលក់មាន់-ទា ឬផលិតផលមាន់-ទា

- ការធ្វើអាជីវកម្មមាន់-ទា ឬផលិតផលមាន់-ទាដែលមានជំងឺ គឺជាវិធីមួយក្នុងចំណោមវិធីសំខាន់ៗនៃការឆ្លងរាលដាលជំងឺផ្តាសាយបក្សី។
- អ្នកធ្វើអាជីវកម្មដែលគោរពច្បាប់ស្តីពីការចរាចរសត្វមាន់-ទា និងផលិតផលមាន់-ទា ជួយបង្ការការឆ្លងរាលដាលជំងឺផ្តាសាយបក្សី និងបង្ការសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួន។
- ជំងឺផ្តាសាយបក្សីអាចឆ្លងរាលដាលទៅតំបន់ថ្មីតាមរយៈមនុស្សម្នាក់ដែលទៅកសិដ្ឋានដែលកើតមានជំងឺ ហើយបន្ទាប់មកចំលងជំងឺនេះទៅកសិដ្ឋានថ្មីទៀត តាមរយៈស្បែកជើង ទ្រុងកខ្វក់ និងកង់ឡាន ឬ កង់ម៉ូតូ ដែលជាប់លាមកដែលមានផ្ទុកមេរោគ។
- មិនត្រូវលក់មាន់-ទាដែលឈឺ ឬងាប់ឡើយ
- មិនត្រូវធ្វើអាជីវកម្មមាន់-ទាពីប្រភពមិនច្បាស់លាស់ (អាជីវកម្មសត្វមាន់-ទាដែលមានអាជ្ញាប័ណ្ណ/ពីប្រភពដែលអាចទុកចិត្តបាន)។

## Bird markets are risky places

- Poultry, their products and the objects which they have contaminated, especially cages can be a source of the infected virus.
- Do not touch feathers or liquid wastes (stool, urine, blood and nasal fluids) without gloves (or plastic bags) and masks or kramas.
- Wash your hands before and after handling poultry or poultry products.

## For people who sell poultry or poultry products

- Commercial movement of infected poultry or poultry products is one of the main ways of spreading avian influenza.
- Traders who respect laws on the movement of poultry and poultry products help prevent the spread of avian influenza and protect their own economic activity.
- Avian influenza can be spread to a new area by someone visiting an infected farm and then passing on the disease to others through infected droppings on shoes, dirty cages and wheels (of bicycles, cars, etc.).
- Do not sell dead or sick poultry.
- Do not trade birds of unknown origin (only trade birds that are certificated/ from a trusted source).

## តើខ្ញុំគួរប្រាប់អ្វីខ្លះដល់អ្នកដែលមានមាន់-ទាឈឺនៅក្នុងកសិដ្ឋាន ឬនៅជុំវិញកសិដ្ឋានរបស់ពួកគេ?

វាជាការលំបាកក្នុងការប្រាប់ថាតើមាន់-ទាមានជំងឺផ្ដាសាយបក្សី ឬជំងឺផ្សេងទៀត។ បុគ្គលិកដែលបានទទួលបានការបណ្ដុះបណ្ដាល អាចកំណត់ថាតើមាន់-ទាដែលឈឺនោះបណ្ដាលមកពីអ្វី។ ត្រូវសុំឱ្យពួកគាត់ជួយ។

ប្រការនេះអាចជួយសង្គ្រោះជីវិតមាន់-ទា ព្រមទាំងក្រុមគ្រួសាររបស់អ្នក និងមនុស្សផ្សេងៗទៀតនៅក្នុងសហគមន៍នោះផងដែរ។

១. សូមរាយការណ៍ជាបន្ទាន់អំពីមាន់-ទាដែលឈឺ។ អាជ្ញាធរមានសមត្ថកិច្ចនឹងបញ្ជូនក្រុមអ្នកស៊ើបអង្កេតភ្លាម

២. ទុកដាក់មាន់-ទាដែលឈឺឱ្យនៅដាច់ពីគេ : យ៉ាងតិចក្នុងចំងាយបីម៉ែត្រពីមាន់-ទាដែលមានសុខភាពល្អ និងដាក់ឱ្យនៅឆ្ងាយពីមនុស្សនិងសត្វផ្សេងៗទៀត

៣. នៅឱ្យឆ្ងាយពីមាន់-ទាដែលឈឺ រហូតដល់ក្រុមអ្នកស៊ើបអង្កេតមកដល់។ ឱ្យកុមារនិងស្ត្រីមានផ្ទៃពោះនៅឆ្ងាយពីមាន់-ទាដែលឈឺ ។ កុំអោយកុមារលេងជាមួយមាន់-ទាដែលឈឺ

៤. សូមពាក់សំភារៈការពារពេលនៅក្បែរមាន់-ទា : ស្រោមដៃ ម៉ាស់ ឬក្រមា វ៉ែនតាការពារភ្នែក ស្បែកជើងកវែង។ លាងសំអាតដៃ ខ្លួនប្រាណ និងសំភារៈការពារជាមួយសាប៊ូបន្ទាប់ពីនៅក្បែរមាន់-ទា។

៥. សូមកុំរៀបចំធ្វើមាន់-ទាដែលឈឺសំរាប់ទទួលទានអោយសោះ

៦. សូមកុំអញ្ជើញភ្ញៀវមកលេងកសិដ្ឋាន : ពួកគេអាចនាំយកវីរុសនេះមកជាមួយ។

## What should I tell someone who has sick poultry on or around their farm?

It is hard to tell whether birds are sick with Avian Influenza or another disease. There are trained people who can determine what is wrong. Ask them for help!

This can save lives of poultry and also your family and other people in the community.

1. Report sick birds immediately. The authorities will send an investigation team.
2. Keep sick poultry isolated: at least 3 meters from healthy birds and away from humans and other animals.
3. Stay away from sick poultry until the investigation team arrives. Keep children and pregnant women away from sick poultry. Do not let children play with sick birds.
4. Wear protective clothing when around the poultry - gloves, mask or krama, goggles, boots. Wash hands, body and clothing with soap after being around poultry.
5. Do not prepare or eat sick poultry.
6. Do not invite visitors to the farm; they might take the virus with them.



MAFF hotline

**រាយការណ៍ជាបន្ទាន់**

**Report Immediately**

មជ្ឈមណ្ឌលជាតិស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល

**012 833 795    012 214 970**

## នៅពេលមានមាន់-ទាងាប់

សូមរាយការណ៍ជាបន្ទាន់ ប្រសិនបើអ្នកអង្កេតឃើញ ៖

- អត្រាងាប់ខ្ពស់ ៖ មាន់-ទាងាប់ច្រើន
- អត្រាងាប់ស្រួចស្រាវ ៖ មាន់-ទាងាប់ភ្លាមៗក្នុងរយៈពេលមិនដល់មួយថ្ងៃ
- អត្រាងាប់កើនឡើង ៖ ចំនួនមាន់-ទាដែលងាប់កើនឡើងរៀងរាល់ថ្ងៃ
- អត្រាងាប់រីករាលដាល ៖ មាន់-ទានៅផ្ទះអ្នកជិតខាងក៏ងាប់នៅពេលជាមួយគ្នានោះ

ដើម្បីបញ្ជាក់ថាតើមាន់-ទានោះកំពុងងាប់ដោយសារជំងឺផ្តាសាយបក្សីមែនដែរឬទេ ត្រូវតែធ្វើការស៊ើបអង្កេត ។

ប្រសិនបើការធ្វើតេស្តលើមាន់-ទានោះបង្ហាញថាមានវីរុសជំងឺផ្តាសាយបក្សី មាន់-ទាដែលងាប់នោះត្រូវកប់ចោលឱ្យបានត្រឹមត្រូវដើម្បីការពារមាន់-ទាដែលមានសុខភាពល្អផ្សេងទៀត និងមនុស្ស ។ ក្រុមអ្នកស៊ើបអង្កេតនឹងផ្តល់ដំបូន្មាន និងព័ត៌មានបន្ថែមទៀតអំពីការកប់ ការសំអាតនិងការបាញ់ថ្នាំសំលាប់មេរោគ ។

- សូមកុំយកមាន់-ទាដែលងាប់ទៅឱ្យសត្វផ្សេងទៀតស៊ីអោយសោះ (វាអាចចំលងដល់សត្វដទៃទៀត)
- សូមកុំចោលមាន់-ទាដែលងាប់ទៅក្នុងទន្លេ ឬស្រះត្រពាំង ឬទុកចោលនៅកន្លែងណាមួយនៅក្នុងភូមិ ឬគ្រាន់តែកប់ស៊េរៗតែប៉ុណ្ណោះ ។ រាល់ខ្មោចមាន់-ទាដែលងាប់ទាំងនេះត្រូវបានដុតចោល ឬដាក់ក្នុងស្បោងមួយ ហើយកប់ក្នុងជំរៅយ៉ាងតិច៦០សង់ទីម៉ែត្រ ដើម្បីការពារមិនឱ្យសត្វផ្សេងទៀតអាចកាយវាចេញបាន ។

សូមកុំរៀបចំធ្វើមាន់-ទាដែលងាប់សំរាប់ទទួលទានឱ្យសោះ ហើយពុំត្រូវលក់វាទៅឱ្យអ្នកដទៃទៀតឡើយ ។

សូមការពារខ្លួនអ្នកនិងក្រុមគ្រួសាររបស់អ្នក ដោយធានាថាគ្មាននរណាម្នាក់ (ជាពិសេសកុមារ) ប៉ះពាល់មាន់-ទាដែលឈឺ ឬងាប់ឡើយ ។ សូមពាក់សំភារៈការពារដើម្បីការពារស្បែក ច្រមុះ និងមាត់របស់អ្នក ។ សូមពាក់ស្រោមដៃ/ស្បោងប្លាស្ទិកនៅដៃរបស់អ្នក និងពាក់ម៉ាស់/ក្រមាលើមុខ ។ សូមលាងសំអាតខ្លួនអ្នក សំភារៈការពារ និងឧបករណ៍ដែលបានប៉ះពាល់មាន់-ទានោះ ។

**សូមលាងសំអាតដៃជាមួយសាប៊ូ (ឬផេះ) ជានិច្ចនៅមុនពេលនិងក្រោយពេលចាប់កាន់មាន់-ទាណាមួយ**

**នៅពេលអ្នកប៉ះពាល់មាន់-ទា ឬផលិតផលមាន់-ទា សូមយល់ដឹងអំពីវិធីការពារខ្លួនអ្នក និងមាន់-ទារបស់អ្នកជានិច្ច ។**



- វីរុសនេះអាច "ធ្វើដំណើរ" តាមរយៈមនុស្សណាម្នាក់ដើម្បីចំលងដល់មាន់-ទាផ្សេងទៀត ។
- សាប៊ូឬផេះអាចសំលាប់វីរុសនេះ ហើយវាអាចបង្ការការចំលងដោយចៃដន្យពីមនុស្សទៅមាន់-ទាផ្សេងទៀត ។
- សូមជួយកុមារក្នុងការលាងដៃរបស់ពួកគេឱ្យបានស្អាតល្អនិងជាទៀងទាត់ ។

## When there are dead poultry

Report immediately if you notice:

- High mortality - many poultry die
- Acute mortality - poultry die suddenly, in less than one day
- Increasing mortality - every day more poultry die
- *Spreading mortality - poultry die in neighboring houses in the same period of time*

To confirm whether the poultry is dying from avian influenza, an investigation will be conducted.

If poultry tests positive for avian influenza the dead birds need to be disposed of correctly to protect other healthly poultry and people. **The investigation team will provide more advise and information about disposal, cleaning and disinfection.**

- Dead birds should NOT be fed to other animals (they could infect other animals).
- Dead birds should NOT be thrown in a river or pond, left in a yard or just buried. *It is important that dead birds are burned or placed in a bag and buried at least 60cm deep, protected from other animals that might dig them up.*

**Do not prepare any dead poultry for eating, and do not sell it to other people.**

Protect yourself and your family by making sure that no one touches sick or dead poultry (especially not children). Wear clothing that protects; cover your skin, nose and mouth. Wear gloves/plastic bag on the hands and a mask/krama on the face. Wash yourself and your clothing/equipment that has touched the poultry.

## Always wash hands with soap (or ash) before and after handling any poultry.

**When you touch poultry or poultry products, always be aware of protecting yourself and your poultry.**

- The virus can "travel" via a person to infect another chicken or duck.
- Soap and ash kills the virus and prevents accidental infection from the person to other poultry.
- Help children to wash their hands thoroughly and regularly.



# ការបង្ការជំងឺផ្តាសាយបក្សីនៅលើមនុស្ស
# Prevention of Avian Influenza in Humans

វីរុសជំងឺផ្តាសាយបក្សី ជាធម្មតាឆ្លងតែចំពោះសត្វប៉ុណ្ណោះ ។ វានៅតែជាជំងឺដ៏ធ្ងន់ធ្ងររបស់សត្វ ហើយវាកម្រឆ្លងមកមនុស្សណាស់ ។ ទោះបីយ៉ាងណាក្តី វីរុសជំងឺផ្តាសាយមិននៅស្ងៀមឡើយ វាបំលែងខ្លួនជាប្រចាំ ដូច្នេះវាជាការសំខាន់ដែលយើងត្រូវផ្លាស់ប្តូរទំលាប់របស់យើង ដើម្បីខិតខំការពារបសុបក្សី និងមនុស្ស ។

ឱកាសដែលវីរុសជំងឺផ្តាសាយរាតត្បាតជាសកលអាចកើតឡើង គឺអាស្រ័យលើឱកាសដែលមនុស្សយើងប្រឈមមុខនឹងគ្រោះថ្នាក់ និងការបង្ករោគ ។ ឱកាសនេះនឹងនៅតែមាន បើវីរុសជំងឺផ្តាសាយបក្សី នៅតែបន្តឆ្លងរាលដាលក្នុងចំណោមសត្វនានា ។

ការគ្រប់គ្រងជំងឺផ្តាសាយបក្សីលើសត្វនានា គឺជាមធ្យោបាយដ៏សំខាន់ក្នុងការកាត់បន្ថយឱកាសចំលងមកមនុស្ស និងកាត់បន្ថយឱកាសនៃការកើតឡើងនៃវីរុសជំងឺផ្តាសាយឆ្លងរាតត្បាតជាសកល ។

ការបង្ការការប្រព្រឹត្តដែលនាំឱ្យមនុស្សប្រឈមមុខនឹងវីរុសនេះ គឺជាមធ្យោបាយសំខាន់ទីពីរ ។

ការប្រព្រឹត្តដ៏សំខាន់មួយក្នុងការបង្ការការចំលងជំងឺផ្តាសាយបក្សីទៅមនុស្សគឺ:

**សូមលាងសំអាតដៃជាមួយទឹក និងសាប៊ូ ឬផេះ មុន និងក្រោយចាប់កាន់មាន់-ទា ។**

*សាប៊ូនិងផេះអាចកំចាត់វីរុសនេះពីដៃបាន ។*

**Avian influenza viruses normally only infect animals. It is still very much an animal disease, and it is rare for humans to become infected. However, the influenza virus is unstable and changing constantly, so it is important that we change our habits to try and protect our poultry and people.**

The risk that a pandemic virus will emerge depends on opportunities for human exposure and infections. These opportunities will persist as long as the avian influenza virus continues to circulate in animals.

Control of the disease in animals is the principal way to reduce opportunities for human infection and thus reduce opportunities for a pandemic virus to emerge.

Prevention of behaviors that expose humans to the virus is a second way.

An important behaviour to prevent the transmission of avian influenza to humans is to:

**Always wash hands with water and soap or ash before and after handling any poultry.**

*Soap and ash remove the virus from hands.*

# ការបង្ការការប្រព្រឹត្តដែលនាំឱ្យមនុស្សប្រឈមមុខនឹងវីរុសផ្តាសាយបក្សី

# Prevention of behavior that exposes humans to the avian influenza virus

## កាត់បន្ថយជាអតិបរមាក្នុងការមានទំនាក់ទំនងជាមួយសត្វបក្សីគ្រប់ប្រភេទ ជៀសវាងរាល់ទំនាក់ទំនងដែលមិនចាំបាច់ណាំងអស់ជាមួយសត្វបក្សី

- សូមដាក់មាន់-ទាឱ្យនៅឆ្ងាយពីមនុស្ស
- សូមឱ្យកុមារនិងស្ត្រីមានផ្ទៃពោះនៅឱ្យឆ្ងាយពីមាន់-ទា
- សូមកុំឱ្យមាន់-ទាចូល ឬរស់នៅក្នុងផ្ទះ

*សូមជៀសវាងការមានទំនាក់ទំនងជាមួយបក្សីព្រៃ៖ ការទិញនិងការលែងសត្វបក្សីដើម្បីជាបុណ្យកុសល អាចជាការប្រឈមមុខនឹងគ្រោះ។ គ្មាននរណាម្នាក់អាចដឹងថាតើបក្សីព្រៃណាមានផ្ទុកវីរុសជំងឺផ្តាសាយបក្សី នោះទេ។*

## Minimize contact with all birds. Avoid all unnecessary contact with poultry.

- Keep poultry and humans separated.
- Keep children and pregnant women away from poultry.
- Do not let poultry enter or live in the house.

*Avoid contact with wild birds - Buying and releasing birds as a good deed is risky - no one knows which wild birds are infected with the avian influenza virus.*



ការមានទំនាក់ទំនងដោយផ្ទាល់ជាមួយសារធាតុរាវ អិលដែលបញ្ចេញពីរាងកាយ និងលាមកមាន់-ទា ដែលមានជំងឺ គឺជាប្រភពដ៏សំខាន់ក្នុងការចំលង ជំងឺផ្តាសាយបក្សីពីមាន់-ទាទៅមនុស្ស។

Direct contact with body fluids and feces of infected poultry is the main source of transmission of avian influenza from birds to humans.

## ប្រសិនបើអ្នកចាំបាច់ត្រូវប៉ះពាល់មាន់-ទាដោយហេតុផលណាមួយ

### សូមពាក់សំភារៈការពារ :

- គ្របការពារច្រមុះ និងមាត់ (ម៉ាស់/ក្រមា) - ដើម្បីជៀសវាងការដកដង្ហើមស្រូបចូលដំណក់តូចៗ នៃសារធាតុរំអិលដែលបញ្ចេញពីរាងកាយមាន់-ទា ឬធូលីដែលមានលាមករបស់វា។ ដំណក់ទឹកទាំងនេះមានលក្ខណៈតូចបំផុត មិនអាចមើលឃើញ ហើយអាចមានផ្ទុកវីរុសជំងឺផ្តាសាយបក្សី។
- ពាក់/គ្របដៃ (ស្រោមដៃ/ស្បោងប្លាស្ទិក)។

*នៅពេលបញ្ចប់ការងារ សូមបាញ់ថ្នាំសំលាប់មេរោគនៅលើសំភារៈការពារ ឬលាងជាមួយទឹក និងសាប៊ូ ហើយលាងសំអាតដៃ ខ្លួនប្រាណ និងសំលៀកបំពាក់របស់អ្នក។ កុំភ្លេចលាងសំអាតបាតស្បែកជើងកវែង ឬស្បែកជើងរបស់អ្នក។*

## If you need to touch any birds for any reason,

### wear protective clothing:

- Cover nose and mouth (mask/krama) – avoid inhaling droplets of poultry body fluid or the dust from the feces of poultry. The droplets are very small and often invisible and may contain the avian influenza virus.
- Cover hands (gloves/plastic bags)

*When finished, disinfect or wash with water and soap the protective clothing and wash your hands, body and clothes. Don't forget to wash the bottom of your boots or shoes!*



ការប្រើសំភារៈការពារ - ម៉ាស់ ឬក្រមា ស្រោមដៃ និងស្បែកជើងកវែង

Protective clothing - mask/krama, gloves, boots

## ចូរនៅឱ្យឆ្ងាយពីមាន់_ទាដែលឈឺ ឬងាប់:

- សូមកុំប៉ះពាល់មាន់-ទាដែលឈឺ ឬងាប់ឱ្យសោះ: សូមរាយការណ៍ជាបន្ទាន់ ហើយរង់ចាំទទួលដំបូន្មានពីអាជ្ញាធរមានសមត្ថកិច្ច ។
- សូមកុំឱ្យកុមារលេងជាមួយ ឬចាប់មាន់-ទាដែលឈឺ ឬងាប់ឱ្យសោះ ។
- សូមកុំបោចរោម/ស្លាប សំលាប់ រៀបចំធ្វើ ឬហូបមាន់-ទាដែលឈឺ ឬងាប់ឱ្យសោះ : ប្រការនេះត្រូវបានគេគិតថាជាការប្រព្រឹត្តដែលមានគ្រោះថ្នាក់បំផុតក្នុងការឆ្លងជំងឺ ។

## Stay away from sick or dead birds:

- Do not touch sick or dead birds – report immediately and wait for advice from the authorities.
- Do not let children play with or catch sick or dead birds.
- Do not pluck, slaughter, prepare or eat sick or dead poultry - this is thought to be the most dangerous behavior for becoming infected.

បើមានមាន់-ទាឈឺ ឬងាប់
Sick or dead birds



**រាយការណ៍ជាបន្ទាន់**
**Report Immediately**
មជ្ឈមណ្ឌលជាតិស្រាវជ្រាវ ផលិតកម្ម និងបសុព្យាបាល
MAFF hotline **012 833 795** **012 214 970**

ប្រសិនបើមនុស្សណាម្នាក់មានរោគសញ្ញាជំងឺផ្តាសាយ ហើយបាននៅជិតមាន់-ទាដែលឈឺ ឬងាប់ ឬនៅជិតអ្នកជំងឺដែលមានជំងឺស្រដៀងនឹងជំងឺផ្តាសាយ – សូមជៀសវាងការមានទំនាក់ទំនងជិតស្និទ្ធ (ដូចជាការថើប ឬការឱប) និងត្រូវ**រាយការណ៍ជាបន្ទាន់** ។

If a person has signs or symptoms of influenza, and has been near sick or dead poultry or a patient with influenza-like illness - avoid close contact (such as kissing or hugging) and **report immediately**.



**រាយការណ៍ជាបន្ទាន់**
**Report Immediately**
សូមអ្នកទាក់ទងមកក្រសួងសុខាភិបាល
MOH hotline **012 488 981** **012 836 868**

## ជៀសវាងបរិស្ថានដែលប្រឈមមុខនឹងគ្រោះថ្នាក់៖

- សូមថែរក្សាទីធ្លាជុំវិញផ្ទះឱ្យបានស្អាត និងគ្មានលាមកសត្វ។ សូមធ្វើរបងព័ទ្ធជុំវិញទីធ្លាដែលមាន់-ទារស់នៅ និងថែរក្សាទីធ្លានោះឱ្យស្អាត ។
- សូមជៀសវាងប្រើប្រាស់ទឹកដែលសត្វបក្សីព្រៃ ឬបសុបក្សីបានប្រើប្រាស់ ។ ទឹកនោះអាចមានមេរោគដោយសារសាកសពបក្សីងាប់ ឬលាមកដែលមានមេរោគ ។
- សូមកុំហូបទឹកឆៅដែលបានមកពីស្រះត្រពាំង/អណ្តូងដែលបក្សីធ្លាប់នៅទីនោះ ។
- សូមកុំងូតទឹក ឬហែលក្នុងទឹកដែលបក្សីព្រៃ ឬទាបានប្រើប្រាស់ឱ្យសោះ ។

## Avoid risky environments:

- Keep the area around the house clean and free of bird and poultry feces. Keep the area where poultry live fenced and clean.
- Avoid water used by wild birds or poultry. The water could be contaminated by the carcasses of dead birds or infected feces.
- Do not drink unboiled water from ponds/wells where birds have been.
- Do not swim or bathe in water used by wild birds or ducks.



## រោមនិងស៊ុតមាន់_ទា

- សូមលាងសំអាតដៃរបស់អ្នកជានិច្ចជាមួយទឹកនិងសាប៊ូឬផេះ នៅមុននិងក្រោយពេលប៉ះពាល់រោម ឬស៊ុតមាន់-ទា។
- អ្នកគប្បីពាក់ស្រោមដៃ ឬស្បោងប្លាស្ទិក នៅដៃរបស់អ្នកនៅពេលដើររើសស៊ុត ឬរោមសត្វ ឬមាន់។
- បើរោម ឬស៊ុតមាន់-ទាមានជាប់វីរុសជំងឺផ្ដាសាយបក្សី វីរុសនេះអាចឆ្លង"ធ្វើដំណើរ" ទៅលើដៃ ក្រោយពីបានប៉ះពាល់រើសរោម ឬស៊ុតមាន់-ទាដែលមានជំងឺនោះរួចមក។ បន្ទាប់មក ដៃដែលបានប្រឡាក់វីរុសនោះ អាចចំលងដល់បសុបក្សីដែលមានសុខភាពល្អ ដោយការប៉ះពាល់ពួកវា។

## Feathers and eggs

Always wash your hands with water and soap or ash before and after collecting feathers or eggs.

It is better to pick up eggs/feathers or chickens with gloves or a plastic bag around hands.

If feathers or eggs have the virus on them it is possible for the virus to "travel" to hands or gloves after picking up the infected feathers or eggs. The infected hands/gloves can then infect healthy poultry by touching them.





ការលេងជំពាមបាញ់សត្វបក្សី ជាសកម្មភាព
ដែលប្រឈមមុខនឹងគ្រោះថ្នាក់ ដូច្នេះត្រូវ លាងសំអាតដៃជានិច្ច
ដើម្បីការពារខ្លួនអ្នកពី
ការឆ្លងមេរោគដោយការប៉ះពាល់
ឬបោច រោមសត្វបក្សី។



Playing with a catapult (slingshot) is risky, so always wash hands before and after, and protect yourself from the virus when collecting or plucking the bird.



## ការងារដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់

មនុស្សដែលងាយរងគ្រោះបំផុត គឺអ្នកដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយមាន់-ទា ដូចជា អ្នកចិញ្ចឹម អ្នកលក់ អ្នកដឹកជញ្ជូន អ្នកដែលមានអាជីពសំលាប់សត្វ អ្នកលក់សាច់ និងអ្នកចំអិន។

មនុស្សដែលមានការងារប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ អាចអនុវត្តវិធានការជាមូលដ្ឋានមួយចំនួន ដើម្បីការពារខ្លួន :

- ពាក់ម៉ាស់/ក្រមា ស្បែកជើងកវែង និងស្រោមដៃជានិច្ចនៅពេល :
  - ចូលនិងចេញពីកសិដ្ឋានចិញ្ចឹមមាន់-ទា
  - ដឹកជញ្ជូនផលិតផលមាន់-ទាតាមឡាន ឬម៉ូតូ ឬយានជំនិះផ្សេងទៀត
  - រៀបចំធ្វើ ឬសំលាប់មាន់-ទានៅតាមទីផ្សារ ឬទីសាធារណៈដោយរួមទាំងនៅផ្ទះរបស់អ្នកផងដែរ
- នៅពេលបញ្ចប់ការងារ ត្រូវលាងសំអាតខ្លួន និងដៃជាបន្ទាន់ ជាមួយសាប៊ូ ឬផេះ។
- រាល់ឧបករណ៍សំភារៈការពារខ្លួនទាំងអស់ត្រូវដាក់ត្រាំក្នុងទឹក ហើយលាងសំអាតដោយសាប៊ូ និងបន្ទាប់មកត្រូវហាលឱ្យស្ងួតល្អ។
- ទីផ្សារដែលលក់មាន់-ទារស់ អាចប្រឡាក់ជាប់មេរោគ។ សូមប្រុងប្រយ័ត្ន និងការពារខ្លួនអ្នកនៅតាមផ្សារ។ សូមលាងសំអាតដៃជាមួយសាប៊ូ ឬផេះ នៅក្រោយពេលចាកចេញពីផ្សារ។

## High risk occupations

The most vulnerable people are those in close contact with poultry, such as raisers, sellers, transporters, cullers, butchers and cooks.

People with high risk occupations can implement basic measures to protect themselves:

- Always wear masks/krama, boots and gloves when:
  - Entering and exiting poultry farms
  - Transporting poultry products by car or motorbike or other vehicle
  - Processing or killing poultry either in market places or public places, including your home.
- When finished, immediately wash hands and clean body with soap or ash.
- All other personal protective equipment should be put in water and washed with soap and then dried properly.
- Markets where live birds are sold could be contaminated. Take care and protect yourselves at markets. Wash hands with soap and ash after leaving markets.

### ចំពោះអ្នកសំលាប់មាន់-ទា៖

- សូមពាក់សំភារៈការពារ
- សូមប្រយ័ត្ន និងកាត់បន្ថយការមានទំនាក់ទំនងជាមួយរោមមាន់-ទា ឈាម ពោះវៀន ។ល។
- សូមលាងសំអាតដៃឱ្យបានស្អាតល្អជាមួយសាប៊ូ ឬផេះនៅមុន និងនៅក្រោយពីសំលាប់មាន់ទា ។
- សូមចោលកាកសំណល់ដោយប្រុងប្រយ័ត្ន ដោយការដុតចោល ឬកប់ឱ្យជ្រៅ ។
- មិនត្រូវឱ្យឆ្កែ ឬសត្វដទៃទៀតមកជិតកាកសំណល់នោះឡើយ ។
- សំអាតកន្លែងសំលាប់ឱ្យបានស្អាត ។ ប្រមូលរាល់កំទេចកម្ទីទាំងអស់ដោយពាក់ស្រោមដៃ ។
- សូមប្រើសាប៊ូ ឬផេះដើម្បីលាងសំអាត និងសំលាប់មេរោគនៅកន្លែងនោះ ។

### For people who cull (kill) poultry:

- Wear protective clothing
- Be very careful and minimize contact with feathers, blood, intestines, etc.
- Wash hands thoroughly with soap or ash before and after culling
- Dispose of any leftovers with care by burning or deep burying
- Do not allow dogs or other animals to come into close contact with leftovers
- Clean the culling place thoroughly - pick up all the pieces with gloved hands.
- Use soap or ash to clean and disinfect the area.



# ការរៀបចំធ្វើ និងការបរិភោគមាន់-ទា និងផលិតផលមាន់-ទា

# Preparing and eating poultry and poultry products

ក្នុងពេលរៀបចំធ្វើមាន់-ទា មានបំណែកតូចៗជាច្រើននៃសារធាតុរំអិលដែលបញ្ចេញពីរាងកាយ ឬលាមករបស់មាន់-ទានោះ ស្ថិតនៅក្នុងខ្យល់ ដែលធ្វើឱ្យងាយស្រួលក្នុងការដកដង្ហើមស្រូបចូល ឬប៉ះជាប់ទៅលើសំលៀកបំពាក់និងខ្លួនប្រាណយើង។ ស៊ុតនិងសំបកស៊ុតមាន់-ទា ក៏អាចមានផ្ទុកវីរុសនេះដែរ។ នៅពេលរៀបចំធ្វើមាន់-ទាដើម្បីចំអិនជាអាហារ សូមពាក់សំភារៈការពារ។

ការហូបផលិតផលមាន់-ទា ដែលចំអិនឆ្អិនល្អ ពុំមានគ្រោះថ្នាក់ឡើយ ប៉ុន្តែទាំងសាច់និងស៊ុតត្រូវតែចំអិនឱ្យឆ្អិនល្អ ដូច្នេះវាពុំមានទឹក ឬកន្លែងដែលនៅឆៅដែលអាចមានវីរុសនេះឡើយ។ រហូតមកដល់បច្ចុប្បន្ននេះ ពុំទាន់មានករណីជំងឺផ្តាសាយបក្សីដែលកើតឡើងដោយសារតែការបរិភោគអាហារឆ្អិនល្អឡើយ។

During preparation of poultry, many small drops of poultry body fluid or feces from the poultry will be in the air, making it easy to inhale or to get on clothes and the body. Eggs and egg shells could also contain the virus. When preparing poultry for cooking, wear protective clothing.

There is no risk in eating well-cooked poultry products, but both meat and eggs should be cooked thoroughly so there are no juices or raw parts in the food which could contain the virus. To date, no case of avian influenza is know to have occurred by eating well-cooked food. However, in a few instances, cases have been linked to eating dishes made of raw contaminated poultry blood.



ការហូបសាច់មាន់-ទា ដែលចំអិនល្អ ពុំមានគ្រោះថ្នាក់ឡើយ ប៉ុន្តែមិនត្រូវហូបមាន់-ទាដែលឈឺ ឬងាប់ឡើយ
It is safe to eat well-cooked poultry, but do not eat sick or dead poultry.

## សូមអនុវត្តតាមវិធីសាមញ្ញៗដើម្បីរៀបចំ និងចំអិនសាច់មាន់ទាឲ្យគួបដោយសុវត្ថិភាព

### ១. អនុវត្តអនាម័យល្អ

- សូមលាងសំអាតដៃរបស់អ្នកជាញឹកញាប់នៅពេលអ្នករៀបចំធ្វើអាហារ ដោយប្រើផេះ ឬសាប៊ូនិងទឹក។ ត្រូវប្រុងប្រយ័ត្នក្នុងការលាងសំអាតដៃរបស់អ្នក នៅក្នុងចន្លោះពេលចាប់កាន់ម្ហូបអាហារឆៅ និងម្ហូបអាហារឆ្អិន ហើយនៅមុន និងក្រោយពីចាប់កាន់មាន់-ទា ឬស៊ុតឆៅ។
- សូមលាងសំអាតកន្លែង និងរាល់សំភារៈទាំងអស់ឱ្យបានស្អាតដោយប្រើផេះ ឬសាប៊ូនិងទឹក។

### ២. ទុកដាក់ម្ហូបអាហារឆៅ និងឆ្អិនឱ្យនៅដាច់ពីគ្នា

ប្រការនេះគឺដើម្បីបង្ការមិនឱ្យវីរុសនេះ "ធ្វើដំណើរ" ពីអាហារឆៅដែលមានផ្ទុកមេរោគទៅដល់អាហារផ្សេងទៀត

- ទុកដាក់សាច់មាន់-ទា និងស៊ុតឆៅឱ្យនៅដាច់ពីម្ហូបអាហារដទៃទៀត។
- កុំប្រើប្រាស់ជ្រុញ ឬកាំបិតដដែល សំរាប់រៀបចំធ្វើសាច់ឆៅ និងអាហារឆ្អិនឬអាហារត្រៀមទុកសំរាប់ហូប។ ត្រូវលាងសំអាតជ្រុញ និងកាំបិតរបស់អ្នកក្នុងចន្លោះពេលកាត់/កាប់សាច់ឆៅ និងអាហារឆ្អិន ឬអាហារត្រៀមទុកសំរាប់ហូប។
- កុំដាក់សាច់ដែលចំអិនរួចនៅលើចានដែលបានប្រើដើម្បីដាក់សាច់ឆៅមុនពេលចំអិនអាហារ ព្រោះបើមានជាប់មេរោគ មេរោគនោះនឹងនៅ ទីនោះ ដដែល។



## Follow these simple steps to prepare and cook poultry safely

### 1. Practice good hygiene

- Wash your hands frequently as you prepare foods, using ash or soap and water. Be careful to wash your hands in between handling raw and cooked foods and before and after handling raw poultry or eggs.
- Wash all surfaces and utensils thoroughly with ash or soap and water.



### 2. Keep raw and cooked foods separated.

This prevents the virus "traveling" from any infected raw food to any other food which could then become infected.

- Keep raw poultry meat and eggs separate from other food items.
- Do not use the same chopping board or the same knife to prepare raw meat and cooked or ready-to-eat foods. Or wash your cutting board and knife between cutting raw meat and cooked and ready-to-eat foods.
- Do not place cooked meat back on the same plate or surface it was on before it was cooked as if there was a virus it will still be there.

### ៣. ចំអិនរាល់ផលិតផលមាន់-ទាទាំងអស់ឱ្យឆ្អិនល្អ

- រាល់ម្ហូបអាហារធ្វើពីមាន់-ទាដោយរួមទាំងស៊ុត និងឈាមរបស់វា ត្រូវចំអិនឱ្យឆ្អិនល្អ ។
- កំដៅភ្លើងសំលាប់វីរុសជំងឺផ្ដាសាយ ។
- ចំអិនមាន់-ទារហូតដល់សាច់ពណ៌ស ។ ពុំត្រូវឱ្យនៅមាន ឈាម ឬកន្លែងដែលនៅឡើយ ។



### ៤. ត្រូវប្រុងប្រយ័ត្នជាពិសេសជាមួយស៊ុត

ស៊ុតដែលបានមកពីតំបន់ដែលកើតមានជំងឺ អាចមានវីរុសនៅផ្ទៃខាងក្រៅ ពីព្រោះតែមានការប្រឡាក់ដី ឬលាមក/ទឹករំអិលផ្សេងៗរបស់មាន់-ទា ។

- វីរុសក៏អាចជ្រាបចូលទៅក្នុងស៊ុតបានផងដែរ ។
- សូមលាងសំអាតដៃជាមួយសាប៊ូ ឬផេះក្រោយពីមានការប៉ះពាល់សាច់និង/ឬស៊ុត ។
- ផ្នែកលឿងនៃស៊ុតត្រូវតែចំអិនឱ្យឆ្អិនល្អរហូតដល់វារឹង (ស៊ុតដែលឆ្អិនល្អ គឺនៅពេលផ្នែកលឿងនៃស៊ុតនោះរឹង) ។ ស៊ុតដែលឆ្អិនល្អគ្មានសារធាតុរំអិលទេ ។
- មិនត្រូវប្រើស៊ុតឆៅដាក់ក្នុងម្ហូបអាហារណាដែលបានចំអិនរួចហើយ (ពុំត្រូវបន្ថែមស៊ុតឆៅ ឬស៊ុតដែលស្ងោរ ហើយនៅទន់ឡើយ ។ ត្រូវធានាថា វាត្រូវបានចំអិនរួចជាមុនសិន ។)
- មិនត្រូវជ្រើសរើសយកស៊ុតបែក ឬប្រឡាក់ដីពីផ្សារឡើយ ។

### 3. Cook all poultry products thoroughly!

- All foods from poultry, including eggs and poultry blood, should be cooked thoroughly.
- Influenza viruses are destroyed by heat.
- Cook chicken until meat is white. No part of the meat should remain pink or bloody.

### 4. Take special precautions with eggs

Eggs obtained from affected areas can have the virus on their surface because of contact with contaminated soil or excretions of poultry. Viruses can also gain entry inside the egg.

- Wash hands with soap or ash after touching meat and/or eggs.
- Egg yolks must be well cooked and solid (eggs are well cooked when the yolk is solid. The egg should not be runny).
- Do not use raw eggs in any food that is already cooked (do not add a raw or soft boiled egg - make sure it is cooked first).
- Do not select cracked or soiled eggs from the market.



### ៥. បន្លែនានាអាចមានការប្រឡាក់ជីអាចម៍សត្វដែលអាចមានវីរុសនេះ

- សូមលាងសំអាតបន្លែឱ្យបានជ្រះល្អជាមួយទឹកស្អាត (ទឹកឆ្អិន)
- បន្ទាប់មក ត្រូវលាងដៃរបស់អ្នកឱ្យបានស្អាត
- ត្រូវចំអិនបន្លែឱ្យឆ្អិនល្អ ទោះបីអ្នកនៅកន្លែងណាក៏ដោយ។

### 5. Vegetables may get contaminated with manure which may contain the virus.

- Wash the vegetables properly, rinse in clean (boiled) water
- Wash your hands thoroughly afterwards
- Wherever possible, cook vegetables properly







ក្នុងពេលរៀបចំធ្វើ ឬចំអិនសាច់ឬស៊ុតមាន់-ទា មិនត្រូវវាសដៃទៅលើច្រមុះ ភ្នែក មាត់ ឬសំភារបរិក្ខារផ្សេងៗទៀតឡើយ (ទូរស័ព្ទដៃ ។ល។) នៅពេលដែលអ្នកមិនទាន់បានលាងសំអាតដៃរបស់អ្នកជាមួយសាប៊ូ ឬផេះរួចនោះ។

សូមលាងសំអាតដៃរបស់អ្នកជានិច្ចជាមួយសាប៊ូ ឬផេះនៅក្នុងចន្លោះពេលចាប់កាន់ម្ហូបអាហារឆៅ និងម្ហូបអាហារឆ្អិន ហើយនៅមុននិងក្រោយពេលចាប់កាន់មាន់-ទា ឬស៊ុតឆៅ។

While preparing or cooking poultry meat or eggs, do not touch your nose, eyes, mouth or other equipment (hand phone etc) until after washing your hands with soap or ash.

Always wash your hands with water soap or ash in between handling raw and cooked foods and before and after handling raw poultry or eggs.



# ការយល់ដឹងនូវចំនុច៥ ប្រការដើម្បីសុវត្ថិភាព



## ស្អាតជានិច្ច

- ☑ លាងដៃរបស់អ្នក មុននឹងកាន់ម្ហូបអាហារ និងពេលរៀបចំអាហារ
- ☑ លាងដៃរបស់អ្នកក្រោយពីចេញពីបន្ទប់ទឹក
- ☑ លាង និង ធ្វើអនាម័យសំភារៈ និងឧបករណ៍ដែលប្រើប្រាស់សំរាប់រៀបចំម្ហូបអាហារ ( តុ ជ្រុញ )
- ☑ ការពារផ្ទះបាយ និងអាហារពីសត្វល្អិត សត្វចង្រៃ និងសត្វផ្សេងៗទៀត ។

**មូលហេតុអ្វី ?**

នៅពេលមេរោគភាគច្រើនពុំបង្កជាជំងឺ មេរោគប្រកបដោយគ្រោះថ្នាក់ ត្រូវបានរកឃើញយ៉ាងទូលំទូលាយនៅក្នុងដី ទឹក សត្វ និងមនុស្ស ។ មេរោគទាំងនេះ នៅនិងដៃ ក្រណាត់ជូត និងគ្រឿងផ្ទះបាយ ជាពិសេស ក្តារជ្រុញ និងការប៉ះពាល់ ទោះតិចតួច អាចចំលងមេរោគទៅអាហារ ។



## ដាក់ដោយឡែកពីគ្នានូវរបស់ឆៅ និងរបស់ឆ្អិន

- ☑ ដាក់សាច់ឆៅ សាច់មាន់- ទា និងគ្រឿងសមុទ្រឱ្យដាច់ពីអាហារផ្សេងៗទៀត ។
- ☑ ប្រើឧបករណ៍ និងប្រដាប់ប្រដាផ្ទះបាយដោយឡែក ដូចជា កាំបិត និង ជ្រុញ សំរាប់តែរៀបចំអាហារមិនទាន់ចំអិន ។
- ☑ ស្តុកអាហារនៅក្នុងរបស់សំរាប់ដាក់ ដើម្បីជៀសវាងការប៉ះពាល់រវាង អាហារមិនទាន់ចំអិន និងចំអិនរួចហើយ ។

**មូលហេតុអ្វី ?**

ចំណីអាហារមិនទាន់ចំអិន ជាពិសេស សាច់បសុបក្សី និងអាហារសមុទ្រ និង ទឹករបស់ វាអាច មានមេរោគដែលបង្កគ្រោះថ្នាក់ ដែលអាចឆ្លងទៅអាហារ ផ្សេងៗទៀត នៅពេលរៀបចំអាហារ និង ការរក្សាទុក ។




## ចំអិនឱ្យបានឆ្អិនល្អ

- ☑ ចំអិនអាហារឱ្យឆ្អិនល្អ ជាពិសេស សាច់បសុបក្សី ( មាន់ ទា ជាដើម ) ស៊ុត និងអាហារសមុទ្រ ។
- ☑ យកអាហារ ដូចជាស៊ុប និងសម្ល មកស្ងោរ ដើម្បីប្រាកដថា វាមាន កំដៅដល់ ៧០ អង្សាសេ ។ សំរាប់សាច់ និងបសុបក្សី ត្រូវប្រាកដថា ទឹកវាថ្លាមិនមែនពណ៌ផ្កាឈូកទេ ។ ជាគោលការណ៍ប្រើសីតុណ្ហមាត្រ ។
- ☑ កំដៅឡើងវិញ នូវអាហារចំអិនហើយ យ៉ាងហ្មត់ចត់ ។

**មូលហេតុអ្វី ?**

ការចំអិនបានសមស្រប សំលាប់មេរោគ ដែលបង្កគ្រោះថ្នាក់ស្ទើរតែទាំងអស់ ។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញ ថា ការចំអិនអាហារនៅកំដៅ ៧០អង្សាសេ អាចជួយធានាថា អាហារ នោះត្រូវបានប្រកបដោយសុវត្ថិភាព ។




## ទុកម្ហូបនៅសីតុណ្ហភាពមួយមានសុវត្ថិភាពត្រឹមត្រូវ

- ☑ កុំទុកចោលអាហារចំអិនរួច នៅសីតុណ្ហភាពក្នុងបន្ទប់ លើសពីពីរម៉ោង ។
- ☑ ទុកក្នុងទូរទឹកកកភ្លាមៗ នូវអាហារចំអិនរួច និងដែលងាយខូច ( ឱ្យពេញចិត្តពីក្រោម ៥អង្សាសេ ) ។
- ☑ កំដៅអាហារចំអិនរួច ឱ្យក្តៅគគុក ( លើសពី ៦០ អង្សាសេ ) មុននឹង បរិភោគ ។
- ☑ កុំទុកដាក់អាហារ យូរពេក ទោះជាក្នុងទូរទឹកកក ក៏ដោយ ។
- ☑ កុំទុកដាក់ឱ្យរលាយនូវអាហារបង្កក នៅសីតុណ្ហភាពបន្ទប់ ។

**មូលហេតុអ្វី ?**

មេរោគអាចកើនចំនួនយ៉ាងលឿន បើទុកដាក់ចំណីអាហារនៅសីតុណ្ហភាពក្នុងបន្ទប់ ។ បើទុកដាក់ ចំណីអាហារនៅ សីតុណ្ហភាពក្រោម ៥អង្សាសេ ឬលើស ពី ៦០អង្សាសេ មេរោគកើនចំនួន យឺត ឬអត់កើនតែម្តង ។



## ប្រើប្រាស់ទឹក និងវត្ថុធាតុដើមដែលមានសុវត្ថិភាព

- ☑ ប្រើប្រាស់ទឹកមានសុវត្ថិភាព ឬធ្វើវាឱ្យមានសុវត្ថិភាព ។
- ☑ ជ្រើសរើសអាហារស្រស់ និងដែលធ្វើឱ្យមានសុខភាពល្អ ។
- ☑ ជ្រើសរើសអាហារដែលកែច្នៃមានសុវត្ថិភាព ដូចជាទឹកដោះគោកំដៅ រំងាប់មេរោគ ។
- ☑ លាងផ្លែឈើ និងបន្លែ ជាពិសេសបើបរិភោគឆៅ ។
- ☑ កុំប្រើអាហារហួសកំណត់កាលបរិច្ឆេទ ។

**មូលហេតុអ្វី ?**

វត្ថុធាតុដើមដែលរួមមាន ទឹក និងទឹកកក អាចឆ្លងមេរោគ និងជាតិពិស ប្រកបដោយគ្រោះថ្នាក់ ។ ជាតិពិសពុលអាចកកើតឡើង នៅក្នុងអាហារដែលខូច និងផ្សិត ។ ការប្រុងប្រយ័ត្នក្នុងការជ្រើសរើសវត្ថុធាតុដើម និងវិធានការសាមញ្ញៗ ដូចជា លាង និង ការចិតសំបកចេញ អាចបន្ថយគ្រោះថ្នាក់ ។

Food Safety
World Health Organization

ចំណេះដឹង = ការការពារ

# 5 keys to safer food



## Keep clean

- Wash your hands before handling food and often during food preparation
- Wash your hands after going to the toilet
- Wash and sanitize all surfaces and equipment used for food preparation
- Protect kitchen areas and food from insects, pests and other animals

**Why?**

While most microorganisms do not cause disease, dangerous microorganisms are widely found in soil, water, animals and people. These microorganisms are carried on hands, wiping cloths and utensils, especially cutting boards and the slightest contact can transfer them to food and cause foodborne diseases.



## Separate raw and cooked

- Separate raw meat, poultry and seafood from other foods
- Use separate equipment and utensils such as knives and cut ting boards for handling raw foods
- Store food in container s to avoid contact between raw and prepared foods

**Why?**

Raw food, especially meat, poultry and seafood, and their juices, can contain dangerous microorganisms which may be transferred onto other foods during food preparation and storage.




## Cook thoroughly

- Cook food thoroughly, especially meat, poultry, eggs and seafood
- Bring foods like soups and stews to boiling to make sure that they have reached 70°C . For meat and poultry, make sure that juices are clear, not pink. Ideally, use a thermometer
- Reheat cooked food thoroughly

**Why?**

Proper cooking kills almost all dangerous micro-organisms. Studies have shown that cooking food to a temperature of 70°C can help ensure it is safe for consumption. Foods that require special attention include minced meats, rolled roasts, large joints of meat and whole poultry.




## Keep food at safe temperatures

- Do not leave cooked food at room temperature for more than 2 hours
- Refrigerate promptly all cooked and perishable food (preferably below 5°C)
- Keep cooked food piping hot (more than 60°C) prior to serving
- Do not store food too long even in the refrigerator
- Do not thaw frozen food at room temperature

**Why?**

Microorganisms can multiply very quickly if food is stored at room temperature. By holding at temperatures below 5°C or above 60°C, the growth of microorganisms is slowed down or stopped. Some dangerous micro-organisms still grow below 5°C.



## Use safe water and raw materials

- Use safe water or treat it to make it safe
- Select fresh and wholesome foods
- Choose foods processed for safety, such as pasteurized milk
- Wash fruits and vegetables, especially if eaten raw
- Do not use food beyond its expiry date

**Why?**

Raw materials, including water and ice, may be contaminated with dangerous microorganisms and chemicals. Toxic chemicals may be formed in damaged and mouldy foods. Care in selection of raw materials and simple measures such as washing and peeling may reduce the risk.

Food Safety
World Health Organization

Knowledge = Prevention

# ការកត់សំគាល់ពិសេសអំពីល្បែងសត្វបក្សី



សត្វបក្សីខ្លះត្រូវបានគេចិញ្ចឹមទុកសំរាប់គោលបំណងជាល្បែង នៅក្នុងប្រទេសជាច្រើន : ការប្រជល់មាន់ ការបរបាញ់សត្វ ការប្រណាំងសត្វព្រាប ។ល។ វាជាការសំខាន់ណាស់ក្នុងការកាត់បន្ថយការមានទំនាក់ទំនងជាមួយ បសុបក្សី ឬបក្សីដទៃទៀតដែលប្រើប្រាស់សំរាប់ជាល្បែង ។

## គោរពតាមអនាម័យនិងសុវត្ថិភាព

- លាងដៃរបស់អ្នកជាមួយទឹកនិងសាប៊ូ ឬផេះ ឱ្យបានស្អាតល្អក្រោយពីចាប់កាន់សត្វបក្សី
- ពាក់សំភារៈការពារនៅពេលចាប់កាន់សត្វបក្សី និងនៅពេលសំអាតកន្លែងទុកសត្វបក្សី
- កុំបណ្តោយឱ្យកុមារចាប់កាន់សត្វបក្សី
- កុំឱ្យកុមារសំអាតកន្លែងទុកសត្វបក្សី

## ប្រុងប្រយ័ត្ននៅពេលសំអាតមាន់ប្រជល់

- ការសំអាតមាន់បន្ទាប់ពីការប្រជល់ អាចមានគ្រោះថ្នាក់ខ្លាំងណាស់ ពោលគឺត្រូវកាត់បន្ថយការប៉ះពាល់ឈាម និងសារធាតុរាវអិលរបស់មាន់នោះ ។
- បន្ទាប់ពីការប្រជល់ មិនត្រូវសំអាតចំពុះមាន់នោះដោយការប្រើមាត់របស់អ្នកបឺតឡើយ ។
- ពាក់សំភារៈការពារនៅពេលចាប់កាន់មាន់ ឬនៅពេលសំអាតកន្លែងប្រជល់មាន់ ។

**មិនត្រូវអនុញ្ញាតឱ្យកុមារចូលរួមក្នុងសកម្មភាពប្រជល់មាន់ឡើយ ។**



## A special note about sporting birds

Birds are kept for sporting purposes in many countries - cock-fighting, falconry, pigeon racing etc. It is very important to minimize contact with poultry and other birds used for sporiting purposes.

**Respect hygiene and safety**

- Wash your hands with water and soap or ash thoroughly after handling birds
- Wear protective clothing when handling birds and cleaning where birds are kept
- Do not let children handle birds
- Do not let children clean the area where the birds are kept

**Take care when cleaning fighting-cocks**

- Cleaning a cock after a fight is very dangerous - minimize contact with the cock's blood and secretions, protect yourself
- After a fight never clean the beak of the cock by sucking with your mouth
- Wear protective clothing when handling birds or cleaning areas where birds have been fighting

**Do not allow children to participate in cock-fighting activities**

## ត្រូវចងចាំ : រយៈពេលសំងំរបស់វីរុសជំងឺផ្តាសាយបក្សី

- មាន់-ទាខ្លះអាចមើលទៅមានសុខភាពល្អ ប៉ុន្តែវាមានផ្ទុកវីរុសនេះ។ មាន់-ទាខ្លះទៀត អាចចំលងវីរុសដោយមើលទៅពុំឃើញថាវាឈឺឡើយ។
- ការប្រឈមមុខ ឬទំនាក់ទំនងជិតស្និទ្ធជាមួយមាន់-ទា អាចឆ្លងរាលដាលវីរុសជំងឺផ្តាសាយបក្សី។
- **សូមដាក់មាន់ប្រជល់ឱ្យនៅដាច់ពីគេ រយៈពេល១៤ ថ្ងៃ នៅពេលយកវាត្រលប់មកផ្ទះវិញ។**

## Remember - there is an incubation period for the avian influenza virus.

- The bird might look healthy, but still have the virus. Some birds can transmit the virus without looking sick.
- Exposure or close contact with birds can spread the avian influenza virus.
- **Keep fighting cocks in quarantine for 14 days when they return to your house.**



## ការកត់សំគាល់ពិសេសអំពីកុមារ

- កុមារមិនត្រូវអនុញ្ញាតឱ្យលេងជាមួយមាន់-ទា ឬនៅកន្លែងដែលមាន់-ទារស់នៅឡើយ ។
- ប្រសិនបើវាជាការងាររបស់ពួកគេក្នុងការថែទាំសត្វមាន់-ទា និងក្នុងការដើររើសស៊ុត ពួកគេគួរយល់ដឹងថា ពួកគេត្រូវតែលាងសំអាតដៃរបស់ខ្លួនជាមួយសាប៊ូ ឬផេះនៅមុននិងក្រោយពេលបញ្ចប់ភារកិច្ចរបស់ខ្លួន ។
- មាន់-ទាអាចមើលទៅហាក់ដូចជាមិនឈឺ ប៉ុន្តែវាអាចមានជំងឺ ដូច្នេះកុមារអាចឆ្លងជំងឺ ឬអាចចំលងវីរុសនេះ ពីមាន់-ទាមួយទៅមាន់-ទាមួយទៀតនៅក្នុងខណៈពេលកំពុងលេងជាមួយវា ។
- កុមារខ្លះចូលចិត្តចាប់មាន់-ទាលេង ។ ប្រការនេះមានគ្រោះថ្នាក់ខ្លាំងណាស់ ។ ជាពិសេសដោយសារមាន់-ទា ដែលឈឺដើរ/រត់យឺត និងងាយស្រួលចាប់ ។
- មិនត្រូវអនុញ្ញាតឱ្យកុមារលេងជាមួយ ឬចាប់មាន់-ទា ឬបសុបក្សីណាមួយឡើយ ។

## A special note about children

- Children should not be allowed to play with poultry or where poultry are living.
- If it is their job to take care of the poultry and collect eggs, then they should understand that they must wash their hands with water and soap or ash before and after they do their duties.
- The birds may not seem like they are sick, but they could be and then the children could get sick or transfer the virus from bird to bird while playing with them.
- Some children like to play with birds and catch chickens. Especially because sick poultry are slower and easier to catch. This is very dangerous!
- Do not let children play with or catch any poultry or wild birds.



# ការបង្ការការឆ្លងជំងឺ
# Infection Control

**ការបង្ការការឆ្លងជំងឺប្រកបដោយប្រសិទ្ធភាព គឺជាការសំខាន់ចំពោះសុខភាពរបស់អ្នកជំងឺ និង ធ្វើឱ្យបរិស្ថាននៅកន្លែងធ្វើការងារមានសុវត្ថិភាព សំរាប់មន្ត្រីសុខាភិបាលផងដែរ ។**

ភ្នាក់ងារចំលងមេរោគជាច្រើន មាននៅតាមកន្លែងថែទាំសុខភាពនានា ។ អ្នកជំងឺអាចឆ្លងមេរោគនៅពេលពួកគេកំពុងទទួលការថែទាំសុខភាព ហើយបុគ្គលិកថែទាំសុខភាពក៏មានការប្រឈមមុខនឹងគ្រោះថ្នាក់ នៅពេលពួកគេកំពុងបំពេញការងាររបស់ខ្លួនដែរ ។ មនុស្សផ្សេងៗទៀតដែលមកកន្លែងថែទាំសុខភាព និងមកធ្វើការនៅកន្លែងថែទាំសុខភាពក៏អាចប្រឈមមុខនឹងគ្រោះថ្នាក់ផងដែរ ។

ការអនុវត្តន៍បទដ្ឋានប្រុងប្រយ័ត្ននានា អាចកាត់បន្ថយជាអតិបរមាការប្រឈមមុខនឹងការឆ្លងជំងឺពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ទោះបីជាស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ខ្ពស់ក៏ដោយ ។

បទដ្ឋានប្រុងប្រយ័ត្ននានា គួរត្រូវបានអនុវត្តនៅគ្រប់ពេលវេលាទាំងអស់ ។

**Effective infection control is important to the health of patients and also to provide a safe working environment for health staff.**

Many infectious agents are present in health facilities. Patients may become infected while they are receiving health care and health care workers are at risk while they are doing their work. Other people visiting and working in the health care establishment may also be at risk.

Implementing standard precautions minimizes the risk of transmission of infection from person to person even in high-risk situations.

Standard precautions should be implemented at all times.



**ការឆ្លងជំងឺដែលទាក់ទងនឹងការថែទាំសុខភាព :** ជំងឺនានាដែលឆ្លងនៅក្នុងមណ្ឌលថែទាំសុខភាព (Nosocomial infections) និងជំងឺនានាដែលកើតឡើងដោយសារការផ្តល់កិច្ចអន្តរាគមន៍ថែទាំសុខភាព (Iatrogentic infectons) និងដែលអាចកើតមានឡើងនៅបន្ទាប់ពីអ្នកជំងឺចាកចេញពីមណ្ឌលថែទាំសុខភាពនោះ ។

**Health care associated Infections** - infections acquired in health care establishments ('nosocomial' infections) and infections that occur as a result of health care interventions ('iatrogenic' infections), and which may manifest after people leave the health care establishment.

# ព័ត៌មានសំខាន់ៗសំរាប់មន្ត្រីសុខាភិបាល
# Tips for health staff

## បទដ្ឋានប្រុងប្រយ័ត្ន

- អនាម័យដៃ

---

អនាម័យដៃអាចសង្គ្រោះជីវិត

---

  - នៅមុននិងក្រោយពេលមានទំនាក់ទំនងជាមួយអ្នកជំងឺណាម្នាក់
  - នៅបន្ទាប់ពីដោះស្រោមដៃចេញ ឬប្រដាប់ការពារខ្លួនផ្សេងៗទៀត
  - អនាម័យដៃជាធម្មតា ត្រូវធ្វើឡើងដោយការលាងសំអាតដៃជាមួយសាប៊ូ និងទឹក
  - បើឃើញដៃមានប្រឡាក់ឈាម ឬសារធាតុរំអិលដែលបញ្ចេញពីរាងកាយ ត្រូវលាងដៃឱ្យបានស្អាតសព្វគ្រប់ខ្លែងជាមួយសាប៊ូ និងទឹក
  - ត្រូវលាងសំអាតដៃក្រោយពេលបន្ទោរបង់

- ប្រដាប់ការពារខ្លួនដែលផ្អែកលើការវាយតំលៃលើការប្រឈមមុខនឹងគ្រោះថ្នាក់ និងដើម្បីជៀសវាងការប៉ះពាល់ឈាម សារធាតុរំអិលដែលបញ្ចេញពីរាងកាយ កាកសំណល់ ពីរាងកាយ និងសារធាតុរាវដែលបញ្ចេញពីសរីរាង្គ ។
- ប្រយ័ត្នប្រយែងក្នុងការចាប់កាន់ឧបករណ៍ថែទាំអ្នកជំងឺ និងកម្រាលដែលប្រឡាក់
- បង្ការការរងរបួសដោយមុតម្ជុល
- សំអាតបរិស្ថានបន្ទប់របស់អ្នកជំងឺឱ្យបានស្អាត
- ប្រយ័ត្នប្រយែងក្នុងការចាប់កាន់កាកសំណល់ ។

## Standard precautions

- Hand hygiene

---

Hand hygiene saves lives!

---

  - Before and after any patient contact
  - After removing gloves or any other PPE item
  - Routine hand hygiene is performed by washing hands with soap and water
  - If hands are visible soiled with blood or other body fluid, hands should be washed thoroughly with soap and water.
  - Hands should be washed after using the toilet

- PPE based on risk assessment and to avoid contact with blood, body fluid, excretions and secretions
- Appropriate handling of patient care equipment and soiled linen
- Prevention of needle stick injuries
- Appropriate environmental cleaning of the patient's room
- Appropriate handling of waste.



## ការចោលកាកសំណល់ ការបាញ់ថ្នាំសំលាប់មេរោគលើសំភារៈ និងទីកន្លែង

- រាល់កាកសំណល់ដែលបានមកពីកន្លែងដាក់អ្នកជំងឺដាច់ដោយឡែកពីគេ គួរត្រូវកើបដាក់ក្នុងធុងឱ្យបានត្រឹមត្រូវដោយកុំឱ្យកំពប់។
- បើផ្នែកខាងក្រៅនៃស្បោងដាក់កាកសំណល់មានប្រឡាក់ ចូរសំអាត និងបាញ់ថ្នាំសំលាប់មេរោគលើស្បោងផ្នែកខាងក្រៅនោះ មុនពេលយកចោល។
- នៅពេលដឹកជញ្ជូនកាកសំណល់ចេញពីកន្លែងដាក់អ្នកជំងឺដាច់ដោយឡែកពីគេនោះ ចូរប្រើស្រោមដៃ ហើយបន្ទាប់មក ត្រូវអនាម័យដៃ។
- ទោះបីការប្រឈមមុខនឹងគ្រោះថ្នាក់ក្នុងការឆ្លងជំងឺផ្តាសាយបក្សីដោយសារលាមកមនុស្ស ពុំត្រូវបានគេដឹងក៏ដោយ ក៏គួរប្រុងប្រយ័ត្នបំផុតក្នុងការចាប់កាន់លាមកផងដែរ។
- ចូរលាងសំអាតចាននិងប្រដាប់ប្រដារហូបបាយរបស់អ្នកជំងឺជាមួយម្សៅសាប៊ូនិងទឹក។ ចូរទុកដាក់ប្រដាប់ប្រដារហូបបាយរបស់អ្នកជំងឺសំរាប់អ្នកជំងឺតែម្នាក់គត់។
- កន្លែងដាក់អ្នកជំងឺដាច់ដោយឡែកនោះ គួរសំអាតនិងបាញ់ថ្នាំសំលាប់មេរោគជារៀងរាល់ថ្ងៃ។

## Waste disposal, appropriate disinfection of surfaces and objects, etc.

- All waste generated in the isolation area should be removed in suitable containers that do not allow spillage of contents.
- If the outside of the waste disposal bag is contaminated, clean and disinfect the outside of the bag before removing it.
- When transporting waste outside of the isolation area, use gloves followed by hand hygiene.
- Although the risk of transmission of avian influenza by human feces is unknown, feces should be handled with extreme caution.
- Wash patient dishes and eating utensils with detergent and water. Keep the patient's utensils for one patient only.
- The isolation area should be cleaned and then disinfected daily.









## បន្ទប់ដាក់អ្នកជំងឺដាច់ដោយឡែកៈ កំណត់ព្រំដែនសំរាប់អ្នកជំងឺនិងមន្ត្រីសុខាភិបាល

- ដាក់អ្នកជំងឺផ្តាសាយបក្សីនៅក្នុងបន្ទប់ដែលមានគ្រែតែមួយ។ បើមានតែបន្ទប់គ្រែច្រើន ចូរដាក់អ្នកជំងឺផ្សេងទៀតឱ្យនៅដាច់ដោយឡែក ហើយត្រូវដាក់ករណីសង្ស័យនិងករណីអ្នកកើតជំងឺផ្តាសាយបក្សីនៅក្នុងបន្ទប់ផ្សេងពីគ្នា។ គ្រែត្រូវដាក់ដាច់ពីគ្នាដោយរបាំងឃាំង (ឧទា. វាំងននឡប់ខ្សែ) ហើយគ្រែត្រូវដាក់ឆ្ងាយពីគ្នាជាងមួយម៉ែត្រ។
- ត្រូវបិទទ្វារជានិច្ច
- មនុស្សដែលចូលទៅក្នុងបន្ទប់នោះ ត្រូវពាក់ប្រដាប់ការពារខ្លួនឱ្យបានត្រឹមត្រូវ (ស្រោមដៃ ម៉ាស់ អាវពេទ្យ ហើយបើអ្នកគិតថាអាចមានការខ្ទាត/បាចសាចឈាម ឬសារធាតុរាវផ្សេងៗ ដែលបញ្ចេញពីរាងកាយ ចូរពាក់សំពត់អៀមការពារ វ៉ែនតាការពារភ្នែក និងថង់គ្របក្បាល)
- កំរិតចំនួនមនុស្សដែលត្រូវមានទំនាក់ទំនងជាមួយអ្នកជំងឺ។ អ្នកសួរសុខទុក្ខអ្នកជំងឺ គួរត្រូវបានផ្តល់ឱ្យនូវប្រដាប់ការពារខ្លួន និងទទួលការណែនាំអំពីរបៀបប្រើវា។
- កំណត់ព្រំដែនឱ្យអ្នកជំងឺចេញចូលពីបន្ទប់របស់ខ្លួន។ ប្រសិនបើចាំបាច់ត្រូវដឹកជញ្ជូនអ្នកជំងឺ ត្រូវកាត់បន្ថយជាអតិបរមានូវការសាយភាយដំណក់ទឹកតូចៗពីមាត់និងច្រមុះរបស់អ្នកជំងឺ ដោយការពាក់ម៉ាស់ឱ្យអ្នកជំងឺ ហើយបុគ្គលិកដែលដឹកជញ្ជូនអ្នកជំងឺនោះក៏គួរតែពាក់ម៉ាស់ការពារផងដែរ។

## Isolation wards - restricted movement of patients and health staff

- Place the patient in a single room. If only multi-bed rooms are available, keep all other patients separate, and separate confirmed and suspected cases into different rooms. Beds should be separated by a physical barrier (e.g. curtain, partition) and beds must be placed more than 1 meter apart.
- Doors must be kept closed.
- Anyone who enters the room must wear appropriate PPE (gloves, mask, gown, and if you anticipate the splashing of blood or other body fluid wear a plastic apron, goggles and head cover)
- Limit the number of people who have contact with the patient. Visitors should be provided with PPE and instructed how to use it.
- Limit the movement of the patient outside his/her room. If transport is necessary, minimize dispersal of droplets by masking the patient and staff transporting the patient should also wear a mask as a precaution.

## ការប្រុងប្រយ័ត្នចំពោះដំណក់ទឹកតូចៗ

ការប្រុងប្រយ័ត្នចំពោះដំណក់ទឹកតូចៗ គួរត្រូវបានអនុវត្តក្នុងពេលផ្តល់ការថែទាំដល់អ្នកជំងឺដែលមានជំងឺផ្លូវដង្ហើម ។

## ប្រដាប់ការពារខ្លួនសំរាប់មន្ត្រីសុខាភិបាល

- ការប្រើប្រាស់ប្រដាប់ការពារខ្លួន គឺត្រូវមានរយៈពេលកំណត់សំរាប់បុគ្គលិកផ្តល់ការថែទាំសុខភាពដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកជំងឺផ្តាសាយបក្សី
- គ្រឿងប្រដាប់ការពារខ្លួនដែលគេផ្តល់អនុសាសន៍ឱ្យប្រើសំរាប់បុគ្គលិកផ្តល់ការថែទាំសុខភាពដែលមានទំនាក់ទំនងជាមួយអ្នកជំងឺ រួមមាន :
  - ម៉ាស់ N95 ឬម៉ាស់ពាក់សំរាប់វះកាត់ដែលតឹងណែនល្អ ប្រសិនបើគ្មានម៉ាស់ N95
  - ពាក់វ៉ែនតាដើម្បីការពារភ្នែក
  - ស្រោមដៃដែលពាក់ហើយបោះចោល
  - អាវពេទ្យដែលពាក់ហើយបោះចោល

## Droplet precautions

Droplet precautions should be followed when providing care for patients with respiratory illnesses.

## Personal Protective Equipment (PPE) for health staff

- The use of PPE is mandatory for any health care worker who is in close contact with an avian influenza patient.
- Recommended PPE items for health care workers in contact with patients include:
  - N95 masks or a tight fitting surgical mask if there are no N95 masks available.
  - Eye protection, such as goggles
  - Disposable gloves
  - Disposable gowns

សំរាប់មនុស្សពេញវ័យនិងកុមារអាយុលើស១២ឆ្នាំ ការប្រុងប្រយ័ត្នក្នុងការបង្ការការឆ្លងជំងឺគួរមានរយៈពេល៧ថ្ងៃនៅបន្ទាប់ពីចេញរោគសញ្ញា និងរយៈពេល២១ថ្ងៃនៅបន្ទាប់ពីចេញរោគសញ្ញាសំរាប់កុមារអាយុក្រោម១២ឆ្នាំ។ ការឆ្លងវីរុសនេះអាចកើតឡើងរហូតដល់រយៈពេល២១ថ្ងៃចំពោះកុមារតូចៗ។

វិធានការបង្ការការឆ្លងជំងឺ ក៏គួរត្រូវបានអនុវត្តផងដែរ នៅពេលមានការបង្ហាញការស្តាយស្រណោះចំពោះអ្នកជំងឺដែលបានស្លាប់ដោយសារជំងឺផ្តាសាយបក្សី។

The infection control precautions should remain in place for 7 days after onset of symptoms for adults and children > 12 years, and for 21 days after onset of illness for children 12 years. Shedding of the virus can occur for up to 21 days in young children.

Infection control measures should also be implemented when caring for the deceased patient.

# ព័ត៌មានសំខាន់ៗសំរាប់អ្នកជំងឺ
# Tips for the patient

នៅពេលអ្នកជំងឺមកដល់ ចូរសាកសួរគាត់ថាតើគាត់មានរោគសញ្ញាជំងឺផ្លូវដង្ហើមដែរឬទេ។ ប្រសិនបើមាន ចូរអប់រំអ្នកជំងឺជាបន្ទាន់អំពីអនាម័យ ផ្លូវដង្ហើម/វិធីក្អកត្រឹមត្រូវ។

- ខ្ទប់ច្រមុះ/មាត់នៅពេលក្អក ឬកណ្តាស់
- ហាមខាកស្តោះ
- ក្រដាសជូតទន់ៗដែលប្រើហើយបោះចោល ដើម្បីដាក់សារធាតុរំអិលដែលបញ្ចេញពីផ្លូវដង្ហើម (ពីការក្អក កណ្តាស់ ឬខាកស្តោះ) និងបោះវាចោលក្នុងធុងសំរាមដែលនៅជិតបំផុត បន្ទាប់ពីប្រើប្រាស់វារួច
- លាងដៃបន្ទាប់ពីក្អក កណ្តាស់ ឬញើសសំបោរ

When patients arrive, ask them if they have any symptoms of a respiratory infection. If yes, educate the patient immediately about respiratory hygiene/cough etiquette.

- Cover the nose/mouth when coughing, sneezing,
- Do not spit
- Use disposable tissues to contain respiratory secretions (from coughing, sneezing or spitting) and dispose of them in the nearest waste bin after use
- Wash hands after coughing, sneezing or blowing nose!





**ចូរចងចាំ** : ទោះបីគ្មានករណីដែលញ្ជាក់ថា មានការចំលងជំងឺផ្តាសាយបក្សីពីមនុស្សទៅមនុស្សក៏ដោយ ក៏ការបង្ការការឆ្លងជំងឺ និងអនាម័យដៃគឺជាការសំខាន់ដើម្បីបង្ការមិនអោយវីរុសមានឱកាសបំលែងខ្លួននិងវិវត្តទៅជាវីរុសថ្មីមួយ ដែលអាចឆ្លងរាលដាលពីមនុស្សទៅមនុស្សបាន។

**Remember** - although there is no confirmed case of human-to-human transmission of avian influenza, infection control and hand hygiene are very important to prevent giving the virus a chance to change and develop into a new virus that can be spread from human to human.

# ការព្យាបាលអ្នកជំងឺផ្តាសាយបក្សី

# Case Management of Avian Influenza in Humans

ប្រសិនបើមានការផ្ទុះជំងឺផ្តាសាយលើមនុស្ស អ្នកជំងឺគួរត្រូវបានគេរាយការណ៍ជាបន្ទាន់ដល់មន្ត្រីសុខាភិបាល ។

If an outbreak of avian influenza in humans occurs, patients should immediately be reported to the Ministry of Health.

## រោគសញ្ញា

រោគសញ្ញានៃជំងឺផ្តាសាយបក្សីលើមនុស្សមានលក្ខណៈស្រដៀងគ្នានឹងជំងឺផ្តាសាយធម្មតាដែរ ។ អាស្រ័យហេតុនេះ វាសំខាន់ណាស់ដែលមន្ត្រីសុខាភិបាលទាំងអស់ត្រូវអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលក្នុងការកំណត់ និងរាយការណ៍អំពីករណីអ្នកជំងឺដែលសង្ស័យ ។

## Signs and Symptoms

Signs and symptoms of avian influenza infection in humans are similar to those of seasonal human influenza. It is therefore very important that all health staff follow the MoH guidelines for detecting and reporting suspected cases.

## និយមន័យនៃករណីសង្ស័យ

**គ្រុនក្តៅ** (សីតុណ្ហភាពលើសពី៣៨អង្សារសេ) និងមានរោគសញ្ញាណាមួយ ឬលើសពីមួយក្នុងចំណោមរោគសញ្ញាខាងក្រោម :

- ក្អក
- ដកដង្ហើមថប់ៗ ឬពិបាកដកដង្ហើម

ឬស្លាប់ដោយសារជំងឺផ្លូវដង្ហើមស្រួចដែលមិនអាចពន្យល់បាន

**និង**មានប្រវត្តិណាមួយ ឬលើសពីមួយខាងក្រោម :

- មានទំនាក់ទំនងជិតស្និទ្ធជាមួយសត្វមាន់-ទាដែលឈឺ ឬងាប់ក្នុងរយៈពេល៧ថ្ងៃមុនពេលចាប់ផ្តើមឈឺ
- មានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកជំងឺ ឬអ្នកស្លាប់ដោយសារជំងឺផ្តាសាយបក្សីក្នុងរយៈពេល៧ថ្ងៃកន្លងមក ។

## Suspected Case Definition

1. FEVER (temperature 38 degree Celsious) and one or more of the following symptoms or signs:

- cough
- shortness of breath or difficulty breathing

**OR** death due to an unexplained acute respiratory illness

AND one or more of the following:

- Close contact with sick or dead poultry in the 7 days prior to onset of illness
- Close contact with any person hospitalised or who has died from influenza-like illness in the past 7 days



# រាយការណ៍ជាបន្ទាន់
# Report Immediately

## សូមអ្នកទាក់ទងមកក្រសួងសុខាភិបាល

**MOH hotline 012 488 981 012 836 868**

ក្រសួងសុខាភិបាលបានផ្តល់អនុសាសន៍ឱ្យគ្រប់មណ្ឌលសុខភាពទាំងអស់ពិនិត្យតាមដានរោគសញ្ញានៃជំងឺផ្លូវដង្ហើមស្រួច ហើយរាយការណ៍ជាបន្ទាន់ ប្រសិនបើកត់សំគាល់ឃើញមានរោគសញ្ញាណាមួយ ជាពិសេសប្រសិនបើ :

- នៅក្នុងមណ្ឌលសុខភាពណាមួយ ប្រសិនបើមានមន្ត្រីសុខាភិបាល២-៣នាក់មានជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវមធ្យមឬធ្ងន់ធ្ងរក្នុងអំឡុងពេលជាមួយគ្នា។
- នៅក្នុងភូមិណាមួយ ប្រសិនបើមានមនុស្ស៣-៥នាក់មានជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវមធ្យម ឬធ្ងន់ធ្ងរក្នុងអំឡុងពេលជាមួយគ្នា។

### រោគសញ្ញានៃជំងឺផ្លូវដង្ហើមស្រួច

- គ្រុនក្តៅ (លើសពី៣៨អង្សារសេ)
- ក្អក ឬពិបាកដកដង្ហើម ឬដកដង្ហើមថប់ៗ
- ចំពោះកុមារ (អាយុពី១-៥ឆ្នាំ) ជំងឺផ្លូវដង្ហើមស្រួចមានក្អក ឬពិបាកដកដង្ហើម និងមានចង្វាក់ដង្ហើមលើសពី៤០ដងក្នុងមួយនាទី។
- ចំពោះទារក (អាយុក្រោម១ឆ្នាំ) ជំងឺផ្លូវដង្ហើមស្រួចមានក្អក ឬពិបាកដកដង្ហើម និងមានចង្វាក់ដង្ហើមលើសពី៦០ដងក្នុងមួយនាទី។

The Ministry of Health recommends health facilities to watch for symptoms of Acute Respiratory Infections (ARI) and report immediately if you notice any symptoms, especially if:

- In a health facility if 2-3 health staff develop moderate to severe ARI during the same period
- In a village if 3-5 people develop moderate to severe ARI during the same period.

### Symptoms of ARI

- Fever (>=38°C)
- Cough, difficulty breathing or shortness of breath
- In children (1 to 5 years), ARI presents with a cough or difficulty breathing and a breathing rate >40/min
- In infants (under 1 year of age), ARI presents with a cough or difficulty breathing and a breathing rate >60/min



## តើនឹងមានអ្វីកើតឡើងនៅពេលអ្នករាយការណ៍អំពីករណីអ្នកសង្ស័យកើតជំងឺផ្តាសាយបក្សី?

នៅពេលក្រសួងសុខាភិបាលទទួលបានរបាយការណ៍អំពីករណីសង្ស័យណាមួយ ក្រុមឆ្លើយតបបន្ទាន់របស់ខេត្តនឹងចុះទៅកន្លែងនោះភ្លាម ដើម្បីស៊ើបអង្កេតករណីនោះ។ ប្រសិនបើករណីនោះត្រូវនឹងនិយមន័យនៃករណីជំងឺផ្តាសាយបក្សីនោះ ការស៊ើបអង្កេតដល់ទីកន្លែងនឹងត្រូវធ្វើឡើង ដើម្បីវាយតំលៃភាពធ្ងន់ធ្ងរនៃករណីនោះ កំណត់អំពីមូលហេតុដែលមនុស្សនោះបានឆ្លងជំងឺ និងដើម្បីប្រមូលវត្ថុវិភាគ។

ការស៊ើបអង្កេតដល់ទីកន្លែងអាចចាប់ផ្តើមធ្វើនៅមណ្ឌលសុខភាពក្នុងភូមិ ក្នុងស្រុកប្រតិបត្តិនៅមន្ទីរពេទ្យខេត្ត ឬមន្ទីរពេទ្យបង្អែក។

ឧបករណ៍ពិសេសត្រូវបានបង្កើតឡើងសំរាប់ការស៊ើបអង្កេតដល់ទីកន្លែង ដែលរួមទាំងឧបករណ៍ការពារផ្ទាល់ខ្លួននិងឧបករណ៍ប្រមូលវត្ថុវិភាគ។

## What will happen when you report human suspect cases

When the MoH receives a report of a suspected case, the provincial Rapid Response Team will come immediately to the site to investigate the case. If the case fulfills the case definition, a field investigation will be conducted to evaluate the severity of the case, to determine how the person caught the disease and to collect samples.

The field investigation could take place either in the village at a local health setting, in an OD, or in a provincial or referral hospital.

Special kits have been set up for field investigation, including PPE and a specimen collection kit.

“ នៅពេលដែលខ្ញុំបានទទួលរបាយការណ៍អំពីការផ្ទុះជំងឺផ្តាសាយបក្សី ក្រុមរបស់ ខ្ញុំនឹងធ្វើការងារសំខាន់១ពីរគឺ:

១. ចុះទៅកន្លែងនោះភ្លាម

២. រាយការណ៍ជាបន្ទាន់ទៅនាយកដ្ឋានកំចាត់រោគឆ្លងនៃក្រសួងសុខាភិបាល

ចំពោះការទៅពិនិត្យដល់កន្លែងដែលមានផ្ទុះជំងឺនោះ ក្រុមរបស់ខ្ញុំនឹងធ្វើការស៊ើបអង្កេតនៅនឹងកន្លែង និងប្រមូលវត្ថុវិភាគពីមនុស្សដែលសង្ស័យ ហើយបញ្ជូនទៅវិទ្យាស្ថានប៉ាស្ទ័រដើម្បីធ្វើតេស្ត។

When I am informed of an area with avian influenza, immediately my team will perform two tasks at the same time:

1. Go to the outbreak area
2. Report immediately to the CDC department at the Ministry of Health

In my visit to the outbreak area, my team will conduct a field investigation and take a sample from the suspect case and send immediately to Institute Pasteur for testing. ”



លោក ជូ ស៊ើត
អនុប្រធានការិយាល័យបច្ចេកទេស
មន្ទីរសុខាភិបាលខេត្តបាត់ដំបង

**Mr. Chou Seut**
Deputy Chief of Technical Office
of Battambang PHD

បន្ទាប់ពីការពិនិត្យគ្លីនិកលើអ្នកជំងឺ និងការប្រមូលប្រវត្តិនៃការប្រឈមមុខនឹងជំងឺ ក្រុមអ្នកស៊ើបអង្កេតដល់ទីកន្លែង នឹងកំណត់ប្រភេទករណីសង្ស័យទៅក្នុងប្រភេទណាមួយនៃប្រភេទទាំងពីរដូចខាងក្រោម :

- **ករណីស្រាល :** មានសញ្ញាគ្លីនិកស្រាល (មានន័យថាគ្មានជំងឺរលាកសួត) និងមានប្រវត្តិប៉ះពាល់តិចតួច ។

- **ករណីធ្ងន់ធ្ងរ:** មានសញ្ញាគ្លីនិកធ្ងន់ធ្ងរ និង/ឬ មានប្រវត្តិប្រឈមមុខនឹងជំងឺ (ជាមួយកសិដ្ឋានដែលបានបញ្ជាក់ច្បាស់ថាបានឆ្លងជំងឺ ឬមានទំនាក់ទំនងជាមួយករណីអ្នកកើតជំងឺ) ។

អ្នកជំងឺ "ករណីស្រាល" អាចទុកតាមដាននៅមណ្ឌលសុខភាពក្នុងតំបន់ ក្នុងអំឡុងពេលរង់ចាំលទ្ធផលវិភាគ។ ប្រសិនបើលទ្ធផលវិភាគបង្ហាញថាមានជំងឺផ្តាសាយបក្សី គេត្រូវតែបញ្ជូនអ្នកជំងឺជាបន្ទាន់ទៅមន្ទីរពេទ្យបង្អែកជំងឺផ្តាសាយបក្សី ។

អ្នកជំងឺ "ករណីធ្ងន់ធ្ងរ" យ៉ាងហោចណាស់ក៏ត្រូវបញ្ជូនទៅមន្ទីរពេទ្យខេត្ត ឬមន្ទីរពេទ្យបង្អែក ប្រសិនបើអាចធ្វើទៅបាន ។

គេត្រូវយកវត្ថុវិភាគពីច្រមុះ និងបំពង់ករបស់អ្នកជំងឺដែលសង្ស័យកើតជំងឺផ្តាសាយបក្សី ហើយបញ្ជូនទៅវិទ្យាស្ថានប៉ាស្ទ័រក្នុងរាជធានីភ្នំពេញដើម្បីធ្វើតេស្តលើវត្ថុវិភាគនោះ ដើម្បីបញ្ជាក់បន្ថែមអំពីករណីសង្ស័យនោះ។ (PCR វិជ្ជមានចំពោះវីរុស Influenza A/H5) ។



After clinical examination of the patient and collection of exposure history, the field investigation team should classify the suspected case in one of these two following categories:

- **Mild case:** mild clinical signs (i.e. absence of pneumonia) and poor history of exposure.
- **Severe case:** severe clinical signs AND/OR good history of exposure (to confirmed infected farms or contact with another confirmed case).

The "mild case" patient could be kept under observation at the local health care service while waiting for the result. If the result comes back positive, the patient must be immediately referred to an avian influenza referral hospital.

The "severe case" patient should be referred to at least a provincial hospital or when possible to a referral hospital.

Nose and throat swabs will be taken for any suspected case and sent to Institut Pasteur in Phnom Penh, who will conduct laboratory tests on the samples to confirm the case. (Positive PCR for Influenza A/H5).

## ការតាមដានលើអ្នកដែលមានទំនាក់ទំនងជាមួយអ្នកដែលបានបញ្ជាក់ថាមានជំងឺ



ការស៊ើបអង្កេតក៏នឹងរួមបញ្ចូលទាំងការតាមដានលើអ្នកដែលមានទំនាក់ទំនងជាមួយអ្នកជំងឺផងដែរ ។

"អ្នកដែលមានទំនាក់ទំនង" គឺមនុស្សដទៃទៀតដែលមានទំនាក់ទំនងជិតស្និទ្ធ (យ៉ាងតិច១ម៉ែត្រក្នុងរយៈពេល៥នាទី) ជាមួយអ្នកជំងឺដែលសង្ស័យថាមានជំងឺផ្ដាសាយបក្សីនៅក្នុងរយៈពេល ១០ថ្ងៃកន្លងមក ។

**ការតាមដានរួមមាន ៖**

- ការកំណត់អ្នកដែលមានទំនាក់ទំនង ដើម្បីផ្តល់ដំបូន្មានដល់ពួកគេសំរាប់ការត្រួតពិនិត្យសុខភាពដោយខ្លួនឯង ។
- ការកំណត់អ្នកដែលមានទំនាក់ទំនងដែលមានរោគសញ្ញា និងការបញ្ជូនទៅមន្ទីរពេទ្យសមស្របណាមួយ ដើម្បីដាក់ឱ្យនៅដាច់ដោយឡែកពីគេសំរាប់ការព្យាបាល ។
- ការស៊ើបអង្កេតលើអ្នកដែលមានទំនាក់ទំនង នឹងត្រូវធ្វើក្នុងរយៈពេល១០ថ្ងៃ ដោយសារហេតុផលនៃរយៈពេលសំងំ ។
- ចំពោះករណីសង្ស័យធ្ងន់ធ្ងរ អ្នកជំងឺនិងអ្នកថែទាំគួរតែពាក់ម៉ាស់ការពារគ្រប់ពេលវេលា ។
- មន្ត្រីសុខាភិបាលនិងអ្នកថែទាំ គួរតែអនុវត្តន៍អនាម័យល្អ និងវិធានការបង្ការការឆ្លងរោគ ។

## Follow-up of contacts for confirmed cases

The investigation will also include a follow-up of contacts.

"Contacts" are other people that have been in close contact (1 meter for at least 5 minutes) with the suspect patient within the past 10 days.

**The follow up includes:**

- Identification of the contacts to give them advice for health self-monitoring.
- Detection of the symptomatic contacts and referral to appropriate hospital for isolation and treatment.
- Investigation of contacts will be implemented for 10 days – because of the incubation period.
- With a suspected severe case, the patient and care-givers should wear a face mask at all times.
- Health staff and care takers should practice very good hygiene and infection control measures.



## មន្ទីរពេទ្យបង្អែក

មន្ទីរពេទ្យបង្អែកដែលបានកំណត់ទុក នឹងត្រូវបានបំពាក់ដោយសំភារៈវេជ្ជសាស្ត្រ ឧបករណ៍ការពារខ្លួន បន្ទប់ដាក់អ្នកជំងឺដាច់ដោយឡែក ហើយមន្ត្រីសុខាភិបាលត្រូវបានទទួលការបណ្តុះបណ្តាល ដើម្បីថែទាំអ្នកជំងឺផ្តាសាយបក្សី និងអំពីវិធានការណ៍បង្ការការឆ្លងរោគ ដើម្បីការពារមន្ត្រីសុខាភិបាល និងមនុស្សដទៃទៀតនៅមន្ទីរពេទ្យទាំងនោះ ។

ក្រសួងសុខាភិបាលកំពុងរៀបចំមន្ទីរពេទ្យបង្អែកសំរាប់ជំងឺផ្តាសាយបក្សី ដែលនឹងត្រូវបំពាក់គ្រឿងបរិក្ខារ ដើម្បីថែទាំអ្នកជំងឺក្នុងអំឡុងពេលផ្ទុះជំងឺផ្តាសាយ ។ បច្ចុប្បន្ននេះមន្ទីរពេទ្យបង្អែកសំរាប់ជំងឺផ្តាសាយបក្សីមានមន្ទីរពេទ្យកាល់ម៉ែតក្នុងរាជធានីភ្នំពេញ និងមន្ទីរពេទ្យខេត្តសៀមរាប ។ ក្រសួងសុខាភិបាលកំពុងរៀបចំឱ្យមានមន្ទីរពេទ្យបង្អែកបីកន្លែងបន្ថែមទៀត ។

## Referral hospitals

Designated referral hospitals are being equipped with medical supplies, personal protective equipment (PPE), isolation wards and the staff are being trained to care for patients infected with avian influenza and in infection control measures to protect health staff and other people at the hospitals.

The MOH has on-going preparation for avian influenza referral hospitals which are being equipped to care for patients during an outbreak of influenza. Currently the avian influenza referral hospitals are Calmette Hospital in Phnom Penh and Siem Reap. The MOH is preparing an additional three hospitals.



# ការវាយតំលៃលើការប្រឈមមុខនឹងគ្រោះថ្នាក់

**សូមសាកសួរអ្នកជំងឺដែលសង្ស័យនូវសំនួរដូចខាងក្រោម។ ប្រសិនបើចំលើយភាគច្រើនគឺ "បាទ/ចាស" នោះវាបង្ហាញថាពួកគេប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ក្នុងការឆ្លងជំងឺផ្តាសាយបក្សី។**

- តើអ្នកធ្លាប់មានទំនាក់ទំនងជាមួយសត្វបក្សីដែលឈឺ ឬងាប់នៅក្នុងរយៈពេល៧ថ្ងៃមុនដែរឬទេ?
- តើអ្នកធ្លាប់បានចូលរួមទស្សនាការប្រជល់មាន់ ឬកីឡាផ្សេងទៀតដែលពាក់ព័ន្ធនឹងសត្វបក្សីដែរឬទេ?
- តើអ្នកបានផឹកទឹកឆៅ ឬមានទំនាក់ទំនងជាមួយទឹកដែលមានសត្វបក្សីព្រៃ ឬសត្វបក្សីស្រុកដែរឬទេ?
- តើអ្នកមានទៅផ្សារដែលមានលក់សត្វបក្សីរស់ដូចជា សត្វបក្សីព្រៃ ឬសត្វមាន់-ទាដែរឬទេ?
- តើអ្នកបានដឹកជញ្ជូនសត្វបក្សី ឬនៅជិតស្និទ្ធនឹងការដឹកជញ្ជូនសត្វបក្សីដែរឬទេ?
- តើអ្នកមានយកមាន់-ទា ដែលឈឺ ឬងាប់មករៀបចំធ្វើជាម្ហូបដើម្បីបរិភោគដែរឬទេក្នុងពេលថ្មីៗនេះ?
- តើអ្នកបានបរិភោគសាច់ ឬស៊ុតបក្សីដែលមិនឆ្អិនល្អទៅពេលថ្មីៗនេះដែរឬទេ?
- ចំពោះកុមារៈ តើអ្នកមានលេងបាញ់សត្វបក្សីដោយប្រើជំពាម ហែលក្នុងទឹកស្រះដែលមានសត្វបក្សី ធ្វើការងារ ឬលេងជាមួយសត្វបក្សី ឬបោចរោមសត្វបក្សីដែរឬទេ?

## Risk Assessment

**Ask suspect patients the following questions. If they answer "yes", then they are at high risk of avian influenza infection:**

- Have you had contact with any sick or dead poultry in the past 7 days
- Have you attended a cockfight or other sport involving birds?
- Have you drunk unboiled water or had contact with water where wild or domestic birds have been?
- Have you been to a market where there are live birds, such as wild birds or ducks?
- Have you transported or been close to birds being transported?
- Have you prepared sick or dead poultry to eat recently?
- Have you eaten undercooked meat or eggs recently?
- For children – have you been catapulting birds, swimming in ponds where there are birds, working or playing with poultry or de-feathering any birds?



# ការរៀបចំផែនការជាស្រេចសំរាប់ការ ផ្ទុះជំងឺផ្ដាសាយឆ្លងរាតត្បាតជាសកល

## Influenza Pandemic Preparedness

ការឆ្លងរាតត្បាតជាសកលគឺជាការផ្ទុះឡើងមួយដែលប៉ះពាល់ដល់ពិភពលោកទាំងមូល ដោយមិនគិតអំពីព្រំដែននិងស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចឡើយ ។ វីរុសជំងឺផ្ដាសាយបក្សី H5N1 គឺជាបញ្ហាសុខភាពសាធារណៈមួយ ដោយសារតែសក្ដានុពលរបស់វាក្នុងការធ្វើឱ្យមានការឆ្លងរាតត្បាតជាសកលនៅទូទាំងពិភពលោក ។ ប្រសិនបើវីរុសជំងឺនេះនៅតែបន្តឆ្លងរាតត្បាត ក្នុងចំណោមសត្វបក្សី នោះវាជាឱកាសសំរាប់ឱ្យវីរុសនេះបំលែងទៅជាអាចឆ្លងដល់មនុស្ស ។

ជំងឺផ្ដាសាយដែលផ្ទុះឡើងឆ្លងរាតត្បាតជាសកលគឺបណ្ដាលមកពីវីរុសថ្មីនៃជំងឺផ្ដាសាយដែលបានបំលែងទៅតាមមនុស្ស ។ ការឆ្លងរាតត្បាតជាសកលអាចកើតឡើងនៅពេលល័ក្ខខ័ណ្ឌបីយ៉ាងត្រូវបានបំពេញ :

១. មានអនុក្រុមមួយនៃវីរុសជំងឺផ្ដាសាយកើតឡើង
២. វាឆ្លងដល់មនុស្ស ដែលបណ្ដាលឱ្យមានជំងឺធ្ងន់ធ្ងរ
៣. វាឆ្លងរាលដាលយ៉ាងងាយនិងជានិរន្តរ៍ក្នុងចំណោមមនុស្ស ។

វីរុសជំងឺផ្ដាសាយបក្សី H5N1 បានបំពេញល័ក្ខខ័ណ្ឌពីរដំបូង ។ វាគឺជាវីរុសថ្មីមួយ (ដែលកើតឡើងលើសត្វបក្សី ក្នុងអំឡុងទស្សវត្សរ៍ឆ្នាំ១៩៩០) ហើយចាប់តាំងពីឆ្នាំ១៩៩៧មក វាមានសមត្ថភាពក្នុងការចំលងដល់មនុស្ស ហើយបណ្ដាលឱ្យមានជំងឺធ្ងន់ធ្ងរ ។

**A pandemic is an outbreak that affects the whole world, regardless of national boundaries or socioeconomic status. The H5N1 avian influenza virus is a public health concern because of its potential to spark a pandemic. As long as the virus continues to spread among animals, there will be opportunities for this virus to adapt and infect humans.**

Influenza pandemics are caused by new influenza viruses that have adapted to human beings. A pandemic can start when three conditions have been met:

(1) a new influenza virus subtype emerges;

(2) it infects humans, causing serious illness; and

(3) it spreads easily and sustainably among humans.

The avian influenza H5N1 subtype meets the first two conditions. It is a new virus (emerging in birds during the 1990s) and, since 1997, it is capable of infecting humans, causing severe disease.

វីរុសអនុក្រុម H5N1 មិនអាចចំលងពីមនុស្សទៅមនុស្សដោយងាយស្រួលបានទេ។ ប៉ុន្តែប្រសិនបើវីរុសនេះនៅតែបន្តឆ្លងរាលដាលលើសត្វទៀត វីរុសនេះនឹងអាចវិវត្តទៅជាវីរុសថ្មីមួយដែលអាចឆ្លងរាលដាលដោយងាយស្រួលពីមនុស្សទៅមនុស្ស ហើយបណ្តាលឱ្យមានផ្ទុះជំងឺផ្តាសាយដែលឆ្លងរាតត្បាតជាសកល។

ពុំមាននរណាម្នាក់អាចព្យាករណ៍អោយបានច្បាស់លាស់ថាតើវីរុស H5N1 នេះនឹងអាចបណ្តាលឱ្យមានការផ្ទុះជំងឺផ្តាសាយឆ្លងរាតត្បាតជាសកលឬទេ ប៉ុន្តែប្រសិនបើវាអាចនោះ យើងក៏ពុំអាចដឹងថា តើវានឹងកើតឡើងរយៈពេលយូរប៉ុណ្ណាទេ ឬតើវានឹងមានគ្រោះថ្នាក់ប៉ុណ្ណាដែរ។

ប៉ុន្តែ វាជាការសំខាន់ណាស់ដែលប្រទេសកម្ពុជាត្រូវចាប់យកឱកាសចន្លោះនេះ ដើម្បីត្រៀមខ្លួនជាស្រេចសំរាប់ប្រឈមមុខនឹងការផ្ទុះឡើងនៃជំងឺផ្តាសាយឆ្លងរាតត្បាតជាសកល ។

The H5N1 subtype cannot be transmitted from human to human very easily. But as long as the virus continues to circulate in animals there is a risk that it will evolve into a new virus that can easily be spread from human to human, causing pandemic influenza.

No one is able to accurately predict whether or when H5N1 will trigger a pandemic, but if it does, we have no idea how long it might last or how deadly the virus will be.

It is essential that Cambodia take this current window of opportunity to prepare for a pandemic.

## តើនរណាខ្លះដែលប្រឈមមុខនឹងគ្រោះថ្នាក់នេះ?

នៅពេលដែលមានផ្ទុះជំងឺផ្តាសាយឆ្លងរាតត្បាតជាសកលកើតឡើង មនុស្សគ្រប់រូបទាំងអស់នឹងប្រឈមមុខនឹងគ្រោះថ្នាក់។

ពុំមានវ៉ាក់សាំងដែលនឹងអាចការពារមនុស្សប្រឆាំងនឹងជំងឺផ្តាសាយដែលឆ្លងរាតត្បាតជាសកលនេះបានឡើយ ព្រោះគេអាចផលិតវ៉ាក់សាំងបានតែនៅពេលបន្ទាប់ពីវីរុសថ្មីនេះត្រូវបានរកឃើញសិនប៉ុណ្ណោះ។



## Who is at risk?

Once a pandemic influenza starts, everybody will be at risk.

There is currently no vaccine that will protect people against pandemic influenza because a vaccine cannot be made until the new virus has been identified.

## តើនឹងអាចមានអ្វីកើតឡើងក្នុងពេលផ្ទុះជំងឺផ្តាសាយឆ្លងរាតត្បាតជាសកល

ប្រសិនបើវីរុសជំងឺផ្តាសាយថ្មីមួយ ធ្វើការវិវត្តន៍ដែលអាចចំលងពីមនុស្សទៅមនុស្សបាននោះ វាអាចមានលទ្ធភាពបណ្តាលឱ្យផ្ទុះជំងឺផ្តាសាយឆ្លងរាតត្បាតជាសកលមួយកើតឡើង។ វានឹងអាចមានគ្រោះថ្នាក់ ពីព្រោះមនុស្សភាគច្រើនអាចពុំមានប្រព័ន្ធការពារប្រឆាំងនឹងវីរុសថ្មីនេះទេ។ នេះមានន័យថាអាចមានមនុស្សជាច្រើនឈឺហើយមនុស្សខ្លះទៀតនឹងស្លាប់។

ការឆ្លងរាលដាលជាសកលដ៏ធ្ងន់ធ្ងរអាចបណ្តាលឱ្យមានជំងឺធ្ងន់ធ្ងរ និងមនុស្សជាច្រើនស្លាប់ធ្វើឱ្យប៉ះពាល់ដល់ជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សជាច្រើន និងនាំឱ្យមានបន្ទុកយ៉ាងធ្ងន់ធ្ងរដល់សេវាសុខភាព និងសេវាផ្សេងៗទៀត។

## What might happen in a pandemic

If a new influenza virus develops that can be transmitted from human to human, it is possible it might cause a global pandemic influenza. It would be dangerous because the vast majority of people would have no immunity to this new virus. This means that lots of people might become sick and some will die.

A serious pandemic may cause severe illness and many deaths, disrupt the daily life of many people and cause intense pressure on health and other services.

អង្គការសុខភាពពិភពលោកបានប្រើប្រាស់៦ដំណាក់កាលក្នុងការប្រុងប្រយ័ត្នចំពោះការផ្ទុះជំងឺផ្តាសាយឆ្លងរាតត្បាតជាសកល ជាប្រព័ន្ធមួយសំរាប់ផ្តល់ព័ត៌មានដល់ពិភពលោកអំពីភាពធ្ងន់ធ្ងរនៃការគំរាមកំហែងនៃជំងឺនេះ និងតំរូវការដើម្បីដាក់ចេញនូវសកម្មភាពរៀបចំជាស្រេចនានា។ បច្ចុប្បន្ននេះ ពិភពលោកកំពុងស្ថិតក្នុងដំណាក់កាលទីបី: អនុក្រុមថ្មីមួយនៃវីរុសជំងឺផ្តាសាយកំពុងបង្កឱ្យមានជំងឺនៅលើមនុស្ស ប៉ុន្តែវានៅពុំទាន់អាចឆ្លងរាលដាលខ្លាំងក្លា និងជានិរន្តរ៍ពីមនុស្សទៅមនុស្សនៅឡើយ។

WHO uses a series of six phases of pandemic alert as a system for informing the world of the seriousness of the threat and the need to launch progressively more intense preparedness activities. The world is presently in phase 3: a new influenza virus subtype is causing disease in humans but is not yet spreading efficiently and sustainably among humans.

## ដំណាក់កាលនៃការឆ្លងរាតត្បាតជាសកល

ដោយសារស្ថានភាពបច្ចុប្បន្ននៅតែបន្តវិវត្ត សហគមន៍អន្តរជាតិ និងអង្គការសុខភាពពិភពលោកបានកំណត់នូវដំណាក់កាលជាច្រើននៃឱកាសដើម្បីធ្វើកិច្ចអន្តរាគមន៍។

**ដំណាក់កាលទី១-៣ : ស្ថានភាពមុនពេលឆ្លងរាតត្បាតជាសកល (ស្ថានភាពបច្ចុប្បន្ន - ដំណាក់កាលទី៣)**

- បង្ការការឆ្លងរាតត្បាតនៃជំងឺផ្តាសាយបក្សីនៅលើសត្វ និងកាត់បន្ថយឱកាសចំលងមកមនុស្ស
- រាយការណ៍ជាបន្ទាន់នូវករណីសត្វ ឬមនុស្សដែលសង្ស័យថាមានការឆ្លងជំងឺផ្តាសាយបក្សី។ ការធ្វើបែបនេះជួយក្នុងការគ្រប់គ្រងការផ្ទុះឡើងនូវជំងឺនេះ ហើយក៏ជួយដល់អ្នកជំនាញក្នុងការចាត់ចែងសកម្មភាពតាមដានដែលចាំបាច់សំរាប់ការត្រួតពិនិត្យការវិវត្តន៍នៃវីរុសថ្មី។

**ដំណាក់កាលទី ៤-៥ : ការលេចឡើងនៃវីរុសជំងឺផ្តាសាយឆ្លងរាតត្បាតជាសកល**

- រារាំង ឬពន្យាការឆ្លងរាលដាលនៅកន្លែងប្រភព : ការធ្វើដំណើរអន្តរជាតិ ទំនងជានឹងត្រូវបានហាមឃាត់ អ្នកជំងឺនឹងត្រូវបានដាក់ដាច់ដោយឡែកពីគេនៅតាមមន្ទីរពេទ្យនានា។ សំភារៈបរិក្ខារការពារខ្លួន (Personal Protective Equipment) នឹងត្រូវបានផ្តល់ឱ្យមន្ត្រីសុខាភិបាលទាំងអស់ដែលថែទាំអ្នកជំងឺ។

**ដំណាក់កាលទី៦ : ការឆ្លងរាតត្បាតជាសកល**

- កិច្ចអន្តរាគមន៍នៅដំណាក់កាលនេះ មានបំណងដើម្បីកាត់បន្ថយផលប៉ះពាល់នៃការរាតត្បាតជាសកល ដោយកាត់បន្ថយការកើតមានជំងឺមរណៈភាព និងភាពចលាចលសង្គម។

## The pandemic phases

As the present situation continues to evolve, countries, the international community, and WHO have identified several phase-wise opportunities to intervene.

**Phase 1-3 - Pre-pandemic situation (current situation- phase 3)**

- Prevent the spread of avian influenza in animals, and reduce opportunities for infection in humans
- Report immediately any suspected animal or human cases of avian influenza – this helps to control the outbreak of the disease and also allows experts to manage surveillance activities necessary for monitoring the evolution of a new virus.

**Phase 4-5 - Emergence of a pandemic virus**

- Contain or delay spread at the source - international travel will most likely be restricted, sick people will be isolated in hospitals. Personal Protective Equipment (PPE) will be required for all health staff caring for infected patients.

**Phase 6 - Pandemic**

- Interventions at this point aim to reduce the impact of a pandemic by reducing morbidity, mortality, and social disruption.

## វិធីសាស្ត្រផ្ទាល់ខ្លួនដែលអាចជួយកាត់បន្ថយការឱកាសនៃការផ្ទុះជំងឺផ្តាសាយឆ្លងរាតត្បាតជាសកលគឺ:



- ខ្ទប់មាត់នៅពេលក្អកនិងកណ្តាស់ ដើម្បីបញ្ឈប់ការឆ្លងរាលដាលជំងឺផ្តាសាយ
- អនុវត្តក្បួនអនាម័យឱ្យបានល្អដើម្បីឱ្យមានសុខភាពល្អ និងមានសុវត្ថិភាព
- រាយការណ៍ជាបន្ទាន់រាល់ករណីសត្វឬមនុស្សដែលសង្ស័យថាមានជំងឺផ្តាសាយបក្សី



## Individual methods which we can all do to help prevent an influenza pandemic are:

- Cover coughs and sneezes to stop the spread of seasonal human influenza
- Practice good hygiene for good health and safety
- Report immediately any suspected animal or human cases of avian influenza






# រាយការណ៍ជាបន្ទាន់
# Report Immediately

| មជ្ឈមណ្ឌលជាតិស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល | សូមអ្នកទាក់ទងមកក្រសួងសុខាភិបាល |
|---|---|
| **012 833 795**<br>**012 214 970** | **012 488 981**<br>**012 836 868** |
| MAFF hotline | MOH hotline |

# លិខិតពីមិត្តអ្នកអាន

## Letters from Readers

?

លោកស្រី **សុខ សុភាព** ឆ្មបមធ្យម នៅផ្នែកពន្យាកំណើត ពិនិត្យផ្ទៃពោះ អប់រំសុខភាព នៅមណ្ឌលសុខភាពវល្លិស ស្រុកប្រតិបត្តិកំពង់ស្ពឺ បានសួរថា: មូលហេតុអ្វីបានជាធ្វើឱ្យអ្នកជំងឺឃ្លង់ក្រញ៉ង់ដៃ ក្រញ៉ង់ជើង មេរោគឈ្មោះអ្វី? បើជំងឺឃ្លង់កើតលើស្ត្រីមានផ្ទៃពោះ តើអាចឆ្លងទៅកូនដែលនៅក្នុងផ្ទៃដែរ ឬទេ?

**លោក វេជ្ជ. អៀង ប៊ុនថា**

**មន្ត្រីកម្មវិធីជាតិកំចាត់រោគរបេង និងហង់សិន បានឆ្លើយថា :**

មេរោគនៃជំងឺឃ្លង់ឈ្មោះ បាក់ស៊ីហង់សិន ។ មេរោគនេះវារស់នៅបង្កើតកូនចៅ និងបំផ្លាញសរសៃប្រសាទជាយក្រៅ (Nerf peripherique) ដូចជា: សរសៃប្រសាទនៅលើមុខក្បែរភ្នែក ម្រាមដៃ ម្រាមជើង...ជាដើម ។ ទាំងនេះកើតឡើងដោយសារតែអ្នកជំងឺយឺតយ៉ាវក្នុងការមកជួបគ្រូពេទ្យដើម្បីពិនិត្យ និងព្យាបាល ។

ចំពោះស្ត្រីមានផ្ទៃពោះ ហើយមានកើតជំងឺឃ្លង់ វាមិនឆ្លងទៅកូននៅក្នុងផ្ទៃទេ ព្រោះមេរោគនៃជំងឺឃ្លង់ឆ្លងពីអ្នកជំងឺម្នាក់ទៅម្នាក់ទៀតតាមរយៈផ្លូវដង្ហើម ។

?

លោកស្រី **អ៊ិម ស៊ីថា** គិលានុបដ្ឋាកបឋម ធ្វើការនៅមណ្ឌលសុខភាពមានជ័យ ស្រុកប្រតិបត្តិឈូក ខេត្តកំពត បានសួរថា មានអ្នកភូមិម្នាក់ ពេលសំរាលកូនហើយ ទឹកដោះរបស់គាត់ហូររហូត តើបណ្តាលមកពីមូលហេតុអ្វី? ហើយមានថ្នាំព្យាបាលដើម្បីអោយទឹកដោះហូរតាមធម្មតាវិញឬទេ?

**លោកស្រី វេជ្ជ. ឌុង រង្គារី**

**អនុប្រធានកម្មវិធីជាតិសុខភាពបន្តពូជ បានឆ្លើយថា :**

ជាធម្មតាក្រោយពេលសំរាលកូនរួច ក្រពេញទឹកដោះត្រូវតែបញ្ចេញទឹកដោះក្រោមឥទ្ធិពលនៃអរម៉ូន ដែលមាននៅក្នុងខ្លួនស្ត្រី ។ បើសិនជាទារកបៅជញ្ជក់ដោះនោះទឹកដោះកាន់តែចេញច្រើនឡើងៗ ហើយអាចហូរនៅពេលណាដែលកូនមិនទាន់បានបៅ (ទារកនៅដេកលក់មិនទាន់ភ្ញាក់) ឬនៅពេលដែលម្តាយធ្វើការឆ្ងាយពីផ្ទះ ។ ទឹកដោះចេញដូចទឹកអណ្តូងអញ្ចឹង បៅកាន់តែច្រើនចេញកាន់តែច្រើន ។ ការហូរទឹកដោះនេះជាករណីធម្មតា ដែលស្ត្រីគ្រប់រូបតែងជួបប្រទះនៅពេលដែលកូននៅតូច កូនមានតម្រូវការទឹកដោះតិច ហើយនៅពេលដែលកូននោះធំ ទឹកដោះនោះនឹងលែងហូរព្រោះកូនបៅកាន់តែច្រើន ។ នៅពេលដែលការហូរទឹកដោះធម្មតាដូចនេះមិនត្រូវព្យាបាលដោយប្រើថ្នាំអ្វីទេ គ្រាន់តែច្របាច់ទឹកដោះនោះចេញពេលដែលដោះឡើងខ្លាំង ហើយហូរទឹកដោះ ឬបើកូនភ្ញាក់ត្រូវឱ្យកូនបៅកុំចាំពេលវេលា ឬកំណត់ម៉ោង ។

ក្នុងករណីដែលទឹកដោះហូររហូត (មិនសូវជួបប្រទះទេ) មិនធម្មតាគួរបញ្ជូនស្ត្រីឱ្យមកជួបពេទ្យជំនាញ ដើម្បីពិភាក្សាមុននឹងសំរេចឱ្យថ្នាំបញ្ឈប់ការចេញ ទឹកដោះរបស់គាត់ត្រូវពិភាក្សាជាពិសេសលើការចិញ្ចឹមទារក ។

លោកស្រី **សុខ លី** គិលានុបដ្ឋាកបឋម ផ្នែកចាក់ថ្នាំបង្ការនៅមណ្ឌលសុខភាពក្រាំងអំពិល ស្រុកប្រតិបត្តិកំពត ។

១. ហេតុអ្វីបានជាការចាក់វ៉ាក់សាំង Hepatitis B បានគ្រប់ចំនួនកំណត់ហើយក្មេងអត់មានអង់ទីគ័រ?

២. ហេតុអ្វីបានជាបន្ទាប់ពីការទទួលការចាក់វ៉ាក់សាំង Hepatitis B ២ ឬ៣ដង ហើយ តែទីបំផុតក្មេងនៅតែកើតជំងឺថ្លើមទៀត ។

**លោក វេជ្ជ. ស្វាត សារ៉ាត**

**អនុប្រធានកម្មវិធីជាតិផ្តល់ថ្នាំបង្ការ បានឆ្លើយថា :**

១. អាចមានមូលហេតុច្រើនយ៉ាង:

- ដោយសារវ៉ាក់សាំងខូចគុណភាព:
  - ការទុកដាក់ និងថែរក្សាក្នុងប្រព័ន្ធត្រជាក់ពុំបានល្អ( វ៉ាក់សាំងខូចដោយត្រូវកំដៅក្តៅ ឬ ធ្លាប់កកដោយសីតុណ្ហភាពក្រោមសូន្យអង្សារ)
  - វ៉ាក់សាំងហួសកាលកំណត់ប្រើប្រាស់
- ឬ ការផ្តល់វ៉ាក់សាំងដល់កុមារពុំត្រូវតាមបច្ចេកទេស ដូចជាក៏រិតដូសវ៉ាក់សាំងពុំគ្រប់គ្រាន់ ឬពុំគោរពតាមប្រតិទិននៃការផ្តល់ថ្នាំបង្ការ ។
- ឬ អាចមានកុមារខ្លះក្នុងចំណោមកុមាររាប់ពាន់នាក់ ពុំបង្កើតបានជាអង់ទីគ័រឡើយទោះជាកុមារទាំងនោះបានទទួលវ៉ាក់សាំងគ្រប់ដូស និងត្រឹមត្រូវតាមបច្ចេកទេសក៏ដោយ ។

២. ជំងឺរលាកថ្លើមមានច្រើនប្រភេទ ហើយប្រភេទដែលជួបប្រទះច្រើនជាងគេ គឺជំងឺរលាកថ្លើមប្រភេទ អា បេ និងសេ ។
វ៉ាក់សាំង Hepatitis B ពុំអាចការពារជំងឺរលាកថ្លើមប្រភេទផ្សេងៗ ក្រៅពីជំងឺរលាកថ្លើម ប្រភេទបេ_បានឡើយ ។
ចំពោះវ៉ាក់សាំង Hepatitis B អាចមានប្រសិទ្ធភាពការពារជំងឺរលាកថ្លើមប្រភេទបេបាន លុះត្រាតែវ៉ាក់សាំងមានគុណភាពល្អ ទុកដាក់ថែទាំត្រឹមត្រូវ និងផ្តល់ត្រូវតាមបច្ចេកទេស ។
ការផ្តល់អោយបានមុន Virus Hepatitis B ឆ្លងមកកុមារ ឬ ទារកនោះវាជាការសំខាន់ ពីព្រោះនៅប្រទេសកម្ពុជាបច្ចុប្បន្នអត្រាស្ត្រីផ្ទុក Virus Hepatitis B (HBV) មានប្រមាណពី៣-៥% ។ ស្ត្រីទាំងនេះអាចចំលង Virus Hepatitis B ទៅទារកតាមការដាច់រលាត់ នៅកំឡុងពេលសំរាល ( Perinatal Transmition ) ។
ដូច្នេះដើម្បីកុមារជៀសផុតពីជំងឺរលាកថ្លើមប្រភេទបេ ត្រូវតែផ្តល់ Vaccine Hepatitis B អោយបានត្រឹមត្រូវតាមបច្ចេកទេសគឺ:

- កំឡុង២៤ម៉ោងក្រោយសំរាល (ឬមុនអាយុ៧ថ្ងៃ) Hep B ដូសពេលកើត (គឺដើម្បីទប់ស្កាត់ការចំលងពីម្តាយទៅទារកកំឡុងពេលសំរាល)
- អាយុ ១ខែ កន្លះ DTP-Hep B 1
- អាយុ ២ខែ កន្លះ DTP-Hep B 2
- អាយុ ៣ខែ កន្លះ DTP-Hep B 3

លោក **កែវ សារុន** គិលានុបដ្ឋាកមធ្យម ធ្វើការនៅមណ្ឌលសុខភាពព្រះនិពាន្ធ ស្រុកប្រតិបត្តិគងពិសី ខេត្តកំពង់ស្ពឺ បានសួរថា អ្នកជំងឺអេដស៍ម្នាក់ (តាមការពិនិត្យឈាម) ផ្ទុកមេរោគអេដស៍ប្រហែល២ឆ្នាំហើយ (មានចេញរោគសញ្ញា) ប៉ុន្តែឥឡូវនេះ ពេលពិនិត្យម្តងទៀត បែរជាមិនឃើញអត្តសញ្ញាណ ហើយថែមទាំងមានសភាពស្រស់ថ្លាដូចដើម តើគាត់ជាមែនទេ ?

**លោកវេជ្ជ. សរិត សុវណ្ណរិទ្ធិ**
**មន្ត្រីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានឆ្លើយថា :**

សព្វថ្ងៃនេះ ពុំទាន់មានឱសថព្យាបាលជំងឺអេដស៍អោយជាសះស្បើយទេ ដូច្នេះករណីដែលមនុស្សម្នាក់មានផ្ទុកមេរោគអេដស៍អាចជាសះស្បើយដោយគ្មានមេរោគអេដស៍នៅក្នុងខ្លួននោះពុំអាចទៅរួចទេ។ ចំពោះអ្នកជំងឺអេដស៍ដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ថ្នាំពន្យាជីវិត) គាត់អាចបាត់រោគសញ្ញា និងមានសភាពស្រស់ថ្លាឡើងវិញ តែនៅតែមានផ្ទុកមេរោគអេដស៍ដដែល ដែលអាចមើលឃើញតាមរយៈការធ្វើតេស្តឈាមរកមេរោគអេដស៍។ ចំពោះករណីក្នុងសំណួរខាងលើ មានចំនុចសង្ស័យខ្លះទាក់ទងនឹងគុណភាពនៃការធ្វើតេស្ត។ តើអ្នកជំងឺនេះទៅពិនិត្យឈាមរកមេរោគអេដស៍នៅមន្ទីរពិសោធន៍ណា? តើមន្ទីរពិសោធន៍នោះមានការធានាគុណភាពនៃការធ្វើតេស្តដែរឬទេ?។ បើសិនជាមានករណីដូចក្នុងសំណួរខាងលើមែនគេត្រូវពិនិត្យឡើងវិញនូវគុណភាពនៃមន្ទីរពិសោធន៍នោះ។

**បើលោកអ្នកមានសំនួរដែលទាក់ទងទៅនឹងការងារប្រចាំថ្ងៃរបស់លោកអ្នក សូមផ្ញើសំនួរទាំងនោះមកយើងខ្ញុំ។ សំនួររបស់លោកអ្នក នឹងត្រូវបានឆ្លើយដោយអ្នកជំនាញ និងបានចុះផ្សាយជូនលោកអ្នកក្នុងទស្សនាវដ្តីសុខភាព។**

**Send in your questions and we will get an expert to answer them for you! Write, phone or fax PSP**

អង្គការពន្លឺសុខភាព
ផ្ទះលេខ៣៤ ផ្លូវលេខ៣០៤ សង្កាត់អូឡាំពិក
រាជធានីភ្នំពេញ ប្រអប់សំបុត្រ ៤៦៤
ទូរស័ព្ទ: ០២៣ ២១២ ៦០០



## ឥឡូវនេះ បន្ទាប់ពីលោក-លោកស្រីបានអានសៀវភៅទស្សនាវដ្ដីសុខភាពរួច តើលោក-លោកស្រីយល់យ៉ាងណាដែរចំពោះសៀវភៅទស្សនាវដ្ដីសុខភាព?

**យើងខ្ញុំស្វាគមន៍យ៉ាងកក់ក្ដៅចំពោះរាល់មតិរិះគន់ ឬសំណូមពរផ្សេងៗ**

ការធ្វើដូច្នេះនឹងជួយឱ្យយើងដឹងថាតើលោក-លោកស្រីត្រូវការអ្វីពីទស្សនាវដ្ដីសុខភាព

សូមចំណាយពេលវេលា២-៣នាទីបំពេញទំរង់ខាងក្រោម ហើយផ្ញើមកយើងខ្ញុំវិញ។

ឈ្មោះ ______________________ លេខទូរស័ព្ទ: ______________________

មន្ទីរពេទ្យ/មណ្ឌលសុខភាព: ______________________ ខេត្ត: ______________________

______________________________________________

យោបល់: ______________________________________

______________________________________________

______________________________________________

សំនួរ: ______________________________________

______________________________________________

______________________________________________

សំណូមពរ: ____________________________________

______________________________________________

______________________________________________

(សូមសរសេរលើក្រដាសបន្ថែម បើចាំបាច់)

សូមផ្ញើមកអង្គការពន្លឺសុខភាព ផ្ទះលេខ ៣៤ ផ្លូវលេខ ៣០៤ រាជធានីភ្នំពេញ ឬតាមរយៈមន្ត្រីសុខាភិបាល ដែលចែកចាយសៀវភៅទស្សនាវដ្ដីសុខភាពនៅតាមស្រុកប្រតិបត្តិ ឬមន្ទីរសុខាភិបាល។


BAYER
Laroscorbine®
Vitamin C 1000mg
មួយថ្ងៃពិសារតែមួយគ្រាប់
ជួយពង្រឹងប្រព័ន្ធការពារ
សារពាង្គកាយលោកអ្នក
ប្រឆាំងទប់ទល់នឹង
ជម្ងឺផ្តាសសាយបាន
Laroscorbine
Laroscorbine®

# Malarine® 3 DAY MALARIA TREATMENT ព្យាបាលគ្រុនចាញ់យ៉ាងស័ក្តិសិទ្ធិប្រើពេលតែ ៣ថ្ងៃ

## តើ Malarine® គឺជាអ្វី?

**ម៉ាឡារីន** គឺជាថ្នាំគ្រាប់លេបសំរាប់ព្យាបាលជំងឺគ្រុនចាញ់ស្រាល ដែលបង្កដោយប្លាស្មូឌ្យូម ហ្វាល់ស៊ីប៉ារ៉ូម ដ៏មានប្រសិទ្ធិភាពបំផុតអាច ព្យាបាល ឱ្យជាសះស្បើយក្នុងរយៈពេល តែ ៣ថ្ងៃប៉ុណ្ណោះ ។ ថ្នាំនេះផ្សំឡើងដោយថ្នាំ ២ មុខរួមគ្នាគឺ ៖

- មេហ្លូគីន (Mefloquine)
- អាតេស៊ុយណាត (Artesunate)។

## Malarine® សំរាប់មនុស្សធំ :




## របៀបប្រើប្រាស់:

ថ្នាំក្នុង១ប្រអប់ប្រើសំរាប់តែមនុស្សធំ ដែលមានជំងឺគ្រុនចាញ់ស្រាលម្នាក់ប៉ុណ្ណោះ មានអាយុចាប់ពី ១៣ ឆ្នាំឡើងទៅ និងមានទំងន់ខ្លួនលើសពី៣០ គីឡូក្រាម ។ ក្នុងបន្ទះថ្នាំនីមួយៗមាន: មេហ្លូគីន (២៥០ មីលីក្រាម) ៤គ្រាប់ និងថ្នាំអាតេស៊ុយណាត (២០០ មីលីក្រាម) ៣គ្រាប់ ។

- ហាមប្រើចំពោះស្ត្រីមានផ្ទៃពោះ៣ខែដំបូង
- ក្នុងករណីអ្នកជំងឺ មានទំងន់ខ្លួនលើសពី ៦០គីឡូក្រាម សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតជំនាញ

## ផលប៉ះពាល់ (ការធ្វើទុក្ខ) របស់ថ្នាំ :

បន្ទាប់ពីលេបថ្នាំនេះហើយ អ្នកជំងឺអាចមានការធ្វើទុក្ខខ្លះៗដូចជា៖

- ក្អួត ចង្អោរ វិលមុខ ឈឺពោះ ឈឺក្បាល ដេកមិនសូវលក់
- ការធ្វើទុក្ខទាំងនេះនឹងបាត់ទៅវិញ ក្នុងរយៈពេល ២ ឬ ៣ថ្ងៃ
- ការធ្វើទុក្ខផ្សេងៗទៀតដែលកម្រជួបមានដូចជាប៉ះពាល់ដល់បេះដូង លើសឈាម សរសៃប្រសាទ និងស្បែក។

## Malarine® សំរាប់ក្មេង :




## របៀបប្រើប្រាស់ :

ថ្នាំក្នុង១ប្រអប់នេះប្រើសំរាប់តែក្មេងមានជំងឺគ្រុនចាញ់ម្នាក់ប៉ុណ្ណោះ ដែលមានអាយុចាប់ពី ៦ឆ្នាំ ដល់ ១៣ ឆ្នាំ និងមានទំងន់ពី ១៥ គីឡូក្រាម ទៅ ៣០ គីឡូក្រាម ។ ក្នុងបន្ទះថ្នាំនីមួយៗមាន: មេហ្លូគីន (២៥០ មីលីក្រាម) ២គ្រាប់ និង ថ្នាំអាតេស៊ុយណាត (៥០ មីលីក្រាម) ៦គ្រាប់ ។

## ពិនិត្យឈាមមុនពេលប្រើថ្នាំនេះ :

តើត្រូវជ្រើសរើសឧបករណ៍អ្វី ដើម្បីពិនិត្យឈាម?

ប្រើប្រាស់ឧបករណ៍ធ្វើតេស្តរហ័សម៉ាក Malacheck® RAPID TEST FOR P. FALCIPARUM MALARIA ដើម្បីរកជំងឺគ្រុនចាញ់បង្កដោយប្លាស្មូឌ្យូមហ្វាល់ស៊ីប៉ារ៉ូមដោយប្រើរយៈពេលតែ ១៥ នាទី ហើយវាអាចផ្តល់នូវលទ្ធផលបានយ៉ាងឆាប់រហ័ស ។




លទ្ធផលមានមេរោគគ្រុនចាញ់ហ្វាល់ស៊ីប៉ារ៉ូម




លទ្ធផលគ្មានមេរោគគ្រុនចាញ់ហ្វាល់ស៊ីប៉ារ៉ូម

**ទទួលស្គាល់ និងអនុញ្ញាតដោយក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក**


ផ្ទះលេខ29 ផ្លូវលេខ334 ក្រុមប្រឹក្សា153 សង្កាត់ បឹងកេងកង១ ខណ្ឌ ចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855-23) 210 814/987 404 ទូរសារ : (855-23) 218 735 អ៊ីមែល : generalinfo@psi.org.kh វិបសាយ : http://www.psi.org


PSI CAMBODIA

# ទស្សនាវដ្ដីសុខភាព
## Health Messenger

ការជាវសំរាប់១ឆ្នាំ (មាន ៤លេខ)
Subscribe for one year (4 issues)

**$១០.០០* ដុល្លា**
$10.00* per year

សូមរួសរាន់ជាវទស្សនាវដ្ដីសុខភាព
ប្រចាំឆ្នាំ នៅមុនដំណាច់ឆ្នាំ២០០៦
លោកអ្នកនឹងទទួលបានរង្វាន់អាវយឺត
ទស្សនាវដ្ដីសុខភាពមួយដោយ**ឥតគិតថ្លៃ**។

Take out a new subscription before the end of 2006 and receive a **free** Health Messenger T-shirt.

**ទំរង់ជាវប្រចាំឆ្នាំ**
**Subscription Form**

កាលបរិច្ឆេទ
Date ______________

ឈ្មោះអង្គការ
Organization ______________________________

អាស័យដ្ឋាន
Address ______________________________

ឈ្មោះរបស់អ្នក
Your Name ______________________________

លេខទូរស័ព្ទ
Telephone ______________

អ៊ីម៉ែល (បើមាន)
E-mail (optional) ______________

សូមបំពេញទំរង់នេះ ហើយផ្ញើមកអង្គការពន្លឺសុខភាព ឬផ្ដល់ព័ត៌មានលំអិតមកយើងខ្ញុំ។
Please complete this form and send it to PSP, or contact us with your details.


អង្គការពន្លឺសុខភាព
ផ្ទះលេខ ៣៤ ផ្លូវលេខ ៣០៤
រាជធានីភ្នំពេញ ប្រអប់សំបុត្រ ៤៦៤
ទូរស័ព្ទ/ហ្វាក់: ០២៣ ២១២ ៦០០
អ៊ីម៉ែល: hmess@online.com.kh

**Ponleu Sokhapheap (PSP)**
**#34, Street 304, Olympic, Chamkarmon**
**Phnom Penh, Cambodia**
**PO Box 464**
**Tel/Fax: 023 212 600**
**E-mail: hmess@online.com.kh**


*ការបញ្ចុះតំលៃត្រូវបានផ្ដល់ជូនចំពោះការជាវច្រើន សូមទាក់ទងអង្គការពន្លឺសុខភាព
*Discounts available for bulk orders. Please contact PSP.

# Rely on PSP for developing IEC and training materials

Our core job is to design and create quality information, education and communication materials.

## What PSP provides

### PSP: a team of professionals

We have more than 7 years experience in the production of IEC materials.

### PSP: a bunch of skills

The team combines all the skills required: writing, designing, testing, photography, illustration...you have them all at hand.

### PSP: a professional service

We are a cost effective solution - providing a complete package from conception and design, pre-testing and testing, printing and finishing, distribution and monitoring, to impact assessment.

PSP has established relationships with printers, and can provide the best price-quality ratio.

We can distribute materials throughout Cambodia.

### PSP: our clients

Our clients include UNICEF, The National Institute of Public Health, CIOMAL and USAID-HSSC. Our products range from flipcharts, posters, booklets, brochures to newsletters and banners.

PSP follows the IEC Materials Production Guidelines from the National Centre for Health Promotion.

We can manage the complete package for you.

- Select appropriate IEC materials
- Develop a creative brief
- Prepare prototype of IEC materials
- Pretest materials
- Assess pretesting results and revise materials
- Monitor use and impact of materials

**For a detailed proposal and quotation, please contact Lao Chantha at PSP.**
**Telephone: 023 212 600 Email: hmess3@online.com.kh**

PSP is a registered non-profit organisation.

# ជំរើស ៣ សំរាប់មធ្យោបាយពន្យារកំណើត









- **OK® Condom (អូខេ ខុនដុម) :**
  មានគុណភាព និងមានប្រសិទ្ធិភាពខ្ពស់ជួយការពារ ការមានផ្ទៃពោះដោយចៃដន្យ ការពារជំងឺអេដស៍ និងជំងឺកាមរោគផ្សេងៗទៀត ។

- **ថ្នាំគ្រាប់ពន្យារកំណើត OK® :**
  លេប ១ថ្ងៃ ១ គ្រាប់ រៀងរាល់ថ្ងៃ និងទៀងពេល មានប្រសិទ្ធិភាព និងសុវត្ថិភាពខ្ពស់ ដើម្បីការពារការ មានផ្ទៃពោះ និងសំរាប់ពន្យារកំណើត ។




ជ្រើសរើស
មួយណាក៏
OK

- **ថ្នាំចាក់ពន្យារកំណើត OK® :**
  មានប្រសិទ្ធិភាពខ្ពស់សំរាប់ស្ត្រី ដែលចាក់ ១ដង អាចការពារ ការមានផ្ទៃពោះរយៈពេល ៣ខែ និងសំរាប់ពន្យារកំណើត ។

សូមជួបជាមួយអ្នកផ្តល់សេវាពន្យារកំណើត ដើម្បីប្រឹក្សាអំពីមធ្យោបាយ ពន្យារកំណើតដែលសក្តិសមបំផុតសំរាប់អ្នក នៅមណ្ឌលសុខភាព ឬបន្ទប់ពិគ្រោះព្យាបាលជំងឺសញ្ញាព្រះអាទិត្យ ។

OK®
គ្រួសារសុខសាន្ត

PSI We Care About Your Health
USAID
DFID Department for International Development
KfW
UNFPA